សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

## សារណាបញ្ចប់ការសិក្សា

# ទំនាក់ទំនងរវាងទីផ្សារមូលបត្រ និង កិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ

ស្រាវជ្រាវពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ខែឧសភា ឆ្នាំ២០២០

តាក់តែងឡើង
និស្សិតឈ្មោះ៖ **យឿន ឡេកហ៊ាង**
**ខៀវ ស្រីភា**

សាស្ត្រាចារ្យណែនាំ
លោក **សាន មន្តិយ៉ា**

ថ្នាក់បរិញ្ញាបត្រ ធនាគារ និងហិរញ្ញវត្ថុ
ជំនាន់ទី១៣

ឆ្នាំចូលសិក្សា ២០១៦
ឆ្នាំសរសេរសារណា ២០២០

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **យឿនហ្គេកហ៊ាង** និង **ខៀវស្រីកា** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកធនាគារ និងហិរញ្ញវត្ថុ ឆ្នាំទី៤ ជំនាន់ទី១៣ នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចក្នុងឆ្នាំសិក្សា២០១៦ ដល់ ២០២០ ដែលបានធ្វើពីប្រធានបទស្តីពី "ទំនាក់ទំនងរវាងទីផ្សារមូលបត្រ និងកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ"។ ហើយយើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ៖

- លោកអ្នកមានគុណទាំងពីរដែលលោកទាំងពីរជាអ្នកផ្តល់កំណើត និងបានចិញ្ចឹមបីបាច់ថែរក្សាប្រកបដោយព្រហ្មវិហារធម៌។ មិនត្រឹមតែប៉ុណ្ណោះលោកក៏បានរកគ្រប់វិធីសាស្ត្រដើម្បីផ្គត់ផ្គង់ដល់ការសិក្សារបស់យើងខ្ញុំរហូតដល់បានបញ្ចប់ថ្នាក់បរិញ្ញាបត្រ។
- អរគុណដល់លោកគ្រូ អ្នកគ្រូនៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលពួកគាត់បានផ្តល់នូវចំណេះដឹង ក៏ដូចជាចែករំលែកនូវបទពិសោធន៍ មកដល់យើងខ្ញុំទាំងអស់គ្នា។
- ជាពិសេសយើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសាស្ត្រាចារ្យ **សាន មន្និយ៉ា** ដែលបានដឹកនាំចង្អុលបង្ហាញផ្លូវក៏ដូចជាបានប្រាប់នូវគន្លឹះសំខាន់ៗក្នុងការប្រមូលនូវព័ត៌មាន និងបានជួយកែសម្រួលសារណារបស់យើងខ្ញុំអោយកាន់តែប្រសើរឡើង។
- សូមថ្លែងអំណរគុណដល់រៀមច្បងដែលគាត់បានបន្សល់ទុកនូវស្នាដៃនិងឯកសារសម្រាប់ឲ្យសិស្សប្អូនជំនាន់ក្រោយបានយកទៅធ្វើការសិក្សាស្វែងយល់បន្ថែមដើម្បីបង្កើនចំណេះដឹង។
- ជាកិច្ចបញ្ចប់ យើងខ្ញុំទាំងអស់គ្នាសូមប្រសិទ្ធពរជ័យជូនចំពោះអ្នកមានគុណទាំងអស់គ្នាឲ្យមានសុខភាពល្អនិងជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលកុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ជាបឋម យើងខ្ញុំសូមលំឱនកាយអនុញ្ញាតគោរពជំរាបសួរលោកគ្រូ អ្នកគ្រូនៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចក្នុងឆ្នាំសិក្សា ២០១៦-២០២០ និងមិត្តនិស្សិតជាទីគោរព។ បន្ទាប់ពីបានធ្វើការសិក្សាអស់រយៈពេល៤ឆ្នាំ នៅសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្រុមរបស់យើងខ្ញុំបានសម្រេចចិត្តជ្រើសរើសយកការធ្វើសារណាដើម្បីបញ្ចប់ការសិក្សា សម្រាប់ទុកជាសមិទ្ធិផលចុងក្រោយរបស់យើងខ្ញុំដែលបានសិក្សាអស់រយៈពេល៤ឆ្នាំ ផ្នែកធនាគារ និងហិរញ្ញវត្ថុ។

ចំពោះសារណាដែលក្រុមយើងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវនេះគឺស្តីពីប្រធានបទ "ទំនាក់ទំនងរវាងទីផ្សារមូលបត្រ និងកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ" គឺធ្វើឡើងដើម្បីស្វែងរកនូវចំណេះដឹងបន្ថែមទៀតអំពីទីផ្សារមូលបត្រក៏ដូចជាការរីចម្រើនរបស់ប្រទេសជាតិផងដែរ។ ដោយយើងខ្ញុំសង្កេតឃើញថាសព្វថ្ងៃនេះទីផ្សារមូលបត្របានដើរតួនាទីយ៉ាងសំខាន់សម្រាប់សេដ្ឋកិច្ចជាតិយើង ដែលគេតែងតែនិយាយថា ទីផ្សារមូលបត្រគឺជានិមិត្តរូបជាតិមួយទាំងមូល។ ជាការពិតណាស់រាល់បម្រែបម្រួលនៃបរិបទជាតិ និងអន្តរជាតិ (សេដ្ឋកិច្ច សង្គម និងនយោបាយ) វាតែងតែធ្វើឲ្យមានផលប៉ះពាល់ដល់ទីផ្សារមូលបត្រ។

ជាចុងក្រោយនេះយើងខ្ញុំសូមថ្លែងអំណរគុណដល់លោកគ្រូ អ្នកគ្រូ និងមិត្តអ្នកអានទាំងឡាយដែលបានចំណាយពេលដល់មានតម្លៃក្នុងការអានកិច្ចការស្រាវជ្រាវមួយនេះ។ ប្រសិនបើកិច្ចការស្រាវជ្រាវនេះមានកង្វះខ្វះខាតដោយប្រការណាមួយ និងកំហុសឆ្គងដោយអចេតនាដោយសារការយល់ដឹងរបស់យើងខ្ញុំនៅមានកម្រិត។ ហើយយើងខ្ញុំក៏សង្ឃឹមថាឯកសារមួយនេះពិតជាបានផ្តល់នូវអត្ថប្រយោជន៍ ដល់អ្នកទាំងអស់គ្នាជាពិសេសនិស្សិតដែលធ្វើការសិក្សាស្រាវជ្រាវទាក់ទងជាមួយប្រធានមួយនេះ។

ជាកិច្ចបញ្ចប់យើងខ្ញុំរីករាយ និងទទួលស្វាគមន៍នូវរាល់មតិរិះគន់ដើម្បីស្តាបនាពីសំណាក់អ្នកទាំងអស់គ្នាដើម្បីធ្វើការកែសម្រួលឲ្យកាន់តែមានភាពប្រសើរឡើងជាងមុន។

# មាតិកា


បញ្ជីអក្សរកាត់ ........ v

បញ្ជីតារាង ........ vi

បញ្ជីរូបភាព ........ vi

បញ្ជីក្រាហ្វិច ........ vii


# សេចក្តីផ្តើម

# ជំពូកទី១

# រំលឹកទ្រឹស្តីទីផ្សារមូលបត្រ


១.១. ទីផ្សារមូលបត្រ ........ ៥

១.១.១. និយមន័យ ........ ៥

១.១.២. ប្រវត្តិទីផ្សារមូលបត្រ ........ ៥

១.២. ប្រភេទនៃមូលបត្រ ........ ៧

១.២.១. មូលបត្រកម្មសិទ្ធ ........ ៧

១.២.២. មូលបត្របំណុល ........ ៨

១.២.៣. ឧបករណ៍និស្សន្ទ ........ ៨

១.៣. ប្រភេទនៃទីផ្សារមូលបត្រ ........ ៩

១.៣.១. ទីផ្សារដំបូង ........ ៩

១.៣.២. ទីផ្សារបន្ទាប់ ........ ១០

១.៣.៣. ទីផ្សារមូលធន ........ ១០

១.៣.៤. ទីផ្សាររូបិយវត្ថុ ........ ១០

១.៤. អត្ថប្រយោជន៍នៃទីផ្សារមូលបត្រ ........ ១១

១.៤.១. ចំពោះវិនិយោគិន ........ ១១

១.៤.២. ចំពោះក្រុមហ៊ុន ........ ១២

១.៤.៣. ចំពោះសេដ្ឋកិច្ច ........ ១៣

១.៥. តួនាទីហិរញ្ញវត្ថុ និងទីផ្សារហិរញ្ញវត្ថុក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ........ ១៥

១.៥.១. តួនាទីហិរញ្ញវត្ថុក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ............ ១៥
១.៥.២. ទីផ្សារហិរញ្ញវត្ថុក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ............ ១៦

## ជំពូកទី២

## ដំណើរការទីផ្សារមូលបត្រកម្ពុជា

២.១. គណៈកម្មការមូលបត្រកម្ពុជា ............ ១៨
២.២. ចក្ខុវិស័យនិង បេសកម្មរបស់គ.ម.ក ............ ១៨
២.២.១. ចក្ខុវិស័យ ............ ១៨
២.២.២. បេសកម្ម ............ ១៩
២.២.៣. ទីតាំងរបស់គ.ម.ក ............ ១៩
២.៣. រូបសញ្ញានិង អត្ថន័យនៃរូបសញ្ញារបស់គ.ម.ក ............ ១៩
២.៣.១. រូបសញ្ញា ............ ១៩
២.៣.២. អត្ថន័យ ............ ២០
២.៣.៣. មូលហេតុនៃជម្រើសយករូបហង្សពណ៌មាសជានិមិត្តសញ្ញា ............ ២០
២.៣.៤. ត្រារបស់គណៈកម្មការមូលបត្រកម្ពុជា ............ ២១
២.៣.៥. រចនាសម្ព័ន្ធអង្គការចាត់តាំងគ.ម.ក ............ ២១
២.៤. តួនាទី និងភារកិច្ចរបស់គណៈកម្មការមូលបត្រកម្ពុជា ............ ២២
២.៥. ប្រធាននិង សមាជិករបស់គ.ម.ក ............ ២៤
២.៦. ការវិនិយោគក្នុងវិស័យមូលបត្រ ............ ២៥
២.៦.១. លក្ខខណ្ឌដែលត្រូវបំពេញដើម្បីវិនិយោគក្នុងវិស័យមូលបត្រ ............ ២៥
២.៦.២. បទប្បញ្ញត្តិដែលវិនិយោគិនត្រូវយល់ដឹងក្នុងវិស័យមូលបត្រ ............ ២៨
២.៧. ប្រភេទនៃការជួញដូរមូលបត្រ ............ ២៨
២.៧.១. ការបញ្ជាតាមថ្លៃ ............ ២៨
២.៧.២. ការបញ្ជាមានកំណត់ ............ ៣០
២.៧.៣. ការបញ្ជាតាមពេលវេលា ............ ៣១
២.៨. វិធាននៃប្រតិបត្តិការជួញដូរលើទីផ្សារ ............ ៣៣
២.៨.១. ម៉ោងជួញដូរ ............ ៣៣

២.៨.២. ឯកតាបញ្ជា និងឯកតាគម្លាត ........ ៣៣
២.៨.៣. ការវិភាគលើអនុបាតភាគហ៊ុន ........ ៣៤
២.៩. ការឲ្យខ្ចីមូលបត្រ ........ ៣៧
២.១០. ការផាត់ទាត់ និងការទូទាត់ ........ ៣៨
២.១០.១. ការផាត់ទាត់ ........ ៣៨
២.១០.២. ការទូទាត់ ........ ៣៩
២.១១. ប្រតិបត្តិការរក្សារទុកមូលបត្រ ........ ៤១

## ជំពូកទី៣

## ទំនាក់ទំនងរវាងទីផ្សារមូលបត្រ និងកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ

៣.១. ក្រុមហ៊ុនដែលចុះបញ្ជីលក់មូលបត្រ ........ ៤៣
៣.២. សកម្មភាពជួញដូរភាគហ៊ុនរបស់ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រកម្មសិទ្ធ ........ ៤៤
៣.២.១. ភាគហ៊ុនរបស់រដ្ឋករទឹកស្វយ័តក្រុងភ្នំពេញ ........ ៤៤
៣.២.២. ភាគហ៊ុនរបស់ក្រុមហ៊ុនហ្គ្រេន ធ្វីនអ៊ីនធើនេសិនណាល ........ ៤៦
៣.២.៣. ភាគហ៊ុនរបស់កំពង់ផែស្វយ័តភ្នំពេញ ........ ៤៨
៣.២.៤. ភាគហ៊ុនរបស់ភ្នំពេញអេស អ៊ី ហ្សិត ភីអិលស៊ី ........ ៥០
៣.២.៥. ភាគហ៊ុនរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ ........ ៥២
៣.៣. សកម្មភាពជួញដូរមូលបត្រកម្មសិទ្ធរបស់វិនិយោគិន ........ ៥៤
៣.៤. សកម្មភាពជួញដូរសញ្ញាបណ្ណរបស់ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្របំណុល ........ ៥៥
៣.៤.១. គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីធីត ........ ៥៥
៣.៤.២. គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី ........ ៥៥
៣.៤.៣. ធនាគារវឌ្ឍនៈអាស៊ីចំកាត់ ........ ៥៥
៣.៥. ស្ថិតិវិនិយោគ ........ ៥៦
៣.៥.១. ចំនួនវិនិយោគចាប់ពីឆ្នាំ២០១២ ដល់ត្រីមាសទី១ឆ្នាំ២០២០ ........ ៥៦
៣.៥.២. ចំនួនគណនីជួញដូរ ........ ៦០
៣.៥.៣. វិនិយោគិនដែល វិនិយោគក្នុងទីផ្សារប្រចាំត្រីមាសទី១ឆ្នាំ២០២០ ........ ៦០
៣.៥.៤. ចំនួនបញ្ជាទិញ និងលក់ ........ ៦១

៣.៦. ទិន្នន័យសង្ខេបនៃការជួញដូរប្រចាំត្រីមាសទី១ឆ្នាំ២០២០ ........................................ ៦២
៣.៧. សន្ទស្សន៍ ផ.ម.ក ........................................................................................ ៦៣
៣.៨. ចំណុចខ្លាំង និងចំណុចខ្សោយ ........................................................................ ៦៤

## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

១. សេចក្តីសន្និដ្ឋាន ........................................................................................ ៦៥
២. ការផ្តល់អនុសាសន៍ ...................................................................................... ៦៥
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# អក្សរកាត់

- **គ.ម.ក** = គណៈកម្មការមូលបត្រកម្ពុជា
- **ផ.ម.ក** = ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- SECC = Securities and Exchange Commission Cambodia
- CSX = Cambodia Securities Exchange
- NBC = National Bank of Cambodia
- CSD = Central Securities Dopository
- SF = Securities Firm
- IPO = Initial Public Offering
- CSA = Cash Securities Exchange
- CSO = Clearing and Settlement Operator
- OTC = Over the Counter

# បញ្ជីតារាង

តារាងទី១៖ ពេលវេលាជួញដូរនៅផ្សារមូលបត្រកម្ពុជា ............................................................ ៣៣
តារាងទី២៖ ឯកតាគម្លាតថ្លៃ ............................................................................................ ៣៤
តារាងទី៣៖ ទិដ្ឋភាពទូទៅនៃការជួញដូរភាគហ៊ុន PWSA...................................................... ៤៤
តារាងទី៤៖ ទិដ្ឋភាពទូទៅនៃការជួញដូរភាគហ៊ុន GTI............................................................ ៤៦
តារាងទី៥៖ ទិដ្ឋភាពទូទៅនៃការជួញដូរភាគហ៊ុន PPAP ......................................................... ៤៨
តារាងទី៦៖ ទិដ្ឋភាពទូទៅនៃការជួញដូរភាគហ៊ុន PPSP ......................................................... ៥០
តារាងទី៧៖ ទិដ្ឋភាពទូទៅនៃការជួញដូរភាគហ៊ុន PAS ........................................................... ៥២
តារាងទី៨៖ ទិដ្ឋភាពទូទៅនៃការជួញដូរមូលបត្រកម្មសិទ្ធ ......................................................... ៦២

# បញ្ជីរូបភាព

រូបភាពទី១៖ រូបសញ្ញា និងអត្ថន័យនៃគ.ម.ក. ......................................................................... ១៩
រូបភាពទី២៖ ត្រារបស់គ.ម.ក. ........................................................................................... ២១
រូបភាពទី៣៖ គណៈកម្មការមូលបត្រកម្ពុជា.............................................................................. ២១

# បញ្ជីក្រាហ្វិច

ក្រាហ្វិចទី១៖ ថ្លៃភាគហ៊ុនធៀប និងទំហំជួញដូររបស់ភាគហ៊ុន PWSA.................................... ៤៥
ក្រាហ្វិចទី២៖ បញ្ជាទិញ និងលក់ភាគហ៊ុន PWSA តាមប្រភេទវិនិយោគិន ................................ ៤៦
ក្រាហ្វិចទី៣៖ ថ្លៃភាគហ៊ុនធៀប និងទំហំជួញដូររបស់ភាគហ៊ុន GTI........................................ ៤៧
ក្រាហ្វិចទី៤៖ បញ្ជាទិញ និងលក់ភាគហ៊ុន GTI តាមប្រភេទវិនិយោគិន ..................................... ៤៨
ក្រាហ្វិចទី៥៖ ថ្លៃភាគហ៊ុនធៀប និងទំហំជួញដូររបស់ភាគហ៊ុន PPAP ...................................... ៤៩
ក្រាហ្វិចទី៦៖ បញ្ជាទិញ និងលក់ភាគហ៊ុន PPAP តាមប្រភេទវិនិយោគិន.................................. ៥០
ក្រាហ្វិចទី៧៖ ថ្លៃភាគហ៊ុនធៀប និងទំហំជួញដូររបស់ភាគហ៊ុន PPSP ...................................... ៥១
ក្រាហ្វិចទី៨៖ បញ្ជាទិញ និងលក់ភាគហ៊ុន PPSP តាមប្រភេទវិនិយោគិន.................................. ៥២
ក្រាហ្វិចទី៩៖ ថ្លៃភាគហ៊ុនធៀប និងទំហំជួញដូររបស់ភាគហ៊ុនPAS......................................... ៥៣
ក្រាហ្វិចទី១០៖ បញ្ជាទិញ និងលក់ភាគហ៊ុន PAS តាមប្រភេទវិនិយោគិន.................................. ៥៤
ក្រាហ្វិចទី១១៖ ការចូលរួមរបស់វិនិយោគិនខ្មែរ និងបរទេស ..................................................... ៥៤
ក្រាហ្វិចទី១២៖ ចំនួនវិនិយោគិនសរុប (២០២០ ដល់ត្រីមាសទី១ ឆ្នាំ២០២០)............................. ៥៦
ក្រាហ្វិចទី១៣៖ វិនិយោគិនជាមួយ និងនីតិបុគ្គលទៅតាមឆ្នាំនីមួយៗ.......................................... ៥៧
ក្រាហ្វិចទី១៤៖ វិនិយោគិនសរុបជារូបវន្តបុគ្គល និងនីតិបុគ្គល .................................................. ៥៧
ក្រាហ្វិចទី១៥៖ វិនិយោគិនសញ្ជាតិខ្មែរ និងសញ្ជាតិបរទេសទៅតាមឆ្នាំនីមួយៗ............................ ៥៨
ក្រាហ្វិចទី១៦៖ វិនិយោគិនសញ្ជាតិខ្មែរ និងសញ្ជាតិបរទេស...................................................... ៥៨
ក្រាហ្វិចទី១៧៖ ចំនួនវិនិយោគិនជារូបវន្តបុគ្គលតាមសញ្ជាតិ..................................................... ៥៩
ក្រាហ្វិចទី១៨៖ ចំនួនវិនិយោគិនជានីតិបុគ្គលតាមសញ្ជាតិ ........................................................ ៥៩
ក្រាហ្វិចទី១៩៖ វិនិយោគិនតាមភេទ (ប្រុស និងស្រី) .............................................................. ៥៩
ក្រាហ្វិចទី២០៖ គណនីជួញដូរ ត្រីមាសទី១ ឆ្នាំ២០២០............................................................ ៦០
ក្រាហ្វិចទី២១៖ ចំនួនបញ្ជាទិញ និងលក់ភាគហ៊ុនចុះបញ្ជីរបស់វិនិយោគិន................................... ៦១
ក្រាហ្វិចទី២២៖ ទំហំជួញដូររបស់ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ (គិតជាភាគរយ) ......................... ៦៣
ក្រាហ្វិចទី២៣៖ ទំហំជួញដូរសរុប និងសន្ទស្សន៍ ផ.ម.ក.......................................................... ៦៣

# សេចក្តីផ្តើម

សេដ្ឋកិច្ចនៅប្រទេសកម្ពុជានៅតែមានលក្ខណៈរឹងមាំ ហើយមានការកើនឡើង៧% ជារៀងរាល់ឆ្នាំរយៈពេល២០ឆ្នាំមកហើយ។ ប្រទេសកម្ពុជាមានល្បឿនកំណើនសេដ្ឋកិច្ចខ្លាំងបំផុត ក្នុងចំណោមសេដ្ឋកិច្ចប្រទេសផ្សេងៗប្រចាំតំបន់ដែលមានការកើនឡើង៧.១% នៅក្នុងឆ្នាំ២០១៨ ដែលកំណើននេះនាំមុខដោយសារតម្រូវការប្រើប្រាស់ទំនិញក្នុងស្រុក និងការនាំចេញ។ ដោយឡែកនៅតំបន់អាស៊ី មនុស្សមួយចំនួនតែងគិតថា ប្រទេសឡាវជាប្រទេសមួយដែលក្រីក្របំផុតក្នុងតំបន់អាស៊ីអាគ្នេយ៍។ ប៉ុន្តែបច្ចុប្បន្ននេះ វាមិនមែនដូចជាអ្វីដែលអ្នកគិតនោះទេ។ ប្រទេសឡាវ មានសេដ្ឋកិច្ចលូតលាស់លឿនបំផុតមួយនៅលើពិភពលោកដែលមានកំណើនជាមធ្យម៨% ក្នុងមួយឆ្នាំបើគិតទៅលើកំណើនផលិតផលក្នុងស្រុកសរុប។ ភាពរីកចម្រើនដ៏គួរឲ្យកត់សម្គាល់ ដែលជាហេតុផលទាក់ទាញវិនិយោគិនបរទេសមកវិនិយោគក្នុងប្រទេសនេះបន្ថែមមួយកម្រិតទៀត។ បើនិយាយពីប្រាក់ចំណូលក្នុងមនុស្សម្នាក់ ប្រជាជនឡាវបច្ចុប្បន្នខ្ពស់ជាងប្រជាជនវៀតណាម ភូមា និងកម្ពុជាទៀតផង។ ចំពោះវិស័យមូលបត្រវិញឡាវបង្កើតឡើងមុនកម្ពុជាតែពីរឆ្នាំប៉ុណ្ណោះ ហើយក៏មានភាគហ៊ុនវិនិយោគពីក្រុមហ៊ុនកូរ៉េ៤៩% ប្រហាក់ប្រហែលនឹងការបង្កើតឡើងនៃផ្សារមូលបត្រកម្ពុជាកាលពីឆ្នាំ២០១២ដែរ។ ផ្សារមូលបត្រឡាវបង្កើតឡើងក្នុងឆ្នាំ២០១០ នៅទីក្រុងវៀងចន្ទប្រទេសឡាវ។ ផ្សារមូលបត្រឡាវ មានភាគហ៊ុនរបស់ក្រុមហ៊ុនកូរ៉េចំនួន៤៩% និងក្រុមហ៊ុនឡាវចំនួន៥១%។ មិនខុសពីមុខងារនៃផ្សារមូលបត្រប្រទេសដទៃទេ ទីផ្សារមូលបត្រឡាវជាកន្លែងចាំបាច់ក្នុងការបង្កើតទីផ្សារមូលធនដើម្បីស្វែងរកដើមទុនផ្តល់ឲ្យក្រុមហ៊ុនចុះបញ្ជី ដែលត្រូវការសម្រាប់ការពង្រីកអភិវឌ្ឍន៍ការផលិត និងសេវាកម្មរបស់ពួកគេប្រកបដោយចីរភាព។

រីឯប្រទេសវៀតណាមវិញ មានទីក្រុងពាណិជ្ជកម្មធំៗចំនួនពីរ ដែលគេតែងតែស្គាល់ភាគច្រើន គឺទីក្រុងហាណូយ និងទីក្រុងហូជីមិញ។ ចាប់តាំងពីមានវត្តមាននៅប្រទេសវៀតណាមនៅឆ្នាំ២០០៥ មកគេសង្កេតឃើញថា ទីផ្សារមូលបត្រនៃប្រទេសនេះបានក្លាយជាចំណែកមួយដែលជួយជម្រុញឲ្យវិស័យសេដ្ឋកិច្ចប្រទេសមួយនេះ កាន់តែរីកចម្រើនបន្ថែមមួយកម្រិតទៀត។ ក្នុងឆ្នាំ២០០៥ ក្រុមហ៊ុនដែលចុះបញ្ជីក្នុងផ្សារមូលបត្រមានត្រឹមតែ៦ ប៉ុណ្ណោះប៉ុន្តែមកដល់ពាក់កណ្តាលឆ្នាំ២០១២ ក្រុមហ៊ុនដែលចុះបញ្ជីជាមួយផ្សារមូលបត្រហាណូយបានកើនឡើងរហូតដល់៣៩៨ក្រុមហ៊ុន។ តាំងពីផ្សារមូលបត្រហាណូយត្រូវបានបង្កើតឡើងមកគឺទទួលបានភាពជោគជ័យយ៉ាងខ្លាំងចំពោះការដេញថ្លៃភាគហ៊ុន ដែលវាជាផ្នែកមួយដែលធ្វើឲ្យសេដ្ឋកិច្ចនៃប្រទេសមួយនេះកាន់តែរីកចម្រើនរហូតមក។ រីឯក្រុមហ៊ុនដែលចុះបញ្ជីជាមួយផ្សារមូលបត្រហូជីមិញក៏កើនឡើងដល់៣៩៦ក្រុមហ៊ុនដែរ។ ផ្សារហ៊ុនទាំងពីរនេះមានគម្រោងក្នុងការប្រេបាច់បញ្ចូល

គ្នាតាំងពីឆ្នាំ២០១១ មកម្ល៉េះគោលបំណងក្នុងការច្របាច់បញ្ចូលគ្នាមួយនេះ គឺដើម្បីជួយជម្រុញទៅដល់សេដ្ឋកិច្ចជាតិឲ្យកាន់រីកចម្រើនជាងមុន និងដើម្បីជួយសម្រួលដល់វិនិយោគិនទាំងអស់ឲ្យមានភាពងាយស្រួលក្នុងការវិនិយោគ និងមានភាពរហ័សរហួនជាងមុន។ ផ្សារមូលបត្រដើរតួរយ៉ាងសំខាន់ក្នុងសេដ្ឋកិច្ចរបស់ប្រទេសនីមួយៗដោយវាអនុញ្ញាតឲ្យក្រុមហ៊ុនសារជីវកម្ម សហគ្រាសសាធារណៈ និងរដ្ឋាភិបាលអាចប្រមូលទុនដោយផ្ទាល់ពីសាធារណៈជន ឬកៀរគរមូលធនដែលនៅសេសសល់មិនមានតម្រូវការប្រើប្រាស់យកទៅវិនិយោគក្នុងសេដ្ឋកិច្ច។

ដោយឡែកបើយើងក្រឡេកមកមើល ការអភិវឌ្ឍវិស័យមូលបត្រនៅកម្ពុជាវិញ គេសង្កេតឃើញថាវិស័យមូលបត្រកម្ពុជា មានលក្ខណៈក្មេងខ្ចីនៅឡើយបើប្រៀបធៀបជាមួយបណ្ដាប្រទេសផ្សេងទៀត។ ការផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងវិស័យមូលបត្រមិនទាន់ទូលំទូលាយ ព្រោះប្រហែលជាផ្សារមូលបត្រទើបតែមានវត្តមាននៅកម្ពុជា ដែលជាហេតុធ្វើឲ្យវិនិយោគិនមិនទាន់មានលក្ខណៈល្អប្រសើរ។ដោយមើលឃើញចំណុចខ្វះខាតទាំងនេះទើបយើងខ្ញុំសម្រេចចិត្តជ្រើសរើសប្រធានបទ "ទំនាក់ទំនងរវាងផ្សារមូលបត្រ និងកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ" ដើម្បីស្រាយបំភ្លឺនូវចម្ងល់របស់វិនិយោគិនដែលមានចំណាប់អារម្មណ៍ចង់វិនិយោគក្នុងវិស័យនេះ។ ដើម្បីសម្រេចគោលបំណងនៃការស្រាវជ្រាវនេះប្រកបទៅដោយប្រសិទ្ធភាពទើបយើងខ្ញុំសម្រេចចិត្តបង្កើតនូវសំនួរដូចខាងក្រោម៖

តើទីផ្សារមូលបត្របង្កើតឡើងក្នុងគោលបំណងអ្វី ?

- តើទីផ្សារមូលបត្រមានតួនាទីដូចម្ដេចខ្លះក្នុងការជម្រុញដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ?
- តើវត្តមានទីផ្សារមូលបត្របានផ្ដល់នូវអត្ថប្រយោជន៍អ្វីខ្លះដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ?

ចំពោះប្រធានបទនៃការស្រាវជ្រាវនេះគឺសំដៅទៅលើទីផ្សារមូលបត្រនិងកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិជាពិសេសមុនពេលមានវត្តមានទីផ្សារមូលបត្រ នៅកម្ពុជានិងក្រោយពេលមានវត្តមានទីផ្សារមូលបត្រនៅកម្ពុជា មានការផ្លាស់ប្ដូរយ៉ាងដូចម្ដេច។

គោលបំណងនៃការស្រាវជ្រាវផ្ដោតសំខាន់លើចំណុចមួយចំនួនដូចខាងក្រោមនេះ៖

- ស្វែងយល់ពីនីតិវិធី និងលក្ខខណ្ឌចាំបាច់ក្នុងការជួញដូរមូលបត្រ
- ស្វែងយល់ពីតួនាទីទីផ្សារមូលបត្រក្នុងសេដ្ឋកិច្ចជាតិ

ជាក់ស្ដែងបើតាមស្ថានភាពមូលបត្រក្នុងប្រទេសយើងពេលបច្ចុប្បន្ន កំពុងតែរីកចម្រើនគួរឲ្យកត់សម្គាល់ក៏ប៉ុន្តែការវិវត្តនៃវិស័យមួយនេះពុំទាន់មានលក្ខណៈរីកលូតលាស់ខ្លាំង ដូចនៅបណ្ដាប្រទេសដទៃទៀតនៅឡើយទេ។ ដោយហេតុថាទីផ្សារមូលបត្រទើបតែបើកសម្ពោធឲ្យដំណើរការជាផ្លូវការនៅថ្ងៃទី១១

កក្កដា ឆ្នាំ២០១២ នោះការលូតលាស់នៃទីផ្សារមូលបត្រចំពោះកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចមិនសូវទូលំទូលាយទេ។ ដូចនេះហើយការស្រាវជ្រាវនេះនឹងធ្វើការសិក្សាទៅលើដំណើរនៃការវិវត្តទីផ្សារមូលបត្រក៏ដូចជាសមិទ្ធិផល និងបញ្ហាប្រឈមរាំងស្ទះដល់ទីផ្សារមូលបត្រកម្ពុជាដែលជាហេតុធ្វើឲ្យពុំសូវមានការរីកចម្រើនដូចប្រទេសដទៃទៀត។

ការសិក្សាស្រាវជ្រាវលើប្រធានបទមួយនេះ គឺបានផ្តល់នូវសារៈសំខាន់ជាច្រើនដូចជា៖

- ❖ ចំពោះយើងខ្ញុំ
  - ➢ ផ្តល់ជាចំណេះដឹងឲ្យកាន់តែច្បាស់លើវិស័យមូលបត្រនៅកម្ពុជា ដោយផ្សារភ្ជាប់ជាមួយនឹងទ្រឹស្តីដែលធ្លាប់បានសិក្សាកន្លងមក
  - ➢ យល់ដឹងពីការអភិវឌ្ឍវិស័យសេដ្ឋកិច្ច បន្ថែមលើទ្រឹស្តីដែលបានសិក្សាកន្លងមក
  - ➢ ពង្រឹងនៅសមត្ថភាពក្នុងការសិក្សាស្រាវជ្រាវ និងប្រមូលទិន្នន័យធ្វើជាភស្តុតាងក្នុងការតាក់តែងអត្ថបទនេះឡើង
  - ➢ ចេះវិភាគរៀបចំទិន្នន័យឲ្យមានរបៀបរៀបរយ និងមានទំនួលខុសត្រូវចំពោះការងាររបស់ខ្លួន
- ❖ ចំពោះនិស្សិត និងអ្នកស្រាវជ្រាវ
  - ➢ ជាទុនសម្រាប់និស្សិត និងអ្នកស្រាវជ្រាវទាំងអស់ដែលមានចំណាប់អារម្មណ៍ស្រាវជ្រាវទាក់ទងនឹងប្រធានបទនេះ
  - ➢ ស្គាល់នូវពាក្យបច្ចេកទេសថ្មីៗទាក់ទងនឹងវិស័យមូលបត្រ
  - ➢ រំលឹកឡើងវិញនៅទ្រឹស្តីដែលធ្លាប់បានសិក្សាកន្លងមក
- ❖ ចំពោះមជ្ឈដ្ឋានទូទៅ
  - ➢ ដើរតួរជាព័ត៌មាន និងជាឯកសារដល់សាធារណៈជនដែលមានបំណងចង់យល់ដឹងពីទំនាក់ទំនងទីផ្សារមូលបត្រចំពោះសេដ្ឋកិច្ចកម្ពុជា
  - ➢ យល់ដឹងច្បាស់មុនពេលចង់ប្រឡូកក្នុងវិស័យមូលបត្រ

ដើម្បីប្រមូលបានទិន្នន័យទាំងអស់នេះមកចងក្រងជាសារណា យើងខ្ញុំបានធ្វើការស្រាវជ្រាវដោយផ្អែកទៅលើទិន្នន័យសំខាន់ៗ ២គឺ ទិន្នន័យចម្បង និងទិន្នន័យបន្ទាប់បន្សំ។

- ❖ ទិន្នន័យចម្បង
  - ➢ ទទួលបានការណែនាំ និងចង្អុលបង្ហាញពីសាស្ត្រាចារ្យណែនាំ

- ទទួលបានការបកស្រាយ និងការណែនាំពីអ្នកជំនាញខាងផ្នែកនេះ

❖ ទិន្នន័យបន្ទាប់បន្សំ

- ឯកសារទាក់ទងនឹងប្រធានបទតាមរយៈការណែនាំរបស់សាស្ត្រាចារ្យណែនាំ
- ទិន្នន័យដែលស្វែងរកតាមប្រព័ន្ធអ៊ីនធឺណែត
- របាយការណ៍កម្មសិក្សា និងសារណាបញ្ចប់ការសិក្សារបស់និស្សិតរៀមច្បង ដែលពាក់ព័ន្ធនឹងប្រធានបទនេះ

ដើម្បីជាជំនួយដល់អ្នកអានសម្រាប់ស្វែងរកនូវខ្លឹមសារនៃប្រធានបទនេះ និងងាយស្រួលយល់ពីអត្ថន័យពីការសរសេរសារណាដែលសិក្សាពីប្រធានបទស្តីពី ″ទំនាក់ទំនងរវាងទីផ្សារមូលបត្រ និងកិច្ចអភិវឌ្ឍសេដ្ឋកិច្ចជាតិ″ នេះត្រូវបានបែងចែកជា ៣ជំពូក៖

- សេចក្តីផ្តើម
- ជំពូកទី១៖ វិលើកទ្រឹស្តីទីផ្សារមូលបត្រ
- ជំពូកទី២៖ ដំណើរការទីផ្សារមូលបត្រកម្ពុជា
- ជំពូកទី៣៖ ទំនាក់ទំនងរវាងទីផ្សារមូលបត្រ និងកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ

# ជំពូកទី១
# រំលឹកទ្រឹស្តីទីផ្សារមូលបត្រ

## ១.១. ទីផ្សារមូលបត្រ

### ១.១.១. និយមន័យ

ទីផ្សារមូលបត្រនៅកម្ពុជា ត្រូវបានបង្កើតឡើងស្របតាមទិសដៅរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុស៊ីជម្រៅទៅនឹងការគាំទ្រដល់កំណើនសេដ្ឋកិច្ចជាតិប្រកបដោយចីរភាព។ ជាការពិតណាស់ទីផ្សារមូលបត្រជាផ្នែកដ៏សំខាន់មួយនៃទីផ្សារហិរញ្ញវត្ថុដែលមានអត្ថប្រយោជន៍ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

ទីផ្សារមូលបត្រ គឺជាកន្លែងសម្រាប់ធ្វើការជួញដូរមូលបត្រ និងឧបករណ៍ហិរញ្ញវត្ថុដទៃទៀត។ តាមនិយមន័យច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជនគឺ "សំដៅដល់ទីផ្សារ ឬទីន្លែងជួញដូរមូលបត្រ ឬ ប្រព័ន្ធដែលផ្តល់មធ្យោបាយនៃការធ្វើសំណើលក់ ផ្ទេរ ឬធ្វើការទិញ-លក់មូលបត្រ" ឧបករណ៍ហិរញ្ញវត្ថុ ដែលតែងតែត្រូវបានជួញដូរលើទីផ្សារនេះរួមមានមូលបត្រកម្មសិទ្ធិ មូលបត្របំណុល និងឧបករណ៍និស្សន្ទជាដើម។

### ១.១.២. ប្រវត្តិទីផ្សារមូលបត្រ[1]

ទីផ្សារភាគហ៊ុន (Stock Market) មានប្រវត្តិតាំងពីយូរយារណាស់មកហើយ។ បច្ចុប្បន្នទីផ្សារនេះត្រូវបានគេធ្វើបច្ចុប្បន្នកម្មទៅជាទីផ្សារមូលបត្រ (Securities Market)។ ទីផ្សារភាគហ៊ុនប្រើប្រាស់រយៈពេលអស់រាប់សតវត្សក្នុងការវិវត្តរហូតក្លាយទៅជាទីផ្សារមូលបត្រដូចបច្ចុប្បន្ន។ ប៉ុន្តែប្រទេសជាច្រើននៅតែពេញនិយមក្នុងការប្រើប្រាស់ពាក្យ "ទីផ្សារភាគហ៊ុន" ជាជាង "ទីផ្សារមូលបត្រ" ដដែល។

ទីផ្សារភាគហ៊ុនកើតឡើងដំបូងប្រហែលជានៅពេលដែលភាគហ៊ុនរបស់ The Dutch East India Company ត្រូវបានគេជួញដូរនៅលើទីផ្សារ អាំស្ទែដាំ (Amsterdam Market)។ ក្រុមហ៊ុន The Dutch East India Company បង្កើតនៅឆ្នាំ១៦០២ ហើយវាជាក្រុមហ៊ុនដំបូងគេដែលបោះផ្សាយលក់ភាគហ៊ុនដើម្បីប្រមូលទុនសម្រាប់ការវិនិយោគរបស់ខ្លួន។ ភាគរយនៃផលចំណេញរបស់ក្រុមហ៊ុនត្រូវបានផ្តល់ជូនដល់អ្នកទិញ ដោយអាស្រ័យទៅនឹងភាគហ៊ុនដែលមាន។ ភាគហ៊ុននេះត្រូវបានគេជួញដូរជាបន្តបន្ទាប់រហូតលេចចេញការជួញដូរនៅលើក្រុមហ៊ុនផ្សារអាំស្ទែដាំ (Amsterdam Exchange)។ ហើយក្រោយមក

[1] http://siborann.blogspot.com/2011/09/blog-post_09.html?m=1

ឧបករណ៍ហិរញ្ញវត្ថុសំបូរបែបផ្សេងៗដែលត្រូវបានធ្វើការទិញ-លក់នៅលើទីផ្សារអាំស្ទែដាំ (Amsterdam Market) នេះ។

ក្រុមហ៊ុនផ្សារភាគហ៊ុន (Stock Exchange) នៅក្នុងទីក្រុងញូយ៉កត្រូវបាន បង្កើតឡើងក្នុងឆ្នាំ ១៧៩២ នៅពេលដែលឈ្មួញជើងសា (Brokers) ចំនួន២៤នាក់ បានសម្រេចចិត្តយកកម្រៃជើងសានៅពេលដែលពួកគេដើរតួជាភ្នាក់ងារសម្រាប់មនុស្សផ្សេងៗទៀតក្នុងការធ្វើជំនួញ។ ពួកគេបានធ្វើការជួញដូរជាច្រើននៅក្រោមដើមឈើមួយនៅ វ៉លស្ទ្រីត (Wall Street) ជាប្រចាំទើបបង្កើតឲ្យមានទីផ្សារមួយឈ្មោះថា វ៉លស្ទ្រីត មកដល់បច្ចុប្បន្ននេះនៅសហរដ្ឋអាមេរិក។

ឧបករណ៍ហិរញ្ញវត្ថុរបស់រដ្ឋាភិបាល បានបង្កើតនូវមូលដ្ឋានគ្រឹះនៃការធ្វើការជួញដូរជាលើកដំបូង ហើយភាគហ៊ុនរបស់ធនាគារ និងក្រុមហ៊ុនធានារ៉ាប់រងបានបន្ថែមលើបរិមាណនៃប្រតិបត្តិការនៃការជួញដូរបន្ថែមទៀត។ ក្នុងឆ្នាំ១៨១៧ ឈ្មួញជើងសា នៅក្នុងទីក្រុងញូយ៉ក បានសម្រេចចិត្តចាត់ចែងជាផ្លូវការនូវក្រុមប្រឹក្សាសម្រាប់ទីផ្សារភាគហ៊ុន បន្ទាប់មកទីផ្សារភាគហ៊ុនបានរីកចម្រើនជាមួយនឹងឧស្សាហូបនីយកម្មរបស់អាមេរិកដែរ។ នៅឆ្នាំ១៨៦៣ ក្រុមហ៊ុនផ្សារភាគហ៊ុននៅទីក្រុងញូយ៉កបានអនុម័តនូវឈ្មោះបច្ចុប្បន្នរបស់ខ្លួនគឺក្រុមហ៊ុនផ្សារភាគហ៊ុនញូយ៉ក (New York Stock Exchange)។ក្នុងពេលនៃសង្គ្រាមស៊ីវិល ក្រុមហ៊ុនផ្សារភាគហ៊ុនមួយចំនួនបន្ថែមទៀត ត្រូវបានបង្កើតឡើងហើយក្រុមហ៊ុនផ្សារភាគហ៊ុនមួយក្នុងចំណោមផ្សារភាគហ៊ុនទាំងនោះដែលត្រូវបានចាត់ទុកជាអ្នកនាំមុខគេគឺ ក្រុមហ៊ុនផ្សារភាគហ៊ុនអាមេរិក (American Stock Exchange) ជាក្រុមហ៊ុនផ្សារភាគហ៊ុនធំទី២នៅសហរដ្ឋអាមេរិកនាពេលបច្ចុប្បន្ននេះ។

ទីផ្សារភាគហ៊ុនមានការវិវត្តខ្លាំងក្រោយសង្គ្រាមលោកលើកទី២។ សង្គ្រាមលោកលើកទី២ បានជះឥទ្ធិពលអវិជ្ជមានជាច្រើនដល់ការវិវត្តរបស់ទីផ្សារនេះ។ រដ្ឋាភិបាលនៃប្រទេសមួយចំនួនមានការចាប់អារម្មណ៍ខ្លាំងក្នុងកាប្រើប្រាស់ទីផ្សារភាគហ៊ុន ព្រោះការវិវត្តខាងផ្នែកនយោបាយក្រោយសង្គ្រាមបានធ្វើឲ្យរដ្ឋាភិបាលខិតខំស្វែងរកនូវប្រភពទុនថ្មីៗសម្រាប់ទ្រទ្រង់ការចំណាយចរន្ត និងចំណាយមូលធនរបស់ខ្លួន ហើយទីផ្សារភាគហ៊ុនជាជម្រើសប្រភពហិរញ្ញប្បទានដ៏ល្អមួយ។ ម្យ៉ាងទៀតដើម្បីធ្វើឲ្យសាច់ប្រាក់មានចលនាវិលឡើងចុះកាន់តែខ្លាំងនៅក្នុងចរន្តសេដ្ឋកិច្ច ក៏ដូចជាធ្វើឲ្យសកម្មភាពនៃជំនួញកាន់តែមានភាពរស់រវើកថែមទៀត ក្នុងទិសដៅលើកកម្ពស់កំណើនសេដ្ឋកិច្ចដែលទើបងើបផុតពីសង្គ្រាម។ ទីផ្សារភាគហ៊ុនក៏ជាគោលនយោបាយដ៏ល្អមួយសម្រាប់រដ្ឋាភិបាលផងដែរ។ ធនាគារក្រុមហ៊ុនធានារ៉ាប់រង និងសហគ្រាសរួមទុនមួយចំនួនទៀត ជាពិសេសក្រុមហ៊ុនពាណិជ្ជកម្មធំៗ ក៏ខ្វះប្រភពទុនថ្មីៗដែរសម្រាប់យកមកទ្រទ្រង់ការចំណាយ និងពង្រីកនូវមុខជំនួញរបស់គេជាហេតុធ្វើឲ្យទីផ្សារភាគហ៊ុនជាជម្រើសប្រភពហិរញ្ញប្ប

ទានដ៏ល្អមួយដល់ពួកគេបន្ថែមលើប្រភពហិរញ្ញប្បទានផ្ទាល់ខ្លួន និងប្រភពហិរញ្ញប្បទានដោយប្រយោល តាមរយៈ ធនាគារ។ ភាពរួមគ្នានៃតម្រូវការទាំងនេះ ទីផ្សារភាគហ៊ុនកាន់តែច្រើនត្រូវបានគេបង្កើតដើម្បីធ្វើសញ្ញ័យលើធនធាន និងកៀរគរនូវធនធានហិរញ្ញវត្ថុពីប្រភពផ្សេងៗ។ ការដែលធ្វើសញ្ញ័យលើធនធាន និងកៀរគរនូវធនធានហិរញ្ញវត្ថុពីប្រភពផ្សេងៗទាំងនេះធ្វើឡើងតាមរយៈ ការបោះផ្សាយលក់ឧបករណ៍ហិរញ្ញវត្ថុដោយផ្តល់ផលប្រយោជន៍ហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុដល់អ្នកលក់ អ្នកទិញ និងអ្នកទិញហើយលក់វិញផងដែរ។ ឧបករណ៍ហិរញ្ញវត្ថុទាំងនោះ ត្រូវបានគេជួញដូរនៅលើទីផ្សារភាគហ៊ុនជាបន្តបន្ទាប់។ តាំងពីពេលនោះមកគេឃើញមានប្រទេសជាច្រើនផ្សេងៗទៀត បានមើលឃើញពីអត្ថប្រយោជន៍នៃទីផ្សារភាគហ៊ុននៅបណ្តាប្រទេសទាំងនោះ ហើយចាប់ផ្តើមខិតខំបង្កើតជាទីផ្សារនេះឡើងផងដែរ។

ទីផ្សារភាគហ៊ុនបានអភិវឌ្ឍន៍យ៉ាងលឿនដែលមានឧបករណ៍ហិរញ្ញវត្ថុជាច្រើនមានដូចជាៈ

មូលបត្របំណុល ឬ សញ្ញាប័ណ្ណ ឧបករណ៍ដេរីវេទីវ ឬឧបករណ៍និស្សន្ទត្រូវបានគេទិញ-លក់នៅលើទីផ្សារនេះផងដែរពុំមែនមានតែ ភាគហ៊ុនប៉ុណ្ណោះទេ។ ហេតុដូចនេះអ្នកវិនិយោគសាធារណៈងាយនឹងយល់ច្រឡំអំពីទីផ្សារនេះណាស់នៅពេលប្រើប្រាស់ពាក្យទីផ្សារភាគហ៊ុន ព្រោះពួកគេអាចយល់ថាភាគហ៊ុនជាឧបករណ៍តែមួយគត់ដែលត្រូវបានគេទិញ-លក់នៅលើទីផ្សារនេះ។ ក្រោយមកឧបករណ៍ទាំងអស់ដែលគេចង់ទិញ ឬលក់ត្រូវបានគេហៅថាមូលបត្រ (Securities) ជំនួសវិញហើយទីផ្សារដែលជាកន្លែងទិញ-លក់មូលបត្រនេះជាទីផ្សារមូលបត្រ។

បច្ចុប្បន្នទីផ្សារមូលបត្រមាននៅប្រទេសអភិវឌ្ឍន៍ស្ទើរតែទាំងអស់ និងមាននៅប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួន ហើយប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនផ្សេងៗទៀតក៏កំពុងតែខិតខំបង្កើតទីផ្សារនេះឡើងដែរ។ ទីផ្សារមូលបត្រដែលធំៗជាងគេមាននៅក្នុងសហរដ្ឋអាមេរិច ចក្រភពអង់គ្លេស ជប៉ុន ឥណ្ឌា ចិន កាណាដា អាឡឺម៉ង់ បារាំង កូរ៉េខាងត្បូង និងហុឡង់។

## ១.២. ប្រភេទនៃមូលបត្រ

តាមរយៈបទដ្ឋានគតិយុត្តនៅកម្ពុជា មូលបត្រត្រូវបានបែងចែកចេញជាពីរ គឺមូលបត្ររដ្ឋ និងមូលបត្រមហាជន។ បច្ចុប្បន្ននេះមូលបត្ររដ្ឋមិនទាន់បានដាក់ឲ្យដំណើរការនៅឡើយទេចំណែកមូលបត្រមហាជនគឺស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់គណៈកម្មការមូលបត្រកម្ពុជារួមមានៈ

### ១.២.១. មូលបត្រកម្មសិទ្ធ

មូលបត្រកម្មសិទ្ធ (ភាគហ៊ុន) សំដៅដល់ផលប្រយោជន៍ ឬសិទ្ធិស្របច្បាប់លើមូលបត្រនៃក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលរួមទាំងនីតិបរទេសរាប់បញ្ចូលទាំងភាគហ៊ុនដែលមាន

សិទ្ធបោះឆ្នោត និងគ្មានសិទ្ធបោះឆ្នោត និងភាគហ៊ុនមិនបង់ថ្លៃគ្រប់ និងភាគហ៊ុនបរិមា។

វិនិយោគិនមូលបត្រកម្មសិទ្ធ (ភាគហ៊ុន) អាចទទួលអត្ថប្រយោជន៍ប្រសិនបើក្រុមហ៊ុន មានដំណើរការល្អហើយតម្លៃរបស់ភាគហ៊ុនកើនឡើង។ ផ្ទុយទៅវិញវិនិយោគិនអាចខាតបង់នៅពេលដែលក្រុមហ៊ុនជួបការលំបាកហើយភាគហ៊ុនអាចនឹងធ្លាក់ថ្លៃ ក្នុងករណីអាក្រក់បំផុតក្រុមហ៊ុនអាចនិងក្ស័យធន។ ឧទាហរណ៍៖ ក្រុមហ៊ុនមួយបានចាប់ដំណើរការ និងទទួលបានភាពជោគជ័យហើយម្ចាស់ក្រុមហ៊ុនមានបំណងចង់ពង្រីកអាជីវកម្មរបស់ខ្លួន ក៏ប៉ុន្តែមិនទាន់មានដើមទុនគ្រប់គ្រាន់ ដូចច្នេះម្ចាស់ក្រុមហ៊ុននោះគឺអាចស្វែងរកដើមទុនបន្ថែមតាមរយៈទីផ្សារមូលបត្រ ដោយលក់ចំណែកកម្មសិទ្ធរបស់ក្រុមហ៊ុននៅក្នុងទីផ្សារដំបូង។ ចំណែកឯវិនិយោគិនដែលបានទិញភាគហ៊ុននោះគឺមានន័យថា ពួកគេបានក្លាយជាម្ចាស់កម្មសិទ្ធនៅក្នុងក្រុមហ៊ុននោះតាមចំណែកភាគហ៊ុនដែលគេបានកាន់កាប់។

### ១.២.២. មូលបត្របំណុល

មូលបត្របំណុល សំដៅដល់ឧបករណ៍ហិរញ្ញវត្ថុដែលបោះផ្សាយដោយបុគ្គលណាមួយដោយបញ្ជាក់ ឬទទួលស្គាល់នូវបំណុលរបស់ខ្លួនចំពោះបុគ្គលមួយទៀតដែលបានឲ្យប្រាក់ខ្ចី ឬដាក់ប្រាក់បញ្ញើរជាមួយបុគ្គលនោះ ហើយទោះបីជាមាន ឬគ្មានទ្រព្យដាក់ធានាក្តី។

ផ្សារមូលបត្រកម្ពុជា បានរៀបរាប់ថា មូលបត្របំណុល ឬ សញ្ញាបណ្ណ គឺជាកិច្ចសន្យាខ្ចីប្រាក់រវាងបុគ្គលបោះផ្សាយមូលបត្របំណុល និងវិនិយោគិន។ បុគ្គលដែលបោះផ្សាយសញ្ញាបណ្ណត្រូវបង់ជាការប្រាក់ ឲ្យទៅវិនិយោគិនតាមពេលវេលាជាក់លាក់និងទៀងទាត់ ព្រមទាំងត្រូវសងថ្លៃដើមដែលបានខ្ចីពីវិនិយោគិនតាមកាលកំណត់ដែលត្រូវសង។សញ្ញាបណ្ណរួមមាន សញ្ញាបណ្ណសាជីវកម្ម និងសញ្ញាបណ្ណសហគ្រាសរដ្ឋ ឬ រាជរដ្ឋាភិបាល។

មូលបត្របំណុលគឺ មានហានិភ័យទាបហើយពេញនិយមសម្រាប់វិនិយោគិនដែលត្រូវការចំណូលថេរ ព្រោះវិនិយោគិននឹងទទួលបានការបង់គូប៉ុងជាទៀងទាត់ហើយទទួលបានប្រាក់ដើមវិញនៅពេលដល់ការកំណត់។ ឧទាហរណ៍៖ មូលបត្របំណុលមួយមានតម្លៃ$១,០០០ ហើយមានអត្រាគូប៉ុង(ការប្រាក់) ៤% ក្នុងមួយឆ្នាំ។ដូច្នេះក្រុមហ៊ុននឹងត្រូវចំណាយប្រាក់$២០ សម្រាប់វិនិយោគិនពីរដងក្នុងមួយឆ្នាំ ($៤០ ជារៀងរាល់ឆ្នាំ) រហូតដល់កាលកំណត់សងប្រាក់ដើមជូនវិនិយោគិនវិញ។

### ១.២.៣. ឧបករណ៍និស្សន្ទ

ការជួញដូរឧបករណ៍និស្សន្ទ ឬដេរីវេទីវ សំដៅទៅដល់កិច្ចសន្យាលើតម្លាតថ្លៃនៃឧបករណ៍ហិរញ្ញវត្ថុដើម ដែលចេញពីមូលបត្រកម្មសិទ្ធ មូលបត្របំណុល សន្ទស្សន៍ លោហៈធាតុមានតម្លៃ ប្រេងឆៅ ឧស្ម័ន

ធម្មជាតិ កសិផល រូបិយបណ្ណ រួមទាំងគម្រោងការពារថ្លៃដើមជាដើម ដែលត្រូវបានជួញដូរក្នុងទីផ្សារ។ ឧបករណ៍និស្សន្ទទាំងនេះគឺជា ឧបករណ៍ហិរញ្ញវត្ថុដែលជាប្រភេទមួយនៃមូលបត្រ។

## ១.៣. ប្រភេទនៃទីផ្សារមូលបត្រ

ទីផ្សារមូលបត្រមានច្រើនប្រភេទ គេអាចធ្វើចំណាត់ថ្នាក់ទីផ្សារមូលបត្របានច្រើនប្រភេទដោយយោងទៅតាមឥណប្រតិទាន (ទីផ្សារមូលធនសម្រាប់មូលបត្ររយៈពេលវែង និងទីផ្សាររូបិយវត្ថុសម្រាប់មូលបត្ររយៈពេលខ្លី) យោងតាមប្រភេទនៃមូលបត្រ (ទីផ្សារមូលបត្រកម្មសិទ្ធិ ទីផ្សារមូលបត្របំណុល និងទីផ្សារឧបករណ៍ដេរីវេទីវ) យោងតាមចរិកលក្ខណៈគតិយុត្តនៃទីផ្សារ (ទីផ្សារប្រតិស្រុត និងទីផ្សាររំលងបញ្ជា) និងយោងតាមប្រភេនៃទីផ្សារ (ទីផ្សារដំបូង និងទីផ្សារបន្ទាប់) ។ ទីផ្សារមូលបត្រដែលគ្រោងនឹងដាក់ឲ្យដំណើរការដំបូងនៅកម្ពុជានាពេលខាងមុខ បើកំណត់តាមចរិកលក្ខណៈគតិយុត្តនៃទីផ្សារ វាជាទីផ្សារប្រតិស្រុត បើតំណត់តាមឥណប្រតិទាន វាជាទីផ្សារមូលធនបើកំណត់តាមប្រភេទនៃមូលបត្រ វាជាទីផ្សារមូលបត្រកម្មសិទ្ធនិងបើកំណត់តាមប្រភេទនៃទីផ្សារ វាជាទីផ្សារដំបូង និងទីផ្សារបន្ទាប់ផងដែរ ។

### ១.៣.១. ទីផ្សារដំបូង

ការដាក់លក់មូលបត្រជាលើកដំបូងដោយក្រុមហ៊ុនបោះផ្សាយទៅឲ្យវិនិយោគិន ត្រូវបានហៅថាជាការលក់ចែកចាយលើកដំបូង។ ទីផ្សារដំបូងជាទីកន្លែងដែលដាក់លក់មូលបត្រជាលើកទីមួយទៅឲ្យសាធារណៈជន ហើយអ្នកទិញបានទិញមូលបត្រដោយផ្ទាល់ពីក្រុមហ៊ុនបោះផ្សាយដែលអាចជាក្រុមហ៊ុនសារជីកម្ម(Corporation) ឬអង្គភាពរដ្ឋាភិបាល (Government Entity) មួយដែលបានបោះផ្សាយលក់មូលបត្រ។ សាច់ប្រាក់សម្រាប់ទូទាត់មូលត្រត្រូវបង់ទៅក្រុមហ៊ុនបោះផ្សាយ ហើយអ្នកទិញភាគហ៊ុនទាំងនេះក្លាយជាអ្នកកាន់កាប់ (ម្ចាស់) ភាគហ៊ុនដំបូងគេ។ ភាគហ៊ុននិកដំបូងគេអាចកាន់កាប់ភាគហ៊ុនទាំងនេះ ឬលក់ភាគហ៊ុនទាំងអស់នេះទៅឲ្យអ្នកផ្សេងទៀត។ ដំណើរការលក់ភាគហ៊ុនជាលើកដំបូងត្រូវគេស្គាល់ថាជា "ការនាំក្រុមហ៊ុនទៅកាន់សាធារណៈ" (Taking The Company Public)។ នេះមានន័យថាក្រុមហ៊ុនលែងកាន់កាប់ដោយវិនិយោគិនដំបូង ឬស្ថាបនិក (Founder) ទៀតហើយ។ ក្រុមហ៊ុនដែលលក់មូលបត្ររបស់ខ្លួនទៅឲ្យសាធារណៈជនត្រូវបានគេសន្មតថា "សំណើរការលក់មូលបត្រជាសាធារណៈ" (Going Public)។ នៅក្នុងប្រទេសមួយចំនួនដែលធ្លាប់ជាអតីតរដ្ឋរបស់សហភាពសូវៀត និងប្រទេសកុម្មុយនីសមួយចំនួនគេប្រើពាក្យ "Taking The Company Private" ជំនួសពាក្យ "Taking The Company Public" ។ ចំពោះដំណើរការលក់ភាគហ៊ុនជាលើកដំបូងរបស់ក្រុមហ៊ុនមួយត្រូវបានគេហៅថា "សំណើរបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង (Initial Public Offering) "IPO"។

### ១.៣.២. ទីផ្សារបន្ទាប់

ដោយសារវិនិយោគិនមួយចំនួនយល់ថា ការប្រើប្រាស់មូលធន ( Tie up Funds) របស់ពួកគេមិនមានការកំណត់ជាក់លាក់ ដូចនេះហើយភាគច្រើននៃមូលបត្រអាចចរចារទិញលក់បាន។ នេះមានន័យថា ភាគហ៊ុនអាចផ្លាស់ប្តូរបានដោយសេរីពីអ្នកលក់ម្នាក់ទៅអ្នកទិញម្នាក់ទៀតដោយ តម្លៃកំណត់មួយដែលមានការព្រមព្រៀង និងពេញចិត្តដោយភាគីទាំងពីតាមរយៈការផ្តល់ភាគហ៊ុនឲ្យទៅអ្នកទិញ។ ប័ណ្ណកម្មសិទ្ធស្របច្បាប់របស់ភាគហ៊ុន នឹងត្រូវបានផ្ទេរឲ្យទៅអ្នកទិញនៅពេលដែលភាគហ៊ុនផ្តល់មកឲ្យភាគីអ្នកទិញ។ ការកំណត់តម្លៃ និងការផ្តល់កម្មសិទ្ធលើមូលបត្រកើតឡើងនៅកន្លែងមួយដែលគេស្គាល់ថាជាទីផ្សារបន្ទាប់ (Secondary Market)។ ទីផ្សារបន្ទាប់គឺជាកន្លែងដែលការជួញដូរមូលបត្របានកើតឡើងជាប្រចាំរវាងអ្នកលក់ និងអ្នកទិញមូលបត្រ។ ទឹកប្រាក់ដែលកើតចេញពីសម្មភាពជួញដូរនេះត្រូវបង់ឲ្យទៅភាគហ៊ុនិកដែលលក់ មិនមែនឲ្យទៅក្រុមហ៊ុនបោះផ្សាយលើកដំបូងទេ។ ក្រុមហ៊ុនបោះផ្សាយមូលបត្រមិនទទួលបានផលចំណេញជាហិរញ្ញវត្ថុពីការជួញដូរមូលបត្រកើតឡើងលើទីផ្សារបន្ទាប់ទេ ហើយមូលបត្រទាំងអស់ដែលត្រូវបានជួញដូរនៅក្នុងទីផ្សារបន្ទាប់អាចត្រូវបានជួញដូរនៅក្នុងទីផ្សារមូលបត្រ ឬនៅក្រៅទីផ្សារមូលបត្រដែលគេហៅថា ″Over-The-Counter″ (ទីផ្សាររំលងបញ្ជរ)។

វាជាមុខងារនៃទីផ្សារមូលបត្រ (Security Exchanges) និងទីផ្សាររំលងបញ្ជរ(Over-The-Counter) ក្នុងការផ្តល់ទីកន្លែងមួយក្នុងការកំណត់តម្លៃភាគហ៊ុន ព្រមទាំងផ្តល់មូលបត្រទៅឲ្យអ្នកទិញ។

### ១.៣.៣. ទីផ្សារមូលធន

ទីផ្សារមូលធន គឺជាទីផ្សារហិរញ្ញវត្ថុដែលអ្នកលក់ និងអ្នកទិញជួញដូរនូវភាគហ៊ុន បណ្ណបំណុលរូបិយបណ្ណអន្តរជាតិ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត ដែលមានឥណប្រតិទានរយៈពេលមួយឆ្នាំ ឬច្រើនជាងមួយឆ្នាំ។ ទីផ្សារមូលធននេះ ជាកន្លែងដែលជួយប្រមូលនូវមូលធនពីអ្នកមានមូលធន ទៅអ្នកដែលត្រូវការមូលធនក្នុងការវិនិយោគផ្សេងៗ។

### ១.៣.៤. ទីផ្សាររូបិយវត្ថុ

ទីផ្សាររូបិយវត្ថុ គឺជាទីផ្សារហិរញ្ញវត្ថុដែលជួញដូររយៈពេលខ្លីតិចជាងមួយឆ្នាំ ដែលមានដូចជាប័ណ្ណរតនាគារ ផលបត្រពាណិជ្ជកម្មជាដើម។ ទីផ្សាររូបិយបណ្ណបានក្លាយជាផ្នែកមួយរបស់ទីផ្សារហិរញ្ញវត្ថុសម្រាប់ទិញ និងលក់មូលបត្រដែលមានពេលខ្លីរយៈពេលមួយឆ្នាំឬតិចជាងដូចជាវិក័យបត្ររតនាគារជាតិ និងឯកសារពាណិជ្ជកម្ម។

## ១.៤. អត្ថប្រយោជន៍នៃទីផ្សារមូលបត្រ

### ១.៤.១. ចំពោះវិនិយោគិន

មានមតិមួយចំនួនលើកឡើងថា ការជួញដូរមូលបត្រប្រៀបបានទៅនឹងការលេងល្បែងស៊ីសង។ ប៉ុន្តែបើយើងវិភាគឲ្យច្បាស់លាស់ការវិនិយោគ និងការលេងល្បែងមានលក្ខណៈខុសគ្នាទាំងស្រុង។ ការលេងល្បែងពឹងលើព្រេងសំណាងគ្មានអ្វីមកបញ្ជាក់ថាឈ្នះនោះទេ ដោយឡែកការវិនិយោគនៅលើវិស័យមូលបត្រគឺ អាស្រ័យទៅលើការរកស៊ីរបស់ក្រុមហ៊ុនហើយមុនពេលជ្រើសរើសទិញមូលបត្ររបស់ក្រុមហ៊ុនណាមួយគឺគេបានមើលពីស្ថានភាពហិរញ្ញវត្ថុ និងសកម្មភាពរបស់ក្រុមហ៊ុនរួចហើយ។ វិនិយោគិនអាចទទួលបាននូវអត្ថប្រយោជន៍ជាច្រើនពីការជួញដូរមូលបត្រលើទីផ្សារមូលបត្រដូចជាៈ[2]

**ក. ទទួលបានភាគលាភ (ប្រាក់ចំណូលអកម្ម)៖** នៅពេលក្រុមហ៊ុនបោះផ្សាយទទួលបានជោគជ័យក្នុងវិនិយោគ ម្ចាស់កាន់កាប់មូលបត្រកម្មសិទ្ធិនឹងទទួលបាននូវចំណែកភាគលាភទៅតាមសមាមាត្រនៃសិទ្ធិដែលខ្លួនមាននៅក្នុងក្រុមហ៊ុន និងទទួលបានប្រាកក់ថេរទោះក្រុមហ៊ុនបោះផ្សាយទទួលបានផលចំណេញ ឬខាត់បង់ក៏ដោយចំពោះម្ចាស់ ឬអ្នកកាន់កាប់មូលបត្របំណុល។

**ខ. ប្រាក់ចំណេញពីការទិញ-លក់មូលបត្រ (ចំណេញមូលធន)៖** វិនិយោគិននឹងទទួលបានផលចំណេញផ្នែកមូលធននៅពេលដែលតម្លៃមូលបត្ររបស់ខ្លួនឡើងថ្លៃក្នុងទីផ្សារមូលបត្រ។ ម្យ៉ាងវិញទៀតការវិនិយោគជាមួយភាគហ៊ុនច្រើនក្រុមហ៊ុនផ្សេងៗគ្នានឹងជួយបង្កើនទ្រព្យសម្បត្តិរបស់វិនិយោគិនតាមរយៈឥទ្ធិពលកំណើនពីវិស័យផ្សេងៗក្នុងសេដ្ឋកិច្ចបើទោះបីជាថ្លៃភាគហ៊ុនខ្លះដែលវិនិយោគិនបានធ្លាក់ថ្លៃក៏ដោយ។

**គ. ការធ្វើពិពិធកម្មការវិនិយោគ** (Diversification) ៖ វិនិយោគិនតែងតែប្រើប្រាស់សាច់ប្រាក់សន្សំច្បាស់លាស់ ដោយតែងតែលៃបម្រុងទុកពី ១៥% ទៅ២០% ដើម្បីវិនិយោគលើទីផ្សារមូលបត្រធៀបនឹងការវិនិយោគសរុប។ សម្រាប់វិនិយោគិនដែលដាក់ប្រាក់វិនិយោគច្រើនប្រភេទផ្សេងៗគ្នាការវិនិយោគក្នុងទីផ្សារមូលបត្រផ្តល់នូវអត្ថប្រយោជន៍សំខាន់មួយគឺពិពិធកម្ម។ ការវិនិយោគក្នុងទីផ្សារមូលបត្រ ថ្លៃប្រែប្រួលដោយមិនជាប់ទាក់ទងជាមួយការវិនិយោគផ្សេងៗទៀត ដូចជាអចលនទ្រព្យនោះទេ។ ការវិនិយោគក្នុងទីផ្សារមូលបត្រអាចជួយកាត់បន្ថយការខាតបង់បានខ្លះ ក្នុងករណីវិនិយោគិនមានការខាតបង់ជាមួយការវិនិយោគផ្សេងទៀត។

[2] គណៈកម្មការមូលបត្រកម្ពុជា, www.secc.gov.kh

**ឃ. ភាពជាម្ចាស់កម្មសិទ្ធិ៖** ការទិញភាគហ៊ុនមានន័យថា លោកអ្នកទទួលយកចំណែកនៃភាពជាម្ចាស់កម្មសិទ្ធិពីក្រុមហ៊ុន ហើយលោកអ្នកក៏មានសិទ្ធិទទួលបាននូវចំណែកនៃប្រាក់ចំណេញដែលក្រុនហ៊ុនទទួលបានផងដែរ។ ភាគហ៊ុនិកមានសិទ្ធិបោះឆ្នោត និងមានសិទ្ធិចូលរួមប្រជុំសម្រេចចិត្តក្នុងអាជីវកម្មរបស់ក្រុមហ៊ុនតាមសមាមាត្រនៃភាគហ៊ុនដែលខ្លួនកាន់កាប់។

**១.៤.២. ចំពោះក្រុមហ៊ុន**

**ក. ទទួលបានប្រភពហិរញ្ញប្បទានរយៈពេលវែង៖** ការចុះបញ្ជីលក់មូលបត្រជាសាធារណៈផ្តល់លទ្ធភាពឲ្យក្រុមហ៊ុនបោះផ្សាយលក់មូលបត្រទទួលបាននូវប្រភពហិរញ្ញប្បទានថ្មីមួយ ដែលអនុញ្ញាតឲ្យក្រុមហ៊ុននេះ អាចប្រមូលបានមូលធនពីអ្នកវិនិយោគសាធារណៈសម្រាប់ពង្រីកការវិនិយោគ។ បន្ថែមពីនេះទៀត នៅពេលដែលក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ និងចុះបញ្ជីលក់មូលបត្រ ក្រុមហ៊ុននឹងទទួលបាននូវកេរ្តិ៍ឈ្មោះល្អ និងគាំទ្រពីច្បាប់ដែលក្រុមហ៊ុនអាចពង្រឹងអំណាចក្នុងការចរចារជាមួយធនាគារពីលទ្ធភាពក្នុងការទទួលបានឥណទាន រួមចំណែកក្នុងការអនុវត្តផែនការអាជីវៈកម្មរយៈពេលវែងរបស់ក្រុមហ៊ុនផងដែរ។

**ខ. ទទួលបានការលើកទឹកចិត្តពន្ធ៖** ក្រុមហ៊ុនទាំងអស់ដែលទទួលបានការអនុញ្ញាតពី **គ.ម.ក.** បោះផ្សាយលក់មូលបត្រជាសាធារណៈ និងចុះបញ្ជីលក់នៅ **ផ.ម.ក.** នឹងត្រូវបានលើកទឹកចិត្តផ្នែកពន្ធដារដោយបន្ថយពន្ធលើប្រាក់ចំណេញចំនួន ៥០% ក្នុងរយៈពេលបីឆ្នាំដំបូង ហើយការលើកទឹកចិត្តនេះ នឹងត្រូវផ្តល់ជូនចំពោះការចុះបញ្ជីមុនខែ មករា ឆ្នាំ២០២១។ ស្របពេលជាមួយគ្នានេះផងដែរ ក្រុមហ៊ុនក៏ទទួលបានការលើកលែងទាំងស្រុង ចំពោះបំណុលពន្ធលើប្រាក់ចំណេញ សម្រាប់រយៈពេល១០ឆ្នាំ សារពើពន្ធកន្លងទៅដែលបានរកឃើញដោយការសវនកម្មឯករាជ្យ ក្រោយការធ្វើសវនកម្មពេញលេញរបស់អគ្គនាយកដ្ឋានពន្ធដារ បន្ថែមលើនេះទៀតប្រាក់រំដោះពន្ធលើប្រាក់ចំណេញ១% ប្រចាំខែត្រូវបានព្យួរជាបណ្តោះអាសន្នរយៈពេល៣ឆ្នាំ។

**គ. ទទួលបាននិរន្តភាពអាជីវកម្មជាមួយនឹងអភិបាលកិច្ចសាជីវកម្ម និងការគ្រប់គ្រងផ្ទៃក្នុងដែលរឹងមាំជាងមុន៖** នៅពេលដែលក្រុមហ៊ុនបានក្លាយទៅជាក្រុមហ៊ុនចុះបញ្ជី ពួកគេនឹងអាចធ្វើឲ្យប្រសើរឡើងនូវអភិបាលកិច្ចសាជីវកម្ម តាមរយៈការរៀបចំឲ្យមានរចនាសម្ព័ន្ធក្រុមប្រឹក្សាភិបាល ដែលនឹងមានតួនាទីពិនិត្យលើការបំពេញមុខងាររបស់ថ្នាក់ដឹកនាំរបស់ក្រុមហ៊ុន។ បន្ថែមលើនេះទៀតម្ចាស់អាជីវកម្មអាចពង្រឹងយន្តការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុន ដែលអាចកាត់បន្ថយការអនុវត្តការងារមិនត្រូវ ឬការកេងបន្លំផ្សេងៗក្នុងដំណើរការអាជីវកម្មប្រចាំថ្ងៃ។ ជាលទ្ធផលអភិបាលកិច្ចអាជីវកម្ម និងការគ្រប់គ្រងផ្ទៃក្នុងនឹងជួយដល់

សហគ្រាសខ្នាតតូច និងមធ្យមឲ្យមានការរីកចម្រើនប្រកបដោយនិរន្តភាព។ ការទទួលយកការអនុវត្តអភិបាលកិច្ចសាជីវកម្ម នឹងជួយដល់ការត្រៀមខ្លួនរបស់សហគ្រាសខ្នាតតូច និងមធ្យមក្នុងការប្រកួតប្រជែងជាមួយគូប្រកួតប្រជែងក្នុងតំបន់អាស៊ាន។

**ឃ. ការធ្វើឲ្យប្រសើរឡើងនូវកេរ្តិ៍ឈ្មោះ និងសក្តានុពលរបស់ក្រុមហ៊ុន៖** ក្រុមហ៊ុនចុះបញ្ជីមួយជាទូទៅទាក់ទាញចំណាប់អារម្មណ៍របស់វិនិយោគិនទាំងក្នុងនិងក្រៅប្រទេស តាមរយៈប្រព័ន្ធព័ត៌មានវិទ្យា និងសាធារណៈជន រីឯប្រតិបត្តិការអាជីវកម្ម ឬប្រតិបត្តិការហិរញ្ញវត្ថុ តែងត្រូវបានផ្សព្វផ្សាយតាមរយៈកាសែត ទូរទស្សន៍ និងគេហទំព័រផ្សេងៗ ព្រមទាំងត្រូវបានលើកឡើងទាំងក្នុង និងក្រៅប្រទេសផងដែរ។ ប្រការនេះអាចជួយកែលម្អនូវរូបភាព និងកេរ្តិ៍ឈ្មោះរបស់ក្រុមហ៊ុនក៏អាចឲ្យសាធាណៈជនស្គាល់កាន់តែច្រើនអំពីផលិតផល និងសេវាកម្មរបស់ក្រុមហ៊ុន។ តាមរយៈនេះក្រុមហ៊ុនក៏អាចពង្រឹងនូវឧត្តមានុភាពការប្រកួតប្រជែងរបស់ខ្លួនចំពោះដៃគូប្រកួតប្រជែងដែលមិនមែនជា ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រនៅក្នុងបរិបទនៃសេដ្ឋកិច្ចសកលភាវូបនីយកម្មដែលពោរពេញដោយការប្រកួតប្រជែងនេះ។

**១.៤.៣. ចំពោះសេដ្ឋកិច្ចជាតិ**

ទីផ្សារមូលបត្រ ដើរតួនាទីយ៉ាងសំខាន់ក្នុងសេដ្ឋកិច្ចរបស់ប្រទេសមួយដោយ វាអនុញ្ញាតឲ្យក្រុមហ៊ុនសាជីវកម្ម សហគ្រាសសាធារណៈ និងរាជរដ្ឋាភិបាល អាចប្រមូលទុនដោយផ្ទាល់ពីសាធារណជនមកប្រើប្រាស់ដើម្បីពង្រីកអាជីវកម្ម ឬអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជាដើម។ ម្យ៉ាងវិញទៀតអ្នកដែលមានប្រាក់សល់ពីការចំណាយ មានជម្រើសក្នុងការធ្វើពិពិធកម្មសំណុំវិនិយោគរបស់ខ្លួន ឬធ្វើការសន្សំ (ជាមួយមូលបត្រដែលមានហានិភ័យទាប) នៅក្នុងទីផ្សារមូលបត្រ។ នៅពេលដែលសាច់ប្រាក់ហូរពីអ្នកមាន ឬអ្នកដែលមានសាច់ប្រាក់លើសតម្រូវការទៅអ្នកដែលត្រូវការប្រកបដោយប្រសិទ្ធិភាព ហើយពេលនោះសកម្មភាពសេដ្ឋកិច្ចដូចជា ផលិតកម្ម និងពាណិជ្ជកម្មនឹងរីកលូតលាស់ទៅតាមនោះដែរ ព្រមទាំងបង្កើតឲ្យមានឱកាសការងារតាមរយៈការវិនិយោគបន្ថែម និងបង្កើនទ្រព្យសម្បត្តិសម្រាប់ប្រជាជនទូទៅ។ បន្ថែមពីនេះទៀតការកើនឡើងនៃទីផ្សារមូលបត្រកម្ពុជាអាចធ្វើឲ្យមានការទាក់ទាញវិនិយោគិនមកប្រទេសកម្ពុជាពីព្រោះថាក្រុមហ៊ុនបរទេសធំៗ ដែលមានបំណងមកវិនិយោគនៅកម្ពុជា អាចបោះផ្សាយលក់មូលបត្រ នៅទីផ្សារមូលបត្រកម្ពុជា និងវិនិយោគនៅកម្ពុជាតែម្តង។ នៅពេលមានទីផ្សារនេះអាចជួយជម្រុញឲ្យក្រុមហ៊ុនត្រូវប្រកាន់ភ្ជាប់នូវអភិបាលកិច្ចល្អ តម្លាភាពផ្តល់នូវទំនុកចិត្តដល់សាធារណជន ដែលករណីនេះបង្កើតបានការប្រកួតប្រជែងរវាងក្រុមហ៊ុនដែលមានអភិបាលកិច្ចល្អ មានតម្លាភាព និងក្រុមហ៊ុនដែលមិនមានអភិបាលកិច្ចល្អ និងគ្មានតម្លាភាព។ ដូច្នេះទីផ្សារមូលបត្រ មានសារៈសំខាន់សម្រាប់ជួយជម្រុញឲ្យ

ប្រភពមូលធនក្នុងស្រុកមានចលនារស់រវើក និងជាការពង្រីកនូវប្រភពហិរញ្ញវត្ថុសម្រាប់កំណើនសេដ្ឋកិច្ចដ៏រឹងមាំរបស់ប្រទេសកម្ពុជា។

❖ **គុណវិបត្តិរបស់ទីផ្សារមូលបត្រ**

ទីផ្សារមូលបត្រមានគុណវិបត្តិមួយចំនួន ដែលគេតែងតែជួបប្រទះនូវបញ្ហាដូចខាងក្រោម ៖

➢ ការឆក់ឱកាសកេងចំណេញក្នុងការជួញដូរ(Speculation) គឺជាការទិញ-លក់មួយ ដែលមានការគិតគូរយ៉ាងហ្មត់ចត់ ដើម្បីទទួលបានផលចំណេញដោយប្រឈមនឹងហានិភ័យ។ អ្នកឆក់ឱកាសកេងចំណេញក្នុងការជួញដូរនេះអាចធ្វើការជួញដូរភាគហ៊ុននាពេលបច្ចុប្បន្ន ដោយរំពឹងថានាពេលអនាគតនឹងទទួលបានប្រាក់ចំណេញទៅតាមការជួញដូរមួយលើកៗ។ ការឆក់ឱកាសកេងចំណេញក្នុងការជួញដូររបៀបនេះ វានឹងបង្កឲ្យមានឥទ្ធិពលដល់តម្លៃភាគហ៊ុន។ព្រឹត្តិការណ៍នេះធ្វើឲ្យមានភាពងាយស្រួលនៅពេលពួកគេព្រមព្រៀងគ្នាក្នុងការជួញដូរ ដែលនាំឲ្យស្ថានភាពនៅលើទីផ្សារមានពេលខ្លះធ្វើឲ្យភាគហ៊ុនខ្វះ ឬលើសហើយធ្វើឲ្យមានចលនាឡើងចុះតម្លៃនៃការជួញដូរមូលបត្រនៅលើទីផ្សារមូលបត្រ។

➢ ការជួញដូរផ្ទៃក្នុង គឺមានបុគ្គលជាបុគ្គលិករបស់ក្រុមហ៊ុនចុះបញ្ជីឆ្លៀតឱកាសយកព័ត៌មានផ្ទៃក្នុងរបស់ក្រុមហ៊ុន ដើម្បីធ្វើការជួញដូរភាគហ៊ុន ដើម្បីស្វែង រកចំណេញរបស់ខ្លួនដែលមានឥទ្ធិពលដល់តម្លៃភាគហ៊ុនរបស់ទីផ្សារមូលត្រ ដែលព័ត៌មាននោះមិនមែនព័ត៌មានសាធារណៈ(ព័ត៌មានសម្ងាត់)

➢ ការជួញដូរក្លែងក្លាយ និងការប្រើឧបាយកលក្នុងទីផ្សារគឺជាការធ្វើសកម្មភាពណាមួយ ឬ គេចវេះមិនធ្វើសកម្មភាពដែលបណ្តាលឲ្យ ឬអាចបណ្តាលឲ្យលក្ខណៈក្លែងបន្លំ ឬនាំឲ្យមានការយល់ខុសចំពោះការជួញដូរមូលបត្រ ឬធ្វើប្រតិបត្តិការធ្វើផែនការជួញដូរដែលមានលក្ខណៈសិប្បនិម្មិតទាក់ទិននឹងមូលបត្រនៅលើទីផ្សារមូលបត្រ។

➢ សេចក្តីថ្លែងការណ៍ ឬការផ្សព្វផ្សាយព័ត៌មានក្លែងបន្លំ ឬដែលនាំឲ្យមានការយល់ខុសធ្ងន់ធ្ងរ ដែលបណ្តាលឲ្យមានសារធារណជនទិញលក់មូលបត្រ ឬបណ្តាលឲ្យមានការកើនឡើង ឬការថយចុះ ឬ នៅថេរចំពោះតម្លៃនៃការជួញដូរនៅក្នុងទីផ្សារមូលបត្រ។

➢ ក្រុមហ៊ុនដែលបោះពុម្ពផ្សាយលក់មូលបត្រ តម្រូវឲ្យមានបញ្ជីគណនេយ្យច្បាស់លាស់ មានតម្លាភាព និងអភិបាលកិច្ចអាជីវកម្មល្អ ដែលទាំងនេះជាបន្ទុកមួយសម្រាប់ក្រុមហ៊ុន ប៉ុន្តែក្រុមហ៊ុនបានផ្លែផ្កាមកវិញនូវទុនរយៈពេលវែងក្នុងតម្លៃថោកសមរម្យសម្រាប់ពង្រីកអាជីវកម្មរបស់ខ្លួន។

# ១.៥.តួនាទីរបស់ហិរញ្ញវត្ថុ និងទីផ្សារហិរញ្ញវត្ថុក្នុងការអភិវឌ្ឍសេដ្ឋកិច្ច

## ១.៥.១. តួនាទីរបស់ហិរញ្ញវត្ថុក្នុងការអភិវឌ្ឍសេដ្ឋកិច្ច

មុខងារនៃសេដ្ឋកិច្ចពឹងផ្អែកលើប្រព័ន្ធហិរញ្ញវត្ថុរបស់ប្រទេស ដូចនេះប្រព័ន្ធហិរញ្ញវត្ថុរបស់ប្រទេសមួយត្រូវបានចាក់ឫសយ៉ាងជ្រៅនៅក្នុងសង្គម និងផ្តល់ការងារដល់ប្រជាជនមួយចំនួនធំ។ យោងតាម Baily និង Elliott មានមុខងារសំខាន់បីនៃប្រព័ន្ធហិរញ្ញវត្ថុ៖[3]

១. ការផ្តល់ឥណទាន៖ រដ្ឋាភិបាលអាចវិនិយោគលើគម្រោងហេដ្ឋារចនាសម្ព័ន្ធដោយកាត់បន្ថយវដ្តនៃប្រាក់ចំណូលពន្ធ។ ពួកគេអាចវិនិយោគទៅលើអាជីវកម្មច្រើនជាងសាច់ប្រាក់ដែលពួកគេមានហើយបុគ្គលម្នាក់ៗអាចទិញផ្ទះ និងឧបករណ៍ប្រើប្រាស់ផ្សេងៗដោយមិនចាំបាច់សន្សំប្រាក់ជាមុន។

២. ការផ្តល់សាច់ប្រាក់ងាយស្រួល៖ ធនាគារផ្តល់នូវកន្លែងដាក់ប្រាក់បញ្ញើដែលអាជីវកម្ម ឬបុគ្គលអាចដកបានគ្រប់ពេល។ ស្រដៀងគ្នានេះដែរពួកគេផ្តល់នូវឥណទាន និងកន្លែងរូបារូបសម្រាប់អាជីវកម្ម។ លើសពីនេះទៅទៀតធនាគារ និងស្ថាប័នហិរញ្ញវត្ថុផ្តល់ជូនដើម្បីទិញ ឬលក់មូលបត្រតាមតម្រូវការហើយជារឿយៗក្នុងបរិមាណច្រើនដើម្បីបំពេញនូវតម្រូវការសាច់ប្រាក់ភ្លាមៗរបស់អ្នកពាក់ព័ន្ធ។

៣. សេវាកម្មគ្រប់គ្រងហានិភ័យ៖ ហិរញ្ញវត្ថុផ្តល់នូវការគ្រប់គ្រងហានិភ័យ ពីហានិភ័យនៃទីផ្សារហិរញ្ញវត្ថុ និងតម្លៃទំនិញដោយប្រមូលផ្តុំហានិភ័យ។ ប្រតិបត្តិការដេរីវេអាចឲ្យធនាគារផ្តល់នូវការគ្រប់គ្រងហានិភ័យ។

➢ ទំនាក់ទំនងសន្សំ និងវិនិយោគ៖ ក្រៅពីមុខងារទាំងនេះកំណើនសេដ្ឋកិច្ចត្រូវបានជម្រុញដោយទំនាក់ទំនងវិនិយោគ និងសន្សំ។នៅពេលមានការសន្សំគ្រប់គ្រាន់មានតែពេលនោះទេដែលអាចមានការវិនិយោគ និងសកម្មភាពផលិតកម្មដែលមានទំហំ។ កន្លែងសន្សំនេះត្រូវបានផ្តល់ជូនដោយស្ថាប័នហិរញ្ញវត្ថុតាមរយៈគម្រោងការប្រាក់គួរឲ្យទាក់ទាញ។ ថវិកាដែលសន្សំដោយសាធារណៈជនត្រូវបានប្រើប្រាស់ដោយស្ថាប័នហិរញ្ញវត្ថុសម្រាប់ ផ្តល់ប្រាក់កម្ចីដល់អាជីវកម្មក្នុងអត្រាការប្រាក់ច្រើន។ មូលនិធិទាំងនេះអនុញ្ញាតឲ្យអាជីវកម្មបង្កើនសកម្មភាពផលិតកម្មនិងចែកចាយរបស់ពួកគេ។

➢ កំណើនទីផ្សារមូលធន៖ ជាមុខងារហិរញ្ញវត្ថុដ៏សំខាន់មួយដែលជួយជម្រុញកំណើនទីផ្សារមូលធន។ អាជីវកម្មត្រូវការដើមទុនពីរប្រភេទគឺ ថេរ និងធ្វើការ។ ដើមទុនថេរសំដៅទៅលើប្រាក់ដែលត្រូវការសម្រាប់វិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដូចជាអាគាររោងចក្រ និងគ្រឿងម៉ាស៊ីន។ ដើមទុនធ្វើការគឺសំដៅទៅលើ

[3] https://docplayer.net/20928200-The-role-of-financial-markets-in-economic-growth.html

ប្រាក់ដែលត្រូវការសម្រាប់ដំណើរការអាជីវកម្មប្រចាំថ្ងៃ។ នេះអាចសំដៅទៅលើការទិញវត្ថុធាតុដើមជាបន្ត បន្ទាប់ការចំណាយលើការបញ្ចប់ទំនិញ និងការដឹកជញ្ជូនទំនិញដែលបានបញ្ចប់ទៅហាង ឬអតិថិជន។

➢ ទីផ្សារប្តូរប្រាក់បរទេសៈ ដើម្បីគាំទ្រដល់ពាណិជ្ជករនាំចេញនិងនាំចូលមានទីផ្សារប្តូរប្រាក់បរទេស ដែលអាជីវកម្មអាចទទួលនិងផ្ទេរប្រាក់ទៅប្រទេសនិងរូបិយប័ណ្ណផ្សេងទៀត។ ទីផ្សារប្តូរប្រាក់បរទេសទាំង នេះក៏អាចឱ្យធនាគារនិងស្ថាប័នហិរញ្ញវត្ថុផ្សេងទៀតខ្ចីប្រាក់ ឬខ្ចីប្រាក់ជារូបិយប័ណ្ណផ្សេងៗផងដែរ។ ម៉្យាង វិញទៀតស្ថាប័នហិរញ្ញវត្ថុអាចវិនិយោគ និងប្រមូលយកប្រាក់ចំណេញពីប្រាក់ដែលទុកចោលក្នុងរយៈពេល ខ្លីដោយវិនិយោគក្នុងទីផ្សារប្តូរប្រាក់បរទេស។ រដ្ឋាភិបាលក៏បំពេញតាមតម្រូវការប្តូរប្រាក់បរទេសតាមរយៈ ទីផ្សារទាំងនេះផងដែរ។ ដូច្នេះហើយបានជាទីផ្សារប្តូរប្រាក់បរទេសជះឥទ្ធិពលដល់កំណើននៃសេដ្ឋកិច្ចនៅ ក្នុងទីផ្សារអន្តរជាតិ។

➢ មូលបត្ររបស់រដ្ឋាភិបាលៈ រដ្ឋាភិបាលប្រើប្រព័ន្ធហិរញ្ញវត្ថុដើម្បីរៃអង្គាសប្រាក់សម្រាប់តម្រូវការមូល និធិរយៈពេលខ្លី និងរយៈពេលវែង។ រដ្ឋាភិបាលចេញប័ណ្ណប្រាក់ និងវិក្កយបត្រក្នុងអត្រាការប្រាក់គួរឲ្យទាក់ ទាញហើយក៏ផ្តល់សម្បទានពន្ធផងដែរ។ គម្លាតថវិកាត្រូវបានយកចិត្តទុកដាក់ដោយមូលបត្ររបស់រដ្ឋាភិ បាល។ ដូច្នេះទីផ្សារមូលធនទីផ្សារប្តូរប្រាក់បរទេស និងទីផ្សារមូលបត្ររបស់រដ្ឋាភិបាលគឺចាំបាច់សម្រាប់ ជួយដល់សហគ្រាសឧស្សាហកម្ម និងរដ្ឋាភិបាលឲ្យអនុវត្តសកម្មភាពអភិវឌ្ឍន៍និងកំណើនសេដ្ឋកិច្ច។

➢ ហេដ្ឋារចនាសម្ព័ន្ធ និងកំណើនៈ កំណើនសេដ្ឋកិច្ចពឹងផ្អែកលើការរីកចម្រើននៃហេដ្ឋារចនាសម្ព័ន្ធ របស់ប្រទេស។ឧស្សាហកម្មសំខាន់ៗមានដូចជា ថាមពលធ្យូងថ្មប្រេងកំណត់ការរីកចម្រើននៃឧស្សាហកម្ម ដទៃទៀត។ ឧស្សាហកម្មហេដ្ឋារចនាសម្ព័ន្ធទាំងនេះបានផ្តល់មូលនិធិដោយប្រព័ន្ធហិរញ្ញវត្ថុរបស់ប្រទេស។ ដូច្នេះហិរញ្ញវត្ថុដើរតួនាទីយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចហើយគ្មានសេដ្ឋកិច្ចណាអាចដំណើរការ ដោយជោគជ័យបានទេបើគ្មានប្រព័ន្ធហិរញ្ញវត្ថុរឹងមាំ។

### **១.៥.២. តួនាទីរបស់ទីផ្សារហិរញ្ញវត្ថុក្នុងការអភិវឌ្ឍនៃសេដ្ឋកិច្ច**[4]

ទីផ្សារហិរញ្ញវត្ថុដើរតួនាទីយ៉ាងសំខាន់ ក្នុងការជម្រុញកំណើនសេដ្ឋកិច្ច។ តាមរយៈការប្រមូល ប្រាក់សន្សំសម្រាប់ការវិនិយោគប្រកបដោយផលិតភាព និងជួយសម្រួលដល់លំហូរមូលធនទីផ្សារហិរញ្ញ វត្ថុជម្រុញការវិនិយោគទាំងធនធានរូបវន្ត និងធនធានមនុស្ស។ វិស័យហិរញ្ញវត្ថុក៏ជួយសន្សំប្រាក់ដល់ការ ប្រើប្រាស់ដែលមានផលិតភាពកាន់តែច្រើនតាមរយៈការប្រមូល និងវិភាគព័ត៌មានអំពីការវិនិយោគ។ វាត្រូវ

[4] https://talentedge.com/blog/role-finance-development-economy/

បានគេអះអាងផងដែរថា ប្រព័ន្ធហិរញ្ញវត្ថុអាចបង្កើនប្រសិទ្ធភាពនៅក្នុងវិស័យសាជីវកម្មដោយត្រួតពិនិត្យការគ្រប់គ្រង និងប្រើប្រាស់ការគ្រប់គ្រងសាជីវកម្ម។ ប្រតិបត្តិករសាធារណៈក៏ដូចជា ប្រតិបត្តិករឯកជន ប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុផ្សេងៗដើម្បីប្រមូល និងវិនិយោគមូលនិធិរយៈពេលខ្លីដែលប្រសិនបើអាចត្រូវការវាអាចត្រូវបានរំលាយយ៉ាងឆាប់រហ័សដើម្បីបំពេញនូវតម្រូវការរយៈពេលខ្លី។ វិនិយោគិនរកលុយបាននៅផ្សារមូលធនតាមរយៈការទិញនិងលក់ មូលបត្រហិរញ្ញវត្ថុ។ នៅពេលវិនិយោគិនទិញឧបករណ៍បំណុលដូចជាសញ្ញាប័ណ្ណរដ្ឋាភិបាលមូលធនក្រុង ឬសញ្ញាប័ណ្ណសាជីវកម្មពួកគេទទួលបានការទូទាត់ការប្រាក់ពីអ្នកចេញមូលបត្របំណុលបូក នឹងចំនួនទឹកប្រាក់ដើមនៅចុងបញ្ចប់នៃរយៈពេលប្រាក់កម្ចី។ ចំនួនទឹកប្រាក់នៃការប្រាក់ដែលវិនិយោគិនត្រូវបង់ឲ្យមានបំណុលគឺ អាស្រ័យលើអត្រាការប្រាក់ដែលបានព្រមព្រៀងដោយកិច្ចសន្យាប្រាក់កម្ចី។ អត្រាការប្រាក់ខ្ពស់លើសុវត្ថិភាពបំណុលខ្ពស់ជាងការទូទាត់ការប្រាក់ដែលរំពឹងទុក។

ដូច្នេះតាមរយៈការបង្កើតយន្តការដែលមានប្រសិទ្ធិភាពសម្រាប់ប្រតិបត្តិការ នៅក្នុងឧបករណ៍ហិរញ្ញវត្ថុរយៈពេលវែងវាផ្តល់នូវការបង្កើតទ្រព្យសម្បត្តិយ៉ាងច្រើន សម្រាប់រដ្ឋាភិបាលក្រុមហ៊ុនសាជីវកម្មបុគ្គលឯកជន និងស្ថាប័នហិរញ្ញវត្ថុផ្សេងទៀត។

# ជំពូកទី២

# ដំណើរការទីផ្សារមូលបត្រកម្ពុជា

## ២.១. គណៈកម្មការមូលបត្រកម្ពុជា[5]

គណៈកម្មការមូលបត្រកម្ពុជា(គ.ម.ក.)មានគោលដៅ និងគោលបំណងដូចខាងក្រោម៖

- គ្រប់គ្រង និងត្រួតពិនិត្យទីផ្សារមូលបត្រ រួមទាំងទីផ្សារមូលបត្ររដ្ឋនៃព្រះរាជាណាចក្រកម្ពុជា
- កំណត់លក្ខខណ្ឌ ដើម្បីផ្តល់ការអនុញ្ញាតជូនប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ។
- កំណត់លក្ខខណ្ឌដើម្បីផ្តល់អាជ្ញាប័ណ្ណជូនក្រុមហ៊ុនមូលបត្រ និងភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រ
- លើកកម្ពស់ និងជម្រុញដល់ការគោរពតាមលក្ខខណ្ឌនៃច្បាប់ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធនានា
- បង្កើត និងរក្សាទំនុកចិត្តអ្នកវិនិយោគដោយការពារសិទ្ធិរបស់អ្នកវិនិយោគ និងធានាឲ្យមានការបោះផ្សាយមូលបត្រប្រកបដោយសណ្តាប់ធ្នាប់ និងត្រឹមត្រូវ។
- ជម្រុញការអភិវឌ្ឍន៍ទីផ្សារមូលបត្រដោះស្រាយវិវាទនានា ដែលពាក់ព័ន្ធនឹងវិស័យមូលបត្រ
- បង្ការ និងដាក់ទណ្ឌកម្មចំពោះបទល្មើសនានាដែលផ្តល់ផលប៉ះពាល់ដល់ទីផ្សារមូលបត្រ និងអ្នកវិនិយោគ។

### ២.១.២. ចក្ខុវិស័យ

គណៈកម្មការមូលបត្រកម្ពុជាហៅកាត់ថា គ.ម.ក ត្រូវបានបង្កើតឡើងក្រោយពីច្បាប់មូលបត្ររដ្ឋ និងច្បាប់ស្តីពីការបោះផ្សាយ និងជួញដូរមូលបត្រមហាជនបានអនុម័តរួច។ គ.ម.ក មានគោលដៅគ្រប់គ្រងវិស័យមូលបត្រក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងចូលរួមចំណែក ដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងសង្គមតាមរយៈការកៀរគរមូលធនពីសាធារណៈជន ឬអ្នកវិនិយោគមូលបត្រ ដើម្បីឆ្លើយតបទៅនឹងតម្រូវការហិរញ្ញវត្ថុសម្រាប់វិនិយោគនៅកម្ពុជា។

### ២.១.៣. បេសកកម្ម

បេសកម្មរបស់ គណៈកម្មការមូលបត្រកម្ពុជារួមមាន៖

- បង្កើតនិងរក្សាទំនុកចិត្តអ្នកវិនិយោគនៅកម្ពុជាតាមរយៈការ ការពារសិទ្ធិស្របច្បាប់អ្នកវិនិយោគ

[5] គណៈកម្មការមូលបត្រកម្ពុជា, www.secc.gov.kh

និងធានាឲ្យមានការបោះផ្សាយនិងការជួញដូរមូលបត្រប្រកបដោយសណ្តាប់ធ្នាប់និងត្រឹមត្រូវ

- លើកកម្ពស់ការគ្រប់គ្រងទីផ្សារមូលបត្រឲ្យមានប្រសិទ្ធិភាព និងជម្រុញការអភិវឌ្ឍទីផ្សារនេះឲ្យមានសណ្តាប់ធ្នាប់ និងត្រឹមត្រូវ
- ជម្រុញឲ្យមានការធ្វើវិនិយោគទុនពីបរទេសនិងការចូលរួមក្នុងទីផ្សារមូលបត្រកម្ពុជា
- ជម្រុញឲ្យមានភាពសម្បូរបែបនៃឧបករណ៍សញ្ជ័យ តាមរយៈការទិញមូលបត្រ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត
- ជួយសម្រួលដល់ការធ្វើឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ២.២. ទីតាំងរបស់គ.ម.ក

គណៈកម្មការមូលបត្រកម្ពុជាមានទីតាំងនៅផ្ទះលេខ៩៩ ផ្លូវលេខ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខ័ណ្ឌសែនសុខ រាជធានីភំពេញ។

## ២.៣. រូបសញ្ញានិង អត្ថន័យនៃរូបសញ្ញារបស់គ.ម.ក

### ២.៣.១. រូបសញ្ញា

រូបភាពទី១ ៖ រូបសញ្ញានិង អត្ថន័យនៃគ.ម.ក

- រូបហង្សពណ៌មាស
- រូបភាពស្លឹកឈើផ្នែកខាងឆ្វេងមានរំលេចស្រមោលពណ៌មាស ហើយខាងស្តាំរំលេចស្រមោលពណ៌ប្រផេះ។
- រូបរង្វង់ថាសដែលពាក់កណ្តាលមានពណ៌មាស និងពាក់កណ្តាលទៀតមានពណ៌ប្រផេះ។

- ព័ទ្ធជុំវិញជារង្វង់នៅផ្នែកខាងលើ ដោយអក្សរខ្មែរថា "គណៈកម្មការមូលបត្រកម្ពុជា" និងព័ទ្ធរង្វង់នៅផ្នែក ខាងក្រោមដោយអក្សរអង់គ្លេសថា "SECURITIES AND EXCHANGE COMMISSION OF CAMBODIA"។

## ២.៣.២. អត្ថន័យរូបសញ្ញា

- រូបហង្សមានពណ៌មាសតំណាងឱ្យអាជ្ញាធរហិរញ្ញវត្ថុដែលជាអ្នកត្រួតពិនិត្យនិង គ្រប់គ្រងប្រតិបត្តិការមូលបត្រ និងធានាឱ្យដំណើរការទីផ្សារមូលបត្រប្រកបដោយប្រសិទ្ធភាព មានសណ្ដាប់ធ្នាប់ និងតម្លាភាព។
- រូបរង្វង់ថាសដែលពាក់កណ្ដាលមានពណ៌មាស និងពាក់កណ្ដាលទៀតមានពណ៌ប្រផេះដែលតំណាងឱ្យភាពចំណេញខាត ឬភាពឡើងចុះនៃដំណើរការទីផ្សារ។
- រូបហង្សពណ៌មាសឈរលើរង្វង់ថាសដែលមានជើងម្ខាងជាន់លើផ្ទៃពណ៌មាស និងជើងម្ខាងទៀតជាន់លើផ្ទៃពណ៌ប្រផេះ ចង់បង្ហាញថាភាពចំណេញខាត ឬភាពឡើងចុះនៃកិច្ចដំណើរការទីផ្សារស្ថិតនៅក្រោមការត្រួតពិនិត្យ និងគ្រប់គ្រងរបស់អាជ្ញាធរជាគណៈកម្មការមូលបត្រកម្ពុជា។
- រូបស្លឹកឈើ តំណាងឱ្យលទ្ធផលជាផ្លែផ្កានៃការចូលរួមចំណែករបស់វិស័យមូលបត្រក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

## ២.៣.៣. មូលហេតុនៃជម្រើសយករូបហង្សពណ៌មាសជានិមិត្តសញ្ញា

- រូបហង្សពណ៌មាសជាប់ពាក់ព័ន្ធទៅនឹងដំណើរការវិវឌ្ឍនៃរូបិយវត្ថុរបស់ខ្មែរ ដោយរូបនេះត្រូវបានប្រើប្រាស់ជាលើកដំបូងនៅលើប្រាក់ប្រាសាទ ក្នុងរជ្ជកាលព្រះបាទអង្គឌួងដើម្បីរំលឹកដល់លោកសំអាងហង្សដែលព្រះបាទអង្គឌួងបញ្ជូនឱ្យទៅសិក្សាវិជ្ជាបោះផ្សាយប្រាក់នៅបរទេស។
- រូបហង្សពណ៌មាសនេះជារូបសញ្ញាដែលបានតំណាងឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនាសម័យសង្គមរាស្ត្រនិយមសម័យសាធារណរដ្ឋ និងក្នុងសម័យព្រះរាជាណាចក្រកម្ពុជាទី២ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ សម្តេចអគ្គមហាសេនាបតីតេជោហ៊ុនសែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

## ២.៣.៤. ត្រារបស់គណៈកម្មការមូលបត្រកម្ពុជា



រូបភាពទី២ ៖ ត្រារបស់គ.ម.ក

ត្រារបស់គណៈកម្មការមូលបត្រកម្ពុជាមានលក្ខណៈប្រហាក់ប្រហែលនឹង ត្រាមូលរបស់អាជ្ញាធរឬស្ថាប័នរដ្ឋដទៃទៀតដែរ ដោយនៅកន្លែងរង្វង់មូលផ្នែកខាងលើមានអក្សរសរសេរថា "ព្រះរាជាណាចក្រកម្ពុជា ផ្នែកកណ្តាលមានសញ្ញា ប្រាសាទអង្គរវត្ត និងផ្នែកខាងក្រោមមានអក្សរសរសេរថា "គណៈកម្មការមូលបត្រកម្ពុជា "។

### ២.៣.៥. រចនាសម្ព័ន្ធអង្គការចាត់តាំងគ.ម.ក

គ.ម.ក មានរចនាសម្ព័ន្ធចាត់តាំងដូចខាងក្រោម៖




រូបភាពទី៣ ៖ គណៈកម្មការមូលបត្រកម្ពុជា

## ២.៤. តួនាទី និងភារកិច្ចរបស់គណៈកម្មការមូលបត្រកម្ពុជា

គ.ម.ក.មាននាយកដ្ឋានចំណុះចំនួន០៦(ប្រាំមួយ)ដែលត្រូវគ្រប់គ្រងដោយអគ្គនាយកនៃ គ.ម.ក មានដូចជា៖

**១.នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ**

មានមុខងារតួនាទីដូចតទៅ៖

- រៀបចំផែនការ និងថវិការបស់ គ.ម.ក.
- គ្រប់គ្រងកិច្ចការរដ្ឋបាល
- ធ្វើទំនាក់ទំនងជាមួយស្ថាប័នរដ្ឋ និងឯកជននានា
- រៀបចំតារាងប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភនានាដល់មន្ត្រីនៃ គ.ម.ក.
- គ្រប់គ្រង និងផ្តល់សេវាកម្មបច្ចេកវិទ្យាព័ត៌មាន

**២.នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ**

មានមុខងារ និងតួនាទីដូចតទៅ៖

- រៀបចំលក្ខខណ្ឌតម្រូវនានាសម្រាប់ផ្តល់ការអនុញ្ញាតឲ្យក្រុមហ៊ុននានាបោះផ្សាយលក់មូលបត្រជាសាធារណៈ
- រៀបចំលក្ខខណ្ឌតម្រូវនានា ទាក់ទងនឹងអភិបាលកិច្ច និងការគ្រប់គ្រងក្រុមហ៊ុនបោះផ្សាយមូលបត្រជាសាធារណៈ
- ត្រួតពិនិត្យលក្ខខណ្ឌតម្រូវនានា ទាក់ទងនឹងអភិបាលកិច្ច និងការគ្រប់គ្រងក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ជាសាធារណៈជាប្រចាំ
- ពិនិត្យ និងផ្តល់យោបល់លើការស្នើសុំចុះបញ្ជី ឯកសារផ្តល់ព័ត៌មាន ឯកសារផ្តល់ព័ត៌មានបន្ថែម ឯកសារ ផ្តល់ព័ត៌មានជំនួស និងសេចក្តីថ្លែងនានាដែលពាក់ព័ន្ធនឹងធុរកិច្ចមូលបត្រ
- ចុះបញ្ជីឯកសារផ្តល់ព័ត៌មាន ឯកសារផ្តល់ព័ត៌មានបន្ថែម ឯកសារផ្តល់ព័ត៌មានជំនួស និងសេចក្តីថ្លែង នានារបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ
- ត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ ឬ/និង របាយការណ៍អាជីវកម្មរបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រលក់ ជាសាធារណៈ

**៣.នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ**

មានមុខងារ និងតួនាទីដូចតទៅ៖

- រៀបចំបទបញ្ញត្តិ និងលក្ខខណ្ឌតម្រូវនានាសម្រាប់ផ្តល់អាជ្ញាប័ណ្ណដល់ក្រុមហ៊ុមមូលបត្រ ភ្នាក់ងារក្រុមហ៊ុន មូលបត្រ ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួញជើងសារមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកចូល រួមដ៏នៃនៅក្នុងទីផ្សារ ដើម្បីដាក់សុំការពិនិត្យ និងអនុញ្ញាតពីអគ្គនាយកនៃ គ.ម.ក.
- ពិនិត្យ និងផ្តល់យោបល់ដល់ការស្នើសុំអាជ្ញាប័ណ្ណ ដើម្បីធ្វើជាក្រុមហ៊ុនមូលបត្រ ភ្នាក់ងាររបស់ក្រុមហ៊ុន មូលបត្រ ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួញជើងសារមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកចូលរួមដ៏ទៃទៀតនៅក្នុងទីផ្សារ
- ត្រួតពិនិត្យ និងតាមដាននូវប្រតិបត្តិការរបស់ក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួញជើងសារមូលបត្រអ្នកគ្រប់គ្រងមូលនិធិ និងអ្នកចូលរួមដ៏ទៃទៀតនៅក្នុងទីផ្សារ

**៤.នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ**

មានមុខងារនិងតួនាទីដូចតទៅ៖

- ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ ដើម្បីដាក់សុំការ
- ពិនិត្យ និងអនុញ្ញាតពីអគ្គនាយកនៃ គ.ម.ក.
- ពិនិត្យ និងផ្តល់យោបល់លើពាក្យស្នើសុំការអនុញ្ញាត ដើម្បីធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ
- ប្រតិបត្តិករប្រព័ន្ធទូទាត់ និងផាត់ទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ
- ត្រួតពិនិត្យ និងតាមដានលើការផ្គត់ផ្គង់ប្រព័ន្ធជួញដូរមូលបត្រ និងប្រតិបត្តិការផ្សេងៗទៀតរបស់ប្រតិបត្តិករទីផ្សារមូលបត្រ
- ត្រួតពិនិត្យ និងតាមដានលើប្រតិបត្តិការនៃប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់
- ត្រួតពិនិត្យ និងតាមដានលើប្រតិបត្តិការនៃប្រតិបត្តិកររក្សាទុកមូលបត្រ
- ត្រួតពិនិត្យជាក់ស្តែងដល់ទីកន្លែងតាមការចាំបាច់ ចំពោះប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធ ផាត់ទាត់ និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ

**៥.នាយកដ្ឋានកិច្ចការគតិយុត្ត**

មានមុខងារនិងតួនាទីដូចតទៅ៖

- ពិនិត្យ និងផ្តល់យោបល់លើវិធានប្រតិបត្តិការរបស់ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ ដើម្បីដាក់សុំការត្រួតពិនិត្យ និងសម្រេចពីអគ្គនាយកនៃ គ.ម.ក
- ពិនិត្យ និងផ្តល់យោបល់លើវិធានប្រតិបត្តិការដែលស្នើដោយស្ថាប័ននិយ័តករ
- រៀបចំបទប្បញ្ញត្តិចាំបាច់នានា និងលើកសំណើធ្វើវិសោធនកម្មច្បាប់ និងបទបញ្ញត្តិផ្សេងៗដើម្បីគាំទ្រដល់ ការអភិវឌ្ឍវិស័យមូលបត្រ
- ទទួលពាក្យបណ្តឹង និងធ្វើការស៊ើបអង្កេតពាក់ព័ន្ធនឹងប្រតិបត្តិការបោះផ្សាយ និងជួញដូរមូលបត្រដែល ល្មើសច្បាប់ ឫមិនប្រក្រតី ទាំងនៅក្នុងទីផ្សារដំបូង និងនៅក្នុងទីផ្សារបន្ទាប់
- ពិនិត្យ និងផ្តល់យោបល់ដើម្បីចាត់វិធានការដាក់ពិន័យនានា ពាក់ព័ន្ធនឹងបុគ្គលប្រព្រឹត្តល្មើសនឹងច្បាប់ និងបទបញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងវិស័យមូលបត្រ

**៦.នាយកដ្ឋានស្រាវជ្រាវបណ្តុះបណ្តាលអភិវឌ្ឍន៍ទីផ្សារមូលបត្រនិងទំនាក់ទំនងអន្តរជាតិ**

មានមុខងារតួនាទីដូចតទៅ៖

- សិក្សាស្រាវជ្រាវពីយុទ្ធសាស្ត្រនានាដើម្បីអភិវឌ្ឍវិស័យមូលបត្រនៅ ព្រះរាជាណាចក្រកម្ពុជាសិក្សាស្រាវជ្រាវលើការអភិវឌ្ឍន៍គ្រប់គ្រងនិង ការអភិវឌ្ឍវិស័យមូលបត្ររៀបចំយុទ្ធសាស្ត្រដើម្បីជំរុញឲ្យក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈសិក្សាវាយតម្លៃ និងផ្តល់យោបល់
- រៀបចំយុទ្ធសាស្ត្រ ដើម្បីជំរុញឲ្យក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈសិក្សាវាយតម្លៃនិងផ្តល់យោបល់លើការបង្កើតឧបករណ៍ហិរញ្ញវត្ថុថ្មី មុននឹងអនុញ្ញាតឲ្យបោះផ្សាយនៅលើ ទីផ្សារ
- រៀបចំកម្មវិធីបណ្តុះបណ្តាលដល់សាធារណជន និងអ្នកចូលរួមនានាក្នុងវិស័យមូលបត្រ
- ធ្វើទំនាក់ទំនងជាមួយនិយ័តករមូលបត្រនៃបណ្តាប្រទេសក្នុងតំបន់ និងនៅក្នុងពិភពលោក
- ចូលរួមក្នុងវេទិកាជាតិ និងអន្តរជាតិពាក់ព័ន្ធនានា។

## ២.៥. ប្រធាននិង សមាជិកនៃគ.ម.ក

គណៈកម្មការមូលបត្រកម្ពុជាមានប្រធានមួយរូប និងសមាជិកចំនួន ៨រូប។ ប្រធាននៃ គ.ម.ក. ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។គ.ម.ក.មានសមាជិក៨រូបដូចខាងក្រោម៖

១. តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ០១រូប

២. តំណាងធនាគារជាតិកម្ពុជា ០១រូប

៣. តំណាងក្រសួងពាណិជ្ជកម្ម ០១រូប

៤. តំណាងក្រសួងយុត្តិធម៌ ០១រូប

៥. តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ០១រូប

៦. អគ្គនាយកនៃ គ.ម.ក. ០១រូប

៧. អ្នកជំនាញដែលមានបទពិសោធន៍វិស័យមូលបត្រ០២រូប។

## ២.៦. ការវិនិយោគក្នុងវិស័យមូលបត្រ

### ២.៦.១. លក្ខខណ្ឌដែលត្រូវបំពេញដើម្បីវិនិយោគក្នុងវិស័យមូលបត្រ

បុគ្គលដែលមានបំណងធ្វើការវិយោគលើវិស័យមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តន៍ទៅតាមដំណាក់កាលដែលមានដូចខាងក្រោម៖

**ដំណាក់កាលទី១ ការត្រៀមខ្លួនមុនពេលជួញដូរ**

បុគ្គលដែលមានបំណងធ្វើការវិយោគក្នុងវិស័យមូលបត្រ ត្រូវធ្វើការកំណត់ពីគោលបំណងនៃការវិនិយោគឲ្យបានច្បាស់លាស់។ ការកំណត់អំពីគោលបំណង គឺរាល់ការវិនិយោគតែងតែផ្សារភ្ជាប់នឹងកត្តាហានិភ័យដែលវិនិយោគិនត្រូវតែពិចារណា មុនពេលសម្រេចចិត្តក្នុងការវិនិយោគលើអ្វីការវិនិយោគដែលមានហានិភ័យខ្ពស់ នោះប្រាក់ចំណេញអាចទទួកបានក៏ខ្ពស់ដែរ (High risk, high return) ហើយគួរកុំប្រថុយប្រថានវិនិយោគលើគម្រោងវិនិយោគតែមួយ (Don't put all your eggs in one basket)។ បុគ្គលដែលមានបំណងវិនិយោគត្រូវបំពេញលក្ខខណ្ឌកំណត់ដូចខាងក្រោម៖

❖ ការទទួលបានលេខអត្តសញ្ញាណវិនិយោគិន (Investors Identification)

ដើម្បីធ្វើការវិនិយោគក្នុងវិស័យមូលបត្រកម្ពុជា វិនិយោគិនត្រូវមានលេខអត្តសញ្ញាណវិនិយោគិនដែលទទួលបានពី **គ.ម.ក.** មុននឹងធ្វើសកម្មភាពជួញដូរ។ វិនិយោគិនអាចស្នើរសុំលេខអត្តសញ្ញាណវិនិយោគិននេះដោយផ្ទាល់មក **គ.ម.ក.** ឬតាមរយៈក្រុមហ៊ុនមូលបត្រណាមួយដែលទទួលបានអជ្ញាប័ណ្ណពី **គ.ម.ក.**។ បច្ចុប្បន្នក្រុនហ៊ុនមូលបត្រដែលទទួលបានអាជ្ញាប័ណ្ណពី **គ.ម.ក.** មានចំនួន១០ ក្នុងនោះមានក្រុមហ៊ុនធានាទិញមូលបត្រចំនួន៦ ក្រុមហ៊ុន, ក្រុមហ៊ុនពាណិជ្ជករមូលបត្រមានចំនួន១ ក្រុមហ៊ុន, និងក្រុមហ៊ុនឈ្មួញជើងសារមូលបត្រមានចំនួន៣ ក្រុមហ៊ុន ដូចមានខាងក្រោម៖

១. យាន់តា ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី /Yuanta Securities (Cambodia) PLC.

២. អ អេច ប៊ីស៊ីឃ្យូរីធី (ខេមបូឌា) ម.ក /RHB Securities (Cambodia) PLC.

៣. កាណា ស៊ីឃ្យូរីធី អិលធិឌី / Cana Securities Ltd.

៤. កាណា ស៊ីឃ្យូរីធី ភីអិលស៊ី /Campu Securities PLC.

៥. អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីឃ្យូរីធី /SBI Royal Securities PLC.

៦. ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី /Phnom Penh Securities PLC.

៧. ហ្គោលដេន ហ្វ័រឈូន (ខេមបូឌា) ស៊ីឃ្យូរីធី ភីអិលស៊ី /Golden Fortune (Cambodia) Securities PLC.

៨. អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី /ACLEDA Securities PLC.

៩. ខេប ស៊ីឃ្យូរីធី លីមីតធីត /CAS Securities Limited.

១០. ខេមបូឌា-វៀតណាម ស៊ីឃ្យូរីធី ឯ.ក /Cambodia-Vietnam Securities Co., Ltd.

ក. ការបំពេញពាក្យស្នើរសុំលេខអត្តសញ្ញាណវិនិយោគិន

បុគ្គលដាក់ពាក្យស្នើរសុំត្រូវបំពេញពាក្យស្នើរសុំទៅតាមទម្រង់ដែលបានកំណត់ដោយ គ.ម.ក. ទម្រង់ទាំងនោះគឺ ទម្រង់ "ក" សម្រាប់រូបវន្តបុគ្គល និង ទម្រង់ "ខ" សម្រាប់នីតិបុគ្គល ដែលត្រូវភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធដូចមានកំណត់ក្នុងគោលការណ៍ណែនាំលេខ ០០១ គ.ម.ក./គ.ណ.ន. ចុះថ្ងៃទី ៦ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការផ្តល់លេខអត្តសញ្ញាណវិនិយោគិន។

ខ. ថ្លៃសេវានៃការដាក់ពាក្យស្នើរសុំ ឬស្នើរសុំបន្តលេខអត្តសញ្ញាណវិនិយោគិន និងសុពលភាព

បុគ្គលដាក់លេខអត្តសញ្ញាណវិនិយោគិន ត្រូវបង់ថ្លៃពាក្យស្នើរសុំ និងសោហ៊ុយសិក្សាសំណុំលិខិតនៅពេលដាក់ពាក្យស្នើរសុំ ឬស្នើរសុំបន្តលេខអត្តសញ្ញាណវិនិយោគិននៅ គ.ម.ក. ដូចតទៅ៖

-ចំពោះរូបវន្តបុគ្គល ជាសាច់ប្រាក់ចំនួន ២០,០០០រៀល។

-ចំពោះនីតិបុគ្គល ជាសាច់ប្រាក់ចំនួន ៥០,០០០រៀល។

លេខអត្តសញ្ញាណវិនិយោគិនមានសុពលភាពសម្រាប់រយៈពេល ១០ឆ្នាំ។ វិនិយោគិនត្រូវដាក់ពាក្យស្នើសុំបន្តលេខអត្តសញ្ញាណវិនិយោគិន មុនពេលអស់សុពលភាពរយៈពេល ៣ខែ។

**សូមបញ្ជាក់៖** វិនិយោគិនម្នាក់ទទួលបានលេខអត្តសញ្ញាណវិនិយោគិនតែមួយគត់។

❖ ការបើកគណនីជួញដូរ

បន្ទាប់ពីទទួលបានលេខអត្តសញ្ញាណវិនិយោគិនពី គ.ម.ក. វិនិយោគិនត្រូវបានធ្វើការបើកគណនីជួញដូរនៅក្រុនហ៊ុនមូលបត្រណាមួយដែលទទួលបានអាជ្ញាប័ណ្ណពី គ.ម.ក.។

ក. ការជ្រើសរើសក្រុមហ៊ុនមូលបត្រដើម្បីបើកគណនីជួញដូរ

មុននឹងឈានដល់បើកគណនីជួញដូរ វិនិយោគិនត្រូវជ្រើសរើលក្រុមហ៊ុនមូលបត្រជាមុនសិន។ វិនិយោគិនត្រូវជ្រើសរើសក្រុមហ៊ុនមូលបត្រមួយដែលទទួលបានអាជ្ញាប័ណ្ណពី គ.ម.ក. និងជាសមាជិក

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។ ជាមួយគ្នានេះ វិនិយោគិនគួរតែពិចារណាទៅលើកត្តាមួយចំនួនដូចជាសេវាកម្ម កម្រៃជើងសារ សិទ្ធិនិងកាតព្វកិច្ចនៅក្នុងកិច្ចព្រមព្រៀងអតិថិជន។

ខ. គណនីជួញដូរ

វិនិយោគិនមួយអាចបើកគណនីជួញដូរមួយនៅក្រុមហ៊ុនមូលបត្រមួយ មានន័យថាវិនិយោគិនអាចបើកគណនីជួញដូរលើសពីមួយបាននៅក្រុមហ៊ុនមូលបត្រផ្សេងៗគ្នា។

គណនីជួញដូរមាន ២ដូចខាងក្រោមៈ

១.គណនីសាច់ប្រាក់ៈ វិនិយោគិនត្រូវដាក់តម្កល់សាច់ប្រាក់ ១០០% ដើម្បីធ្វើការជួញដូរមូលបត្រ។ ក្រុមហ៊ុនមូលបត្រត្រូវយកសាច់ប្រាក់ដែលអតិថិជនបានដាក់តម្កល់នោះដាក់ចូលក្នុងគណនីសាច់ប្រាក់អតិថិជន (Client Money Account) នៅភ្នាក់អារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ (CSA)។

២.គណនីមូលបត្រៈ សម្រាប់រក្សាទុកមូលបត្រ នៅក្នុងប្រតិបត្តិការរក្សាទុកមូលបត្ររបស់វិនិយោគិនត្រូវបានរក្សាទុកនៅប្រតិបត្តិការរក្សារមូលបត្រ ដាច់ដោយឡែកពីទ្រព្យរបស់ក្រុមហ៊ុនមូលបត្រ។

**ដំណាក់កាលទី២ ការជួញដូរមូលបត្រ**

បន្ទាប់ពីបានបើកគណនីជួញដូរជាមួយក្រុមហ៊ុនមូលបត្ររួចមកវិនិយោគិនអាចធ្វើការជួញដូរមូលបត្រនៅលើទីផ្សារមូលបត្របាន។ វិនិយោគិនអាចជួញដូរមូលបត្រនៅលើទីផ្សារដំបូងនិងទីផ្សារបន្ទាប់។

**ដំណាក់កាលទី៣ ការធ្វើឲ្យប្រសើរឡើងលើការវិនិយោគ**

ក្រោយពីបានធ្វើការវិនិយោគក្នុងទីផ្សារមូលបត្រ វិនិយោគិនទទួលបានបទពិសោធន៍ និងចំណេះដឹងទាក់ទងនឹងការជួញដូរមូលបត្រនេះ វិនិយោគិនគួរមានសកម្មភាពដូចខាងក្រោមបន្ថែមទៀតៈ

-ពិនិត្យឡើងវិញលើគោលបំណងដែល អ្នកបានកំណត់មុនពេលជួញដូរនិងរៀបចំគោលបំណងនិងយុទ្ធសាស្ត្រការវិនិយោគរបស់អ្នកដើម្បីធ្វើឲ្យកាន់តែប្រសើរឡើង

-បន្តសិក្សានិងស្វែងយល់ពីទីផ្សារមូលបត្រ ការវិភាគលើទីផ្សារមូលបត្រ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត តាមរយៈការចូលរួមសិក្ខាសាលា វគ្គបណ្តុះបណ្តាល និងស្វ័យសិក្សាជាដើម។

-គម្បីតាមដានព័ត៌មានអំពីវិស័យមូលបត្រ ជាពិសេសទាក់ទងទៅក្រុមហ៊ុនបោះផ្សាយ និងក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រដែលលោកអ្នកបានកាន់កាប់មូលបត្រ។

-តាមដានព័ត៌មានសេដ្ឋកិច្ចរួមមានកំណើនសេដ្ឋកិច្ច អត្រាប្តូរប្រាក់គោលនយោបាយសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល

-ធ្វើជាភាគហ៊ុនិកដែលមានការទទួលខុសត្រូវខ្ពស់។

### ២.៦.២. បទប្បញ្ញត្តិដែលវិនិយោគិនត្រូវយល់ដឹងក្នុងវិស័យមូលបត្រ

វិនិយោគិនត្រូវយល់ដឹងពីច្បាប់បញ្ញាត្តិ និងគោលការណ៍ណែនាំពាក់ព័ន្ធនានា មួយចំនួនមុននឹងធ្វើការសម្រេចចិត្តវិនិយោគលើទីផ្សារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដូចខាងក្រោម៖

-ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន

-អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងជួញដូរមូលបត្រមហាជន

-ប្រកាសស្តីពី ការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ

-ប្រកាសស្តីពី ថ្លៃសេវាលើប្រតិបត្តិការជួញដូរមូលបត្រកម្មសិទ្ធិ

-ប្រកាសស្តីពី ថ្លៃសេវាលើប្រតិបត្តិការជួញដូរមូលបត្របំណុល

-វិធានស្តីពីការចុះបញ្ជី

-វិធានប្រតិបត្តិការទីផ្សារ

-វិធានប្រតិបត្តិការផាត់ទាត់មូលបត្រ

-វិធានប្រតិបត្តិការរក្សាទុកមូលបត្រ និងបទបញ្ញាត្តិផ្សេងៗទៀត។

ជាមួយគ្នានេះដែរ ដើម្បីជៀសវាងនឹងហានិភ័យប្រឈមនឹងផ្លូវច្បាប់ និងទទួលទោសទណ្ឌនានា វិនិយោគិន ត្រូវស្វែងយល់បន្ថែមពាក់ព័ន្ធការជួញដូរផ្ទៃក្នុង ដែលមានចែងក្នុងច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជនឲ្យបានលម្អិតនិងច្បាស់លាស់។

## ២.៧. ប្រភេទនៃការជួញដូរមូលបត្រ [6]

### ២.៧.១. ការបញ្ជាតាមថ្លៃ

**ក. ការបញ្ជាទិញ-លក់មូលបត្រ** (Buy and Sell Orders)

ការបញ្ជាទិញមូលបត្របង្កើតឲ្យមាន ឬបង្កើនការកាន់កាប់មូលបត្រជាក់លាក់មួយ។ វិនិយោគិនដែលកាន់កាប់មូលបត្រមួយមានន័យថា ពួកគាត់មានកម្មសិទ្ធិកាន់កាប់មូលបត្ររយៈពេលវែង (Long Position) នៃមូលបត្រនោះ។ ផ្ទុយមកវិញការបញ្ជាលក់មូលបត្រធ្វើឲ្យអស់សិទ្ធិ ឬកាត់បន្ថយការកាន់កាប់មូលបត្រ។ វិនិយោគិនដែលលក់មូលបត្រដែលពួកគាត់ពុំមានក្នុងដៃ មានន័យថាពួកគេខ្ចីមូលបត្ររបស់អ្នកដទៃ លក់ក្នុងរយៈពេលខ្លី (Short Position) លើមូលបត្រនោះ។ ជាទូទៅការខ្ចីមូលបត្ររយៈពេលខ្លី (short Sale) អាចត្រូវបានហាមឃាត់ក្នុងប្រទេសមួយចំនួន។

[6] សៀវភៅមូលដ្ឋានគ្រឹះនៃទីផ្សារមូលបត្រ បោះពុម្ពលើកទី១ឆ្នាំ២០១១ (ទំព័រទី១៣៧)

វិនិយោគិននឹងធ្វើការខ្ចីមូលបត្រតយៈពេលខ្លី (short Sale) នៅពេលដែលខ្លួនជឿថា មូលបត្រនោះនឹងធ្លាក់ថ្លៃ។ ក្រោយពេលធ្លាក់ថ្លៃពួកគេនឹងទិញយកមូលបត្រនោះដើម្បីសងទៅម្ចាស់ដើមវិញក្នុងតម្លៃទាប ហើយពួកគេនឹងទទួលបានប្រាក់ចំណេញពីគម្លាតទាំងពីរ។ ការធ្វើដូចនេះត្រូវបានគេហៅថាជាការទូទាត់លើការខ្ចីមូលបត្រមកលក់ ឬការទិញមូលបត្រចូល (Buying In)។

**ខ. ការបញ្ជាតាមទីផ្សារ** (Market Order)

ការបញ្ជាតាមទីផ្សារ គឺជាប្រភេទនៃការបញ្ជាទិញ-លក់ដែលសាមញ្ញបំផុត។ ការបញ្ជាទិញ-លក់មូលបត្រនេះត្រូវបានធ្វើឡើងដោយមិនមានដាក់តម្លៃ ហើយការជួញដូរត្រូវបានប្រតិបត្តិជាមួយនឹងថ្លៃប្រសើរជាងគេបំផុតមួយ (Best price) នៅក្នុងទីផ្សារខណៈពេលការបញ្ជាត្រូវបានប្រតិបត្តិ (Execution) ឧទាហរណ៍៖ គឺនៅពេលថ្លៃខ្ពស់បំផុតសម្រាប់ការលក់ និងថ្លៃទាបបំផុតសម្រាប់ការទិញ។ ការជួញដូរប្រភេទនេះកើតឡើងភ្លាមៗ ហើយវិនិយោគិនចំបាច់ត្រូវបញ្ជាក់ការបញ្ជារបស់ខ្លួនភ្លាមៗដោយផ្ទាល់មាត់តាមរយៈទូរស័ព្ទចំពោះការបញ្ជាតាមប្រព័ន្ធអ៊ីធឺណែត។ ប្រសិនបើមូលបត្រមិនត្រូវបានជួញដូរញឹកញាប់នោះទេ គេអាចពន្យាពេលបានខ្លះក្នុងការបញ្ជាក់។

ដើម្បីជួញដូរ ឈ្មួញជើងសារមូលបត្រ (Securities Brokers) អាចផ្ញើរការបញ្ជាទៅកាន់បញ្ជរទីផ្សារ (Exchange Floor) ឬបញ្ជូនការបញ្ជាតាមបណ្តាញកុំព្យូទ័រណាមួយ។ បញ្ជាដែលមានលើបញ្ជរទីផ្សារត្រូវបានទិញ និងលក់ដោយសមាជិកទីផ្សារដែលជាឈ្មួញជើងសាមូលបត្រ ឬពាណិជ្ជករមូលបត្រ ((Securities Dealer)។ ឯបញ្ជាដែលដាក់នៅលើបណ្តាញកំព្យូទ័រនឹងត្រូវផ្គូផ្គងតាមប្រព័ន្ធជួញដូរដោយស្វែងរកការបញ្ជាពីដែលត្រូវគ្នាដើម្បីផ្គូផ្គង ឬផ្គូផ្គងបញ្ជាមួយ ជាមួយបញ្ជារពីរ បីដែលត្រូវគ្នា (គេច្រើននិយមហៅការផ្គូផ្គងនេះ ថាជាការបន្សុំការបញ្ជា)។ ឧទាហរណ៍៖ ការបញ្ជាទិញមួយមានចំនួន ១,០០០ ហ៊ុននៃក្រុមហ៊ុន ATC (និមិត្តសញ្ញា ATC ) អាចត្រូវផ្គូផ្គងជាមួយការ បញ្ជាលក់តែមួយដែលមានចំនួនស្មើគឺ ១,០០០ ហ៊ុនដូចគ្នា ឬការបញ្ជាពីរដែលសរុបចូលគ្នាមានចំនួនស្មើ ១,០០០ ហ៊ុន។

ឈ្មួញជើងសាមូលបត្រចង់ឲ្យវិនិយោគិនធ្វើការបញ្ជាតាមទីផ្សារ (Market Order) ពីព្រោះធ្វើដូចនេះពួកគេនឹងទទួលបានកម្រៃជើងសាភ្លាមៗម្យ៉ាងទៀត ឈ្មួញជើងសារមូលបត្រក៏មិនចាំបាច់ទុកការបញ្ជាក្នុងកំព្យូទ័ររបស់ពួកគេ ហើយដោយសារប្រទេសភាគច្រើនតម្រូវឲ្យមានរយៈពេលជាក់លាក់ (Periodic Confirmation) ជាមួយវិនិយោគិនមុនពេលបញ្ជាទិញដូច្នោះឈ្មួញជើងសាមូលបត្រមិនចាំបាត់ធ្វើការបញ្ជាក់ឡើយ។ ឈ្មួញជើងសាមូលបត្រនឹងត្រូវឧស្សាហ៍សួរបញ្ជាក់វិនិយោគិនរបស់ខ្លួនពីភាគហ៊ុនដែលនឹងត្រូវទិញ-លក់នៅលើទីផ្សារ។

**២.៧.២. ការបញ្ជាមានកំណត់** ( Limited Orders )

ការបញ្ជាមានកំណត់ គឺមានបញ្ជាក់ពីថ្លៃអតិបរិមាដែលវិនិយោគិនមានបំណងចង់ទិញ ឬថ្លៃអតិបរិមាដែលវិយោគិនមានបំណងចង់លក់ (ការកំណត់ថ្លៃខ្ពស់បំផុត ដែលខ្លួនហ៊ានទិញ និងថ្លៃទាបបំផុតដែលខ្លួនអាចលក់បាន)។ ការបញ្ជាមានកំណត់ ធ្វើឡើងដើម្បីបានថ្លៃដែលប្រសើរមួយ ពោលគឺប្រសិនបើមូលបត្រអាចដូញដូរនៅថ្លៃដែលប្រសើរជាងថ្លៃអតិបរិមា ឬអប្បរមាដែលបានកំណត់ នោះមូលបត្រត្រូវតែជួញដូរនឹងស្ថិតនៅត្រង់ថ្លៃណាដែលប្រសើរជាងនោះ។ ដូចនេះចំពោះបញ្ជាទិញមួយដែលកំណត់ថ្លៃអតិបរិមា ១០ ដុល្លារ អាចត្រូវបានទិញនៅត្រង់ថ្លៃ ៩ដុល្លារ ដោយសារវាថោកជាង ១០ដុល្លារប៉ុន្តែមិនអាចទិញនៅត្រង់ថ្លៃ ១១ដុល្លារទេ។ ផ្ទុយមកវិញបញ្ជាលក់មួយដែលកំណត់ថ្លៃអប្បរមា ១០ដុល្លារ អាចត្រូវបានលក់នៅត្រង់ថ្លៃ ១១ដុល្លារវិញ គឺមិនមែនថ្លៃប្រសើរជាងសម្រាប់គាត់ឡើយ។ឈ្មួញជើងសាមូលបត្រដែលមិនបានបញ្ជាដោយដាក់ថ្លៃកំណត់ ឬថ្លៃប្រសើរជាង ត្រូវបានចាត់ទុកថា ខកខានក្នុងការចូលរួមក្នុងទីផ្សារ (Missing the Market) ហើយជាទូទៅត្រូវទទួលខុសត្រូវចំពោះការខាតបង់ដែលកើតមានចំពោះវិនិយោគិន ដែលអាស្រ័យទៅតាមច្បាប់ និងបទប្បញ្ញត្តិរបស់ប្រទេសនិមួយៗ។

ការបញ្ជាមានកំណត់អនុញ្ញាតឲ្យជួញដូរដោយមិនចាំបាច់តាមដានឥតឈប់ឈរពី តម្លៃមូលបត្រដើម្បីដឹងច្បាស់ថាពេលណាត្រូវបញ្ជាទិញ-លក់មូលបត្រ។ ទោះបីជាវិនិយោគិនបានបញ្ជាទិញ-លក់មូលបត្រភ្លាមៗនៅលើទីផ្សារ នៅពេលដែលតម្លៃមូលបត្រឈានដល់តម្លៃដែលពួកគេចង់បានក៏ដោយ ប៉ុន្តែពេលវេលាដែលត្រូវចំណាយដើម្បីទូរស័ព្ទទៅឈ្មួញជើងសារមួយដើម្បីធ្វើប្រតិបត្តិបញ្ជា (Execute Order) គឺយូរល្មមគ្រប់គ្រាន់ដែលអាចឲ្យថ្លៃនោះប្រែប្រួលបន្តទៀតក្នុងទីផ្សារដែលមានភាពមមាញឹក(Active Market)។

**ក. ការបញ្ជាបញ្ឈប់** (Stop Order)៖ ការបញ្ជាបញ្ឈប់ មានសុពលភាពនៅពេលដែលទីផ្សារឈានទៅដល់ ឬឆ្លងកាត់ថ្លៃជាក់លាក់មួយ។ពេលឈានទៅដល់ថ្លៃនោះការបញ្ជានឹងមានសុពលភាព (Triggered) ហើយការបញ្ជានោះនឹងក្លាយទៅជាការបញ្ជាតាមទីផ្សារ (Market Order) ដែលនឹងត្រូវបានប្រតិបត្តិភ្លាមៗ។

ការបញ្ជាបញ្ឈប់ ត្រូវបានប្រើតែនៅលើទីផ្សារភាគហ៊ុន (Exchange) ប៉ុណ្ណោះ។ ទីផ្សាររំលងបញ្ជរ (Over-The-Counter Market) ស្ទើរតែទាំងអស់មិនទទួលការបញ្ជាបែបនេះទេដោយសារតែភាពខុសគ្នាក្នុងការប្រតិបត្តិការបញ្ជា រវាងទីផ្សារភាគហ៊ុនដេញថ្លៃ (Exchange Auction Market) និងទីផ្សាររំលងបញ្ជាលក់ដុំ (Over-The-Counter Dealer Market)។

ប្រសិនបើ បញ្ជាបញ្ឈប់ដាក់ថ្លៃក្នុងទំហំមួយខិតជិតទៅរកនឹងថ្លៃទីផ្សារពេកការបញ្ជានោះនឹងត្រូវបានប្រតិបត្តិយ៉ាងរហ័ស ហើយឱកាសក្នុងការទទួលបានប្រាក់ចំណេញច្រើនក៏នឹងត្រូវបាត់បង់ផងដែរ។ ប្រសិនបើថ្លៃទីផ្សារធ្លាក់ចុះច្រើន មុននឹងបញ្ជាបញ្ឈប់មានសុពលភាព ហើយបន្ទាប់មកកើនឡើងគេថា វិយោគិន (គួរប្រែសម្រួលជាភាសាខ្មែរ) Stopped out ។ ប្រសិនបើ បញ្ជាបញ្ឈប់ត្រូវបានដាក់ថ្លៃដែលស្ថិតនៅឆ្ងាយពីទីផ្សារពេក ការពារពីការខាតបង់នឹងត្រូវបានកាត់បន្ថយ។ ប្រសិនបើ មានរូបមន្តយ៉ាងសុក្រឹត្យមួយក្នុងការកំណត់ថាតើត្រូវដាក់ថ្លៃបញ្ជាបញ្ឈប់ឃ្លាតពីថ្លៃទីផ្សារប៉ុន្មាន យើងប្រាកដជិះនាវាលំហែកម្សាន្តនៅជុំវិញពិភពលោកដ៏ស្រស់បំព្រងដោយគ្មានការខ្វាយខ្វល់អ្វីឡើយ ហើយយើងគ្រាន់តែរងចាំទទួលប្រាក់ចំណេញដ៏ច្រើនសន្ធឹកសន្ធាប់ប៉ុណ្ណោះ។

**ខ. ការបញ្ជាបញ្ឈប់មានកំណត់** (Stop-limit Order)៖ ដូចទៅនឹងបញ្ជាបញ្ឈប់ដែរ បញ្ជាបញ្ឈប់មានកំណត់នឹងមានសុពលភាពនៅថ្លៃដែរបានកំណត់។ នៅពេលការបញ្ជាមានសុពលភាព វានឹងក្លាយទៅជាការបញ្ជាមានកំណត់។ ឧទាហរណ៍៖ វិនិយោគិនបានដាក់បញ្ជាលក់ ១០០ភាគហ៊ុននៃក្រុមហ៊ុនជួញដូរអាស៊ី (និមិត្តសញ្ញា ATC) នៅថ្លៃបញ្ឈប់មានកំណត់ ១២ដល្លារ ។ ដូចបញ្ជាបញ្ឈប់ដែរ វានឹងមានសុពលភាពពេលថ្លៃឈប់នៅចំណុច ១២ដុល្លារ ហើយវានឹងក្លាយទៅជាបញ្ជាមានកំណត់នៅថ្លៃ១២ដុល្លារថ្លៃប្រសើរជាងនេះ។ ប្រសិនបើថ្លៃធ្លាក់ចុះយ៉ាងលឿន ការបញ្ជាមានកំណត់នឹងអាចខកខាន ហើយមូលបត្រមិនត្រូវបានលក់ទេ។ ប្រសិនបើវាជាបញ្ជាបញ្ឈប់ទិញមានកំណត់ (Buy Stop-limit Order) ហើយថ្លៃកើនឡើងយ៉ាងលឿន ការបញ្ជាមានកំណត់នឹងអាចខកខាន ហើយមូលបត្រមិនត្រូវបានទិញទេ។

**២.៧.៣. ការបញ្ជាតាមពេលវេលា** ( Time Order )

ការបញ្ជាតាមពេលវេលាមិនដូចជាការបញ្ជាមួយទេ ប៉ុន្តែហាក់ដូចជាការណែនាំមួយថាតើបញ្ជាមួយមានលក្ខណៈល្អប្រសើរក្នុងរយៈពេលប៉ុន្មាន។

**ក. បញ្ជាក្នុងថ្ងៃ ឬបញ្ជាបើក** (Day Order or Open Order)

បញ្ជាក្នុងថ្ងៃមានសុពលភាពពេញមួយថ្ងៃនៃថ្ងៃជួញដូរ។ ប្រសិនបើការបញ្ជានេះមិនត្រូវបានប្រតិបត្តិនៅក្នុងថ្ងៃនេះទេ វានឹងត្រូវបានលុបចោល។ បញ្ជាតាមទីផ្សារ (Market Orders)ជាទូទៅគឺជាបញ្ជាក្នុងថ្ងៃ។ ប្រសិនបើការជួញដូរត្រូវបានលុបចោលការបញ្ជាថ្មីនឹងធ្វើឡើងនៅថ្ងៃជួញដូរបន្ទាប់។

បញ្ជាបើកមានសុពលភាពរហូត ទាល់តែបញ្ជាលុបចោល ហើយជាបញ្ជាដែលសាមញ្ញបំផុត។ ការបញ្ជាទាំងនេះ តែងតែត្រូវបានវាយតម្លៃដោយឈ្មួញជើងសាមូលបត្រ មុនពេលទទួលការបញ្ជា។ ឧទាហរណ៍៖ បញ្ជាទិញហ៊ុន ATC១០០ នៅថ្លៃ ១ដុល្លារ នៅពេលមូលបត្រកំពុងលក់ក្នុងតម្លៃ ១៤ដុល្លារ

អាចសមហេតុផលទទួលយកបានប៉ុន្តែបញ្ជាទិញ ភាគហ៊ុន ATC១០០ នៅថ្លៃ ១០ដុល្លារ មិនអាចទទួលយកបានទេចំពោះឈ្មួញជើងសាមូលបត្រ។

**ខ. ការបញ្ជាឲ្យបិទ ឬបើកជួញដូរ** (On the Open or close)

បញ្ជាប្រភេទនេះ តែងត្រូវបានប្រើនៅពេលទីផ្សាររំលងអធ្រាត (Overnight market) បង្ហាញពីការប្រែប្រួលខ្លាំងនៅទីផ្សារក្នុងស្រុក។ ការបញ្ជាឲ្យបិទការជួញដូរគឺជាបញ្ជាតាមទីផ្សារ (Market Orders) ប៉ុន្តែការបញ្ជាឲ្យបើកការជួញដូរ អាចជាការជួញដូរ តាមទីផ្សារ (Market Orders) ឬការបញ្ជាមានកំណត់។ ការបញ្ជាឲ្យបិទ ឬបើកការជួញដូរភាគច្រើនត្រូវបានប្រើដោយអ្នកជួញដូរប្រកបដោយវិជ្ជាជីវៈ (Professional Traders)។ ឧទាហរណ៍៖ អ្នកជួញដូរក្នុងថ្ងៃតែងតែបញ្ជាឲ្យបិទការជួញដូរទាំងអស់នៅចុងបញ្ចប់នៃថ្ងៃជួញដូរនិមួយៗ។

**គ. ការបញ្ជាទំហំធំ** (Scale Orders)

ការបញ្ជាទំហំធំ ជាធម្មតាត្រូវបានប្រើប្រាស់ដោយវិនិយោគិនជាស្ថាប័នដើម្បីទិញនៅលើទីផ្សារដែលកំពុងធ្លាក់ថ្លៃខ្លាំង ឬដើម្បីលក់នៅក្នុងទីផ្សារដែលកំពុងឡើងថ្លៃខ្លាំង។ ការបញ្ជានេះជួយឲ្យគេមិនចាប់អារម្មណ៍ទៅលើការជួញដូររបស់ពួកគេ។ វិនិយោគិនអាចបញ្ជាទិញភាគហ៊ុន ATC ចំនួន ៣,000 នៅថ្លៃ ១៤ដុល្លារ និងចំនួន ១,000 នៅរាល់ ១/៤ នៃថ្លៃ ១២ដុល្លារ។ប្រសិនបើវាត្រូវបានប្រតិបត្តិទាំងអស់ មានន័យថាការបញ្ជាសរុបមានចំនួន ១១,000 ភាគហ៊ុនព្រោះការបញ្ជាដំបូងមាន ៣,000 បូក ១,000 ប្រាំបីដងព្រោះរាល់ ១/៤ នៃថ្លៃ១២ រហូត ដល់ថ្លៃ ១៤ មាន ១២, ១២,២៥ ១២,៥០, ១២,៧៥, ១៣, ១៣,២៥, ១៣,៥០, ១៣,៧៥។ ប្រសិនបើមូលបត្រមិនធ្លាក់ថ្លៃដល់ ១៣ដុល្លារ ទេ ការបញ្ជាដែលនៅសល់មិនត្រូវបានប្រតិបត្តិទេ។

ការបញ្ជាទំហំធំត្រូវបានប្រើចំពោះការបញ្ជាដែលមានទឹកប្រាក់ច្រើនសន្ធឹកសន្ធាប់ឬ នៅក្នុងទីផ្សារតូចតាច ដើម្បីកុំឲ្យជះឥទ្ធិពលធ្ងន់ធ្ងរដល់ថ្លៃមូលបត្រ ក៏ដូចជាយុទ្ធសាស្ត្រវិនិយោគមួយរបស់អ្នកជួញដូរដើម្បីបញ្ចៀសការរកឃើញរបស់វិនិយោគិនដ៏ទៃទៀតដែលអាចធ្វើឲ្យប៉ះពាល់ទៅដល់ថ្លៃមូលបត្រ។

## ២.៨. វិធាននៃប្រតិបត្តិការជួញដូរលើទីផ្សារ

### ២.៨.១. ម៉ោងជួញដូរ

| វគ្គជួញដូរ | ម៉ោងបិទ/បើកវគ្គ | ចំនួនជួញដូរ | ម៉ោងជួញដូរ | វិធីសាស្ត្រជួញដូរ |
|---|---|---|---|---|
| វគ្គបើក | ០៨:០០ - ០៩:០០ ព្រឹក | ០១ ដង | ០៩:០០ ព្រឹក | ដេញថ្លៃដោយយកថ្លៃតែមួយ |
| វគ្គជួញដូរនិរន្តន៍ | ០៩:០០ - ១១:០០ ព្រឹក | មិនកំណត់ | ០៩:០០ - ១១:០០ ព្រឹក | ដេញថ្លៃដោយយកថ្លៃច្រើន (មានករណីលើកលែង) |
| វគ្គបិទ | ១១:០០ - ១១:៣០ ព្រឹក | ០១ ដង | ១១:៣០ ព្រឹក | ដេញថ្លៃដោយយកថ្លៃតែមួយ |

តារាងទី១ ៖ ពេលវេលាជួញដូរនៅផ្សារមូលបត្រកម្ពុជា

- ថ្ងៃចន្ទ ដល់ថ្ងៃសុក្រ (លើកលែងថ្ងៃឈប់សម្រាកសាធារណៈ)
- ម៉ោងជួញដូរ ចាប់ផ្តើមពីម៉ោង ៨:០០ ព្រឹក ដល់ម៉ោង ១១:៣០ ព្រឹក
- ការអនុវត្តន៍ការជួញដូរ ឬការផ្គូរផ្គងធ្វើឡើង ០៦ដងក្នុងមួយថ្ងៃគឺ ៖
    - ការផ្គូរផ្គងលើកទី១ នៅម៉ោង ០៩:០០ព្រឹក
    - ផ្គូរផ្គងលើកទី២ នៅម៉ោង ០៩:៣០ព្រឹក
    - ការផ្គូរផ្គងលើកទី៣ នៅម៉ោង ១០:០០ព្រឹក
    - ការផ្គូរផ្គងលើកទី៤ នៅម៉ោង ១០:៣០ព្រឹក
    - ការផ្គូរផ្គងលើកទី៥ នៅម៉ោង ១១:០០ព្រឹក
    - ការផ្គូរផ្គងលើកទី៦ នៅម៉ោង ១១:៣០ព្រឹក
- រូបិយប័ណ្ណ៖ រៀល

### ២.៨.២. ឯកតាបញ្ជា និងឯកតាគម្លាត

- ឯកតាបញ្ជាមូលបត្រកម្មសិទ្ធនៅផ្សារមូលបត្រកម្ពុជាគឺ ០១ (មួយ) ឯកតាមូលបត្រ
- ឯកតាគម្លាតថ្លៃ សម្រាប់ថ្លៃនៃមូលបត្រនីមួយៗ ត្រូវបានកំណត់ដូចខាងក្រោម៖

| ថ្លៃ | ឯកតាគម្លាតថ្លៃ | ឧទាហរណ៍ថ្លៃបញ្ជាខុស | ឧទាហរណ៍ថ្លៃបញ្ជាត្រូវ |
|---|---|---|---|
| ]0-4,000[ | 10 | 2,555; 3,012 | 2,550; 3,010 |
| [4,000-20,000[ | 20 | 4,210; 19,525 | 4,200; 19,520 |
| [20,000-40,000[ | 50 | 20,110; 35,530 | 20,100; 35,550 |
| [40,000-100,000[ | 100 | 50,720; 90,450 | 50,700; 90,400 |
| [100,000-200,000[ | 200 | 150,500; 125,300 | 150,400; 125,400 |
| [200,000-400,000[ | 500 | 300,100; 350,200 | 300,000; 350,500 |
| [400,000-[ | 1,000 | 620,500; 851,100 | 621,000; 852,000 |

តារាងទី២ ៖ ឯកតាគម្លាតថ្លៃ

រាល់តម្លៃនីមួយៗវាមានឯកតាគម្លាតថ្លៃរបស់វា បើយើងក្រឡេកមកមើលតាមតារាងខាងលើ

នៅចន្លោះពី]0-៤,000[ មានឯកតាគម្លាតថ្លៃ ១០ ដែលឧទាហរណ៍ថ្លៃបញ្ជាខុស ២,៥៥៥ ; ៣,០១២ (ចែកមិនដាច់នឹង ឯកតាគម្លាតថ្លៃ១០) និងឧទាហរណ៍ថ្លៃបញ្ជាត្រូវ ២,៥៥០; ៣,០១០ (ចែកដាច់នឹងឯកតាគម្លាតថ្លៃ១០) ។

នៅចន្លោះពី [៤,000-២០,000[ មានឯកតាគម្លាតថ្លៃ ២០ ដែលឧទាហរណ៍ថ្លៃបញ្ជាខុស ៤,២១០ ; ១៩,៥៥២ (ចែកមិនដាច់នឹង ឯកតាគម្លាតថ្លៃ២០) និងឧទាហរណ៍ថ្លៃបញ្ជាត្រូវ ៤,២០០; ១៩,៥២០ (ចែកដាច់នឹងឯកតាគម្លាតថ្លៃ២០) ។

### ២.៨.៣.ការវិភាគលើការអនុបាតភាគហ៊ុន

ការវិភាគលើការអនុបាតជាឧបករណ៍មួយដ៏ពេញនិយមជាងគេក្នុង ការវិភាគរបាយការណ៍ហិរញ្ញវត្ថុ។ ការវិភាគលើអនុបាតភាគហ៊ុនគឺបង្ហាញអំពីទំនាក់ទំនងយ៉ាងសំខាន់ និងជាមូលដ្ឋានក្នុងការប្រៀបធៀបលក្ខខ ណ្ឌមួយដែលពិបាកក្នុងការពិនិត្យលើធាតុនីមួយៗដែលមានសមាមាត្រកើតឡើង។

ដើម្បីបណ្តាក់ទុនលើភាគហ៊ុនឲ្យកាន់តែជោគជ័យ និងទទួលបានប្រាក់ចំណូលច្រើនអ្នកវិនិយោគគួរតែលើអនុបាតភាគហ៊ុននីមួយៗឲ្យកាន់តែច្បាស់។

ដូចនេះហើយទើបយើងលើកយកនូវអនុបាតមួយចំនួនដើម្បីបកស្រាយដូចខាងក្រោមនេះ៖

អនុបាតថ្លៃលើប្រាក់ចំណេញ (Price-Earnings Ratio) គឺជាវិធីសាស្ត្រមួយក្នុងការកំណត់តម្លៃទីផ្សាររបស់ភាគហ៊ុនធម្មតាមួយ។

តម្លៃទីផ្សាររបស់ភាគហ៊ុនធម្មតាត្រូវបានគេកំណត់ដូចខាងក្រោម៖

**Current Price = P/E ratio*Earning per share**

តម្លៃទីផ្សាររបស់ភាគហ៊ុនធម្មតាខ្ពស់ឬទាបអាស្រ័យទៅលើអនុបាត P/E។

ឧទាហរណ៍៖ តាមទិន្នន័យរបស់សាជីវកម្ម Kramer អនុបាត P/E គឺ 15 ដង នោះតម្លៃភាគហ៊ុន គឺ $15 ដែលគេគណនាដូចខាងក្រោម៖

Current Price = P/E*E = 15*$1=$15

ដើម្បីធ្វើការជ្រើសរើសភាគហ៊ុនដែលល្អសម្រាប់ធ្វើការវិនិយោគ អ្នកវិនិយោគត្រូវធ្វើការប្រៀបធៀប ក្រុមហ៊ុនមួយទៅនឹងក្រុមហ៊ុនមួយទៀតដែលស្ថិតនៅក្នុងវិស័យតែមួយ។

ចំពោះអនុបាត P/E Ratio នោះដែរវាមានរូបមន្តដូចខាងក្រោម ៖

**P/E ratio = Price per Share/ Earning Per Share**

អនុបាតនៃថ្លៃភាគហ៊ុន និងការលក់ (Price to Sale Ratio-P/S)

អ្នកវិនិយោគតែងតែរុករកនូវមធ្យោបាយក្នុងការប្រៀបធៀបនូវតម្លៃភាគហ៊ុន ដើម្បីរកឃើញនូវភាគហ៊ុនដែលល្អបំផុតសម្រាប់វិនិយោគ។ អនុបាតនៃថ្លៃភាគហ៊ុនកនិងការលក់ (Price to Sale Ratio-P/S)គឺជាអនុបាតមួយដែលសាមញ្ញដោយយកតម្លៃភាគហ៊ុនក្នុងមួយឯកតាក្នុងពេលបច្ចុប្បន្ន ចែកនឹងចំណូលពីការលក់ក្នុងមួយឯកតា ឬ ត្រូវយកតម្លៃនៃ Market Capitalization ចែកនឹងចំណូលពីការលក់សរុប។

អនុបាតនៃថ្លៃភាគហ៊ុន និងការលក់មានរូបមន្តដូចខាងក្រោម៖

$$\text{P/S Ratio} = \frac{\text{Price Per Share}}{\text{Sale per Share}} = \frac{\text{Market Capitalization}}{\text{Total sale overpast 12 months}}$$

អ្នកវិនិយោគគួរតែយក P/S Ratio របស់ក្រុមហ៊ុនពីរដែលមានស្ថានភាពប្រហាក់ប្រហែលគ្នាយកមកប្រៀបធៀប។ កាលណាក្រុមហ៊ុនណាក្រុមហ៊ុនណាដែលបង្ហាញថាមាន P/S Ratio ទាបគឺជាក្រុមហ៊ុនដែលល្អសម្រាប់ធ្វើការវិនិយោគ។ ហើយក្រុមហ៊ុនដែលមាន P/S Ratio ខ្ពស់ អាចជាស់តឿនថាមិនគួរវិនិយោគឡើយ

ទិន្នផលភាគលាភ (Dividend Yield)

ទិញផលភាគលាភគឺជា អនុបាតហិញ្ញវត្ថុមួយដែលវាស់វែងនូវតម្លៃនៃភាគលាភដែលបែងចែកទៅឲ្យម្ចាស់ភាគហ៊ុន (Common Stock Holder) ដោយធៀបជាមួយនឹងតម្លៃភាគហ៊ុនក្នុងមួយឯកតា។

ទិញផលភាគលាភ គឺត្រូវបានយកទៅប្រើដោយអ្នកវិនិយោគដើម្បីបង្ហាញឲ្យដឹងថាប្រាក់ដែលពួកគេវិនិយោគទៅលើភាគហ៊ុនត្រូវបានបំលែងជាទម្រង់ចរន្តសាច់ប្រាក់ (Cash Flow) ទៅជាភាគលាភ ឬក៏ទុកដើម្បីបង្កើននៃទ្រព្យសកម្ម។

អ្នកវិនិយោគធ្វើការវិនិយោគលុយរបស់ពួកគេទៅលើភាគហ៊ុនគឺរំពឹងចង់ទទួលបាភាគលាភ និងថ្លៃកើនរបស់ភាគហ៊ុន (Stock Appreciation)។ អ្នកវិនិយោគអាចប្រើទិន្នផលភាគលាភ (Dividend Yield) ដើម្បីជួយវិភាគពីប្រាក់ចំណេញដែលទទួលបានពីការវិនិយោគលើស្តុករបស់ពួកគេ។

ទិន្នផលភាគលាភមានរូបមន្តដូចខាងក្រោមៈ

$$\text{Dividend Yield} = \frac{\text{Cash divident Per Share}}{\text{Market value per Share}}$$

ទិន្នផលភាគលាភអាចធ្វើឲ្យអ្នកវិនិយោគដឹងថាតើក្នុង $1 ដែលពួកគេវិនិយោគលើភាគហ៊ុនទទួលបានភាគលាភប៉ុន្មាន។ អ្នកវិនិយោគគួរតែវិនិយោគលើក្រុមហ៊ុនដែលផ្តល់ទិន្នផលភាគលាភខ្ពស់មានន័យថាអ្នកវិនិយោគនឹង ទទួលបាន នូវប្រាក់ចំណេញខ្ពស់ដែលបានមកពីការវិនិយោគរបស់ពួកគេ។

តម្លៃគណនេយ្យក្នុងមួយឯកតា (Book Value)

អនុបាតតម្លៃគណនេយ្យរបស់ក្រុមហ៊ុន គឺជាអនុបាតមួយដែលបង្ហាញ តើពេលបច្ចុប្បន្នតម្លៃទ្រព្យសកម្មរបស់ក្រុមហ៊ុនដែលគេចង់និនិយោគមានតម្លៃប៉ុន្មាន បើប្រៀបធៀបជាមួយនឹងតម្លៃភាគហ៊ុននាពេលបច្ចុប្បន្ន តើវាសមស្របសម្រាប់ធ្វើការវិនិយោគដែរឬទេ។

តម្លៃគណនេយ្យ គឺបានបង្ហាញឲ្យឃើញនូវទ្រព្យសម្បត្តិសរុបរបស់ក្រុមហ៊ុន ដោយយកទ្រព្យសកម្មទាំងអស់របស់ក្រុមហ៊ុន (Total Assets) ដកចេញនូវទ្រព្យអរូបី (Intangible Asset) និងបំណុល (Liabilities) របស់ក្រុមហ៊ុនចេញ។

អ្នកវិនិយោគអាចយកតម្លៃគណនេយ្យ មកប្រើប្រាស់ដើម្បីឲ្យដឹងថាតើក្រុមហ៊ុននោះមានទ្រព្យសម្បត្តិប៉ុន្មានក្រោយពីសងបំណុលឲ្យគេរួចរាល់ហើយ។ ដើម្បីឲ្យកាន់តែច្បាស់ថា អ្នកវិនិយោគនឹងទទួលបានត្រឡប់មកវិញប៉ុន្មាន ប្រសិនបើក្រុមហ៊ុនដែលពួកគេវិនិយោគនោះក្ស័យធន គេអាចប្រើប្រាស់នូវ អនុបាត Price-to-book ratio (P/B ratio) ដោយអនុបាតនោះបានធ្វើការប្រៀបធៀបរវាងតម្លៃនៅក្នុងទីផ្សារ និងតម្លៃគណនេយ្យរបស់ភាគហ៊ុន។

ដោយអនុបាត $\text{P/B Ratio} = \frac{\text{Market Price Per Share}}{\text{Book value per Share}}$

តែ $\text{Book Value per share} = \frac{\text{Total asset} - \text{Total Laiabilities}}{\text{Number of share outstanding}}$

ដោយសារតែ Book Value តំណាងឲ្យតម្លៃពិត (Net Worth) របស់ក្រុមហ៊ុនដូចនេះហើយវាគឺជាឧបករណ៍មួយដែលមានប្រយោជន៍សម្រាប់អ្នកវិនិយោគក្នុងការកំណត់ឲ្យ ដឹងថាតើក្រុមហ៊ុននោះកំពុងតែ លក់ទាបជ្រុល ឬខ្ពស់ជ្រុល ហើយវាបង្ហាញឲ្យអ្នកវិនិយោគដឹងថាតើគួរលក់ ឬទិញភាគហ៊ុននោះ។ ឧទាហរណ៍ អ្នកវិនិយោគភាគច្រើនចង់វិនិយោគលើភាគហ៊ុនដែលនៅស្មើ ឬតិចជាង Book Value (មានន័យថា P/B ratio តូចជាង ឬស្មើ ១) ដែលមានន័យថាក្រុមហ៊ុននោះកំពុងលក់ភាគហ៊ុនក្នុងតម្លៃពិតរបស់ក្រុមហ៊ុន។

## ២.៩. ការឲ្យខ្ចីមូលបត្រ

ការឲ្យខ្ចីមូលបត្រ មិនមែនជាការជួញដូរតាមលក្ខណៈបច្ចេកទេសនោះទេ។ ភាគហ៊ុនអាចត្រូវបានខ្ចីពីវិនិយោគិនផ្សេងជាជាងឈ្មួញជើងសារមូលបត្រ។ កិច្ចព្រមព្រៀងឲ្យខ្ចីត្រូវបានចុះហត្ថលេខាដោយវិនិយោគិន ដែលអនុញ្ញាតឲ្យឈ្មួញជើងសាមូលបត្រខ្ចីភាគហ៊ុនពីគណនីរបស់ខ្លួន ទៅឲ្យវិនិយោគិនផ្សេងទៀតខ្ចីបន្ត។ ការឲ្យខ្ចីមូលបត្រគឺជា វិធីមួយដែលអាចស្វែងរកប្រាក់ចំណេញពីមូលបត្រ ហើយតែងតែធ្វើឡើងដោយវិនិយោគិនជាស្ថាប័នដែលមានភាគហ៊ុនយ៉ាងច្រើនតែមិនសូវធ្វើការជួញដូរ។ ការឲ្យខ្ចីមូលបត្រក៏ផ្តល់ប្រាក់ចំណេញឲ្យទៅឈ្មួញជើងសារមូលបត្រដែរ។ កម្ចីនេះតម្រូវឲ្យដាក់សាច់ប្រាក់ស្មើរនិងថ្លៃទីផ្សារនៃមូលបត្រដែលបានខ្ចី។ កម្ចីនេះត្រូវបានកែតម្រូវជាមួយថ្លៃទីផ្សារ (Marked-to-Market)(តម្លៃនៃកម្ចីត្រូវធៀបទៅនិងតម្លៃនៃភាគហ៊ុននៅលើទីផ្សារ)។ ប្រសិនបើថ្លៃភាគហ៊ុនកើនឡើង អ្នកខ្ចីត្រូវតែដាក់ប្រាក់បន្ថែមឲ្យស្មើរគ្នាវិញ។ ប្រសិនបើថ្លៃភាគហ៊ុនធ្លាក់ចុះវិញ សាច់ប្រាក់និងត្រូវដកយកទៅដាក់នៅក្នុងគណនីអ្នកខ្ចីវិញ។ សាច់ប្រាក់នេះបង្ហាញថាវាជាកម្ចីដែលមានការប្រាក់សម្រាប់ឈ្មួញជើងសារមូលបត្រដែលវិនិយោគលើមូលបត្ររយៈពេលខ្លីក្នុងរយៈពេលនៃកម្ចី។

វិនិយោគមិនត្រូវបានគិតការប្រាក់លើកម្ចីនេះទេ ហើយវិនិយោគិនក៏មិនទទួលបានចំណេញពីការវិនិយោគរយៈពេលខ្លីនេះដែរ។ ឈ្មួញជើងសារមូលបត្រជាអ្នកទទួលបានប្រាក់ចំណេញ។ វិនិយោគិនដែលជាស្ថាប័នធំៗដែលយល់ច្បាស់ពីកិច្ចព្រមព្រៀងនេះ ចាប់ផ្តើមស្នើរសុំឲ្យមានការបែងចែកប្រាក់ចំណេញនេះជាមួយឈ្មួញជើងសារមូលបត្រតាមរយៈ ការចរចាឬការព្រមព្រៀងបែបណាមួយ។ភាគលាភសម្រាប់ភាគហ៊ុនថ្មីដែលបានខ្ចីត្រូវបានគិតទៅឲ្យអ្នកខ្ចីយកទៅលក់បន្ទាប់មកផ្ទេរទៅឲ្យម្ចាស់ដើមវិញគឺអ្នកដែលបានឲ្យខ្ចី។

អ្នកឲ្យខ្ចីអាចទាមទារយកសិទ្ធក្នុងការបោះឆ្នោតរបស់មូលបត្រដែលបានឲ្យខ្ចី។ ប្រសិនបើវាកើតឡើង ដោយយោងទៅតាមទ្រឹស្តី ឈ្មួញជើងសារមូលបត្រត្រូវបានទាមទារសិទ្ធិក្នុងការបោះឆ្នោត ឬផ្តល់សិទ្ធប្រទាន (Proxy) ក្នុងការបោះឆ្នោត។ សិទ្ធិប្រទាន (Proxy) គឺជា ឯកសារមួយដែលផ្តល់សិទ្ធិឲ្យអ្នកដែលកាន់កាប់ឯកសារនេះបោះឆ្នោតក្នុងនាមជាម្ចាស់កម្មសិទ្ធិ លើមូលបត្រនោះ។

## ២.១០. ការផាត់ទាត់ និងការទូទាត់

### ២.១០.១. ការផាត់ទាត់

ការផាត់ទាត់ គឺជាដំណើរការនៃការប្រៀបធៀប (Comparing) ការជួញដូរមុនពេលទូទាត់ (Settlement)។ នៅពេលដែលការជួញដូរចប់សព្វគ្រប់នៅលើទីផ្សារមូលបត្រ ឬទីផ្សាររំលងបញ្ជរ (OTC) ព័ត៌មានលម្អិតនៃការជួញដូរនឹងត្រូវបានរាយការណ៍ទៅផ្នែកទិញ-លក់នៃ ឈ្មួញជើងសាមូលបត្រ (សម្រាប់ទិញ-លក់)។ ជាទូទៅផ្នែកនៃក្រុមហ៊ុនមូលបត្រនិមួយៗ នឹងប្រៀបធៀប ឬផ្ទៀងផ្ទាត់ការបញ្ជាដោយកុំព្យូទ័រ។ ក្រោយពេលការផ្ទៀងផ្ទាត់ត្រូវបានបញ្ជាក់ (confirmed) ឈ្មួញជើងសាមូលបត្រនិមួយៗ នឹងប្រៀបធៀប ឬផ្ទៀងផ្ទាត់ត្រូវចេញលិខិតបញ្ជាក់ក៏បានបង្ហាញពីកាលបរិច្ឆេទទូទាត់ និងបរិមាណទឹកប្រាក់ដែលត្រូវទូទាត់ទៅកាន់វិនិយោគិន (ចំពោះការលក់)។ ឬឈ្មួញជើងសារមូលបត្រ (ចំពោះការទិញ)។ ការខកខានមិនបានទទួលលិខិតបញ្ជាក់ទាន់ពេល ដើម្បីធ្វើការទូទាត់នៅការបរិច្ឆេទកំណត់មួយមិនអាចយកធ្វើជាហេតុផលក្នុងការខកខានមិនអាចទូទាត់នៅ ការបរិច្ឆេទកំណត់នោះឡើយ។ លើពីនេះទៅទៀត ចំពោះការបញ្ជាតាមទីផ្សារ (Market Orders) ឬការបញ្ជាភ្លាមៗផ្សេងទៀតដែលមិនលក្ខណៈស្មុគស្មាញ (Immediate Non-complication Orders) ឈ្មួញជើងសារមូលបត្រអាចបញ្ជាក់ការប្រតិបត្តិ (Execution) នៃការជួញដូរពេលដែលវិនិយោគិនកំពុងនិយាយទូរស័ព្ទ ឬកំពុង Online ជាមួយភ្លែមៗ ឬឈ្មួញជើងសាមូលបត្រអាចទូរស័ព្ទត្រឡប់ទៅវិញ ដើម្បីបញ្ជាក់ក្រោយពេលការបញ្ជាត្រូវបានប្រតិបត្តិក៏បាន។

មានតែសមតុល្យសរុបប៉ុណ្ណោះត្រូវបានបញ្ជូន ឬទទួលរវាង ឈ្មួញជើងសាមូលបត្រនៅចុងបញ្ចប់នៃថ្ងៃជួញដូរ។ ដូចនេះបរិមាណទិញ លក់មូលបត្រសរុបនឹងត្រូវបានដកចេញពីគ្នា ហើយសមតុល្យទឹកប្រាក់ដែលត្រូវទទួលបាន ឬជំពាក់នឹងត្រូវបានកាត់កង (Netted)។ ដំណើរការនៃការកាត់កងនេះ ត្រូវបានហៅថា ការផាត់ទាត់ (Clearing)។ ឧទាហរណ៍៖ បើគ្មានប្រព័ន្ធផាត់ទាត់ នៅពេលឈ្មួញជើងសាមូលបត្រតំណាងឲ្យអ្នកលក់ បញ្ជូនមូលបត្រទៅឲ្យឈ្មួញជើងសាមូលបត្រ តំណាងឲ្យអ្នកទិញ អ្នកបញ្ជូនមូលបត្រនឹងទាមទារការទូទាត់ជាសាច់ប្រាក់ភ្លែមៗ ព្រោះកម្មសិទ្ធិនៃមូលបត្រត្រូវបានផ្ទេរនៅពេលបញ្ជូន ចែក

ចាយមូលបត្រ (Deliver)។ ក្នុងករណីឈ្មួញជើងសាមូលបត្រដែលមានការជួញដូររាប់សិបពាន់ប្រតិបត្តិការក្នុងមួយថ្ងៃ នោះប្រហែលជាត្រូវទាមទារឲ្យមានឯកសារ ទឹកប្រាក់ និងអ្នកបញ្ជូនមូលបត្រគរដូចភ្នំហើយ បើឈ្មួញជើងសាមូលបត្រទាំងនោះស្ថិតនៅពីគ្នាទៀត តើវាទៅជាយ៉ាងណា? វាប្រាកដមិនអាចធ្វើទៅរួចទេចំពោះទីតាំងឆ្ងាយពីគ្នា និងឆ្លងប្រទេសនោះ។

ដូចច្នេះហើយទើបគេបង្កើតប្រព័ន្ធផាត់ទាត់នេះឡើងដែលធ្វើប្រតិបត្តិការ (Operated) ដោយប្រតិបត្តិករផាត់ទាត់ (Clearing Houses)។ បទប្បញ្ញត្តិស្តីពីការផាត់ទាត់ និងប្រតិបត្តិករផាត់ទាត់មានលក្ខណៈខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ ទាំងការចុះបញ្ជី និងប្រតិបត្តិករផាត់ទាត់។ ឧទាហរណ៍៖ ប្រទេសហ្វីលីពីន មានប្រតិបត្តិករផាត់ទាត់កណ្តាល (Central Clearing House) ចំនួនពីរ ដែលប្រតិបត្តិករមួយសម្រាប់ផាត់ទាត់មូលបត្រ និងប្រតិបត្តិមួយទៀតផាត់ទាត់សាច់ប្រាក់។ ប្រទេសភាគច្រើនមានប្រតិបត្តិករតែមួយទេ ដែលធ្វើប្រតិបត្តិការផាត់ទាត់ទាំងមូលបត្រនិងទាំងសាច់ប្រាក់។ ទោះបីជាយ៉ាងណាក៏ដោយ វាមានសុវត្ថិភាព ប្រសិនបើច្បាប់ទាំងអស់តម្រូវឲ្យប្រតិបត្តិករផាត់ទាត់ត្រូវចុះបញ្ជី ហើយត្រូវមានមូលធនដែលត្រូវបង់ (Paid-in Capital)។ ច្បាប់របស់ប្រទេសចិនបានចែងថា ប្រតិបត្តិករផាត់ទាត់ត្រូវតែជាអង្គភាពមិនស្វែងរកប្រាក់ទៅក្នុងមូលនិធិផាត់ទាត់ (Clearing Fund) ដើម្បីកាត់បន្ថយហានិភ័យនៃភាពមិនអាចទូទាត់ (Default Risk) របស់សមាជិក (ករណីនៅក្នុងប្រទេសមួយចំនួន)។

**២.១០.២. ការទូទាត់**

ការទូទាត់គឺជា ដំណាក់កាលចុងបញ្ចប់នៃជួញដូរ ដោយមូលបត្រ ឬមូលនិធិ ឬទឹកប្រាក់ ត្រូវបានបញ្ជូនរួច។ កាលបរិច្ឆេទទូទាត់ គឺជាដំណាក់កាលដែលមូលបត្រដែលបានលក់ត្រូវតែបញ្ជូន ឬមូលបត្រដែលបានទិញត្រូវបានបង់ប្រាក់រួចរាល់។ ការបញ្ជូន គឺជាការបំពេញឲ្យការជួញដូរ ឬប្រតិបត្តិការចប់សព្វគ្រប់ដោយមិនចាំបាច់ទាល់តែឃើញមូលបត្រ ឬក៏សាច់ប្រាក់ត្រូវបានបញ្ជូនដោយជាក់ស្តែងឡើយ។ ការបញ្ជូនសម្តៅលើការគណនាសមតុល្យដោយការធ្វើឥណទានកម្ម(បូកបន្ថែម) ឬការធ្វើឥណពន្ធកម្ម (ដកចេញ) ពីគណនី។

ការលក់មូលបត្រដែលបានចុះបញ្ជីចប់សព្វគ្រប់នៅកាលបរិច្ឆេទទូទាត់ ដោយធ្វើការផ្ទេរសិទ្ធលើមូលបត្រពីអ្នកលក់ទៅ អ្នកទិញនៅពេលបង់ប្រាក់។ ចន្លោះពេលរវាងកាលបរិច្ឆេទជួញដូរ និងកាលបរិច្ឆេទត្រូវបានកំណត់ដោយច្បាប់ និងបទប្បញ្ញត្តិនៅក្នុងប្រទេសនីមួយៗ ហើយអាស្រ័យទៅលើបច្ចេកវិទ្យា និងទំហំនៃមូលបត្រដែលបានជួញដូរ។ ការទូទាត់តែងត្រូវបានធ្វើឡើងនៅចន្លោះពី៣ទៅ៥ថ្ងៃបន្ទាប់ពីថ្ងៃជួញដូរ (T+3ឬT+5)។ គេជឿថា ចន្លោះពេលរវាងការបរិច្ឆេទជួញដូរ និងកាលទូទាត់កាន់តែខ្លី មានន័យថា

ទីផ្សារនោះកាន់តែមានកម្រិតសន្ទនីយភាពខ្ពស់ និងកម្រិតហានិភ័យទាប ហេតុនេះទើបគោលដៅរបស់សមាគមន៍វិនិយោគអន្តរជាតិ គឺចង់ប្តូរទៅ T+1 សម្រាប់ការទូទាត់គ្រប់ ប្រតិបត្តិការជួញដូរទាំងអស់។

កាលបរិច្ឆេទទូទាត់ ជាធម្មតាតំណាងដោយ T+រយៈពេលរងចាំការទូទាត់។ ដូចនេះការទូទាត់នៅរយៈពេល៣ថ្ងៃក្រោយថ្ងៃជួញដូរត្រូវបានតំណាងដោយ T+3 ដោយ "T"មានន័យថាTrade Day"ថ្ងៃជួញដូរ"។ កាលបរិច្ឆេទនេះ សម្តៅតែទៅលើថ្ងៃដែលទីផ្សារបើឲ្យធ្វើអាជីវកម្មតែប៉ុណ្ណោះ។ ប្រសិនបើមានថ្ងៃឈប់សម្រាកនៅចន្លោះថ្ងៃជួញដូរនិងថ្ងៃទូទាត់នោះមានតែថ្ងៃដែលទីផ្សារបើកទេដែលត្រូវបានរាប់បញ្ចូល។ ដូច្នេះ ប្រសិនបើការជួញដូរកើតឡើងនៅថ្ងៃចន្ទ័ ហើយកាលបរិច្ឆេទទូទាត់គឺT+4 មានន័យថាការបរិច្ឆេទទូទាត់គឺនៅថ្ងៃសុក្រ។ តែប្រសិនបើមានថ្ងៃឈប់សម្រាកមួយថ្ងៃចន្លោះពេលនោះ ហើយទីផ្សារត្រូវបិទកាលបរិច្ឆេទដែលត្រូវទូទាត់ពិតប្រាកដគឺធ្វើឡើងនៅថ្ងៃចន្ទ័ក្រោយ។ កាលបរិច្ឆេទជួញដូរកើតឡើងនៅថ្ងៃចន្ទ័ ប៉ុន្តែដោយសារមានថ្ងៃឈប់សម្រាក នាំឲ្យកាលបរិច្ឆេទទូទាត់នៅ T+4 ត្រូវរំកិលឬទៅថ្ងៃសៅរ៍ តែដោយទីផ្សារត្រូវបិទនៅថ្ងៃសៅរ៍និង ថ្ងៃអាទិត្យ ដូច្នេះនៅថ្ងៃបន្ទាប់ដែលទីផ្សារបើកគឺនៅថ្ងៃចន្ទ័ក្រោយ។

នីតិវិធីនៃការទូទាត់ ត្រូវបានកំណត់ដោយច្បាប់ និងមានភាពខុសគ្នាទៅតាមប្រទេសនីមួយៗ។ ឧទាហរណ៍៖ នៅក្នុងប្រទេសភីលីពីន ប្រសិនបើមូលបត្រមិនបានបញ្ជូន(ចំពោះការលក់) ឬទឹកប្រាក់មិនត្រូវបានបង់(ចំពោះការទិញ) នៅថ្ងៃទូទាត់ទេ ឈ្មួញជើងសាមូលបត្រ និងត្រូវទទួលខុសត្រូវក្នុងការជួញដូរនេះ ហើយត្រូវទារពីអតិថិជនវិញ។ អតិថិជនដែលមិនបានទូទាត់ការជួញដូររបស់ពួកគេនៅកាលបរិច្ឆេទកំណត់ កម្រនិងរកបានឈ្មួញជើងសារមូលបត្រដើម្បីធ្វើប្រតិបត្តិការជួញដូរឲ្យគេណាស់ ហើយព័ត៌មានប្រភេទនេះផ្សព្វផ្សាយយ៉ាងលឿនពីក្រុមហ៊ុនមួយទៅក្រុមហ៊ុនមួយ។ ប្រទេសម៉ាឡេស៊ីមានបញ្ជីឈ្មោះអ្នកមិនទូទាត់ការជួញដូរ ដែលរក្សាទុកដោយឈ្មួញជើងសារមូលបត្រ។ នៅក្នុងប្រទេសខ្លះមានការហាមឃាត់គណនីដែលមិនបានទូទាត់តាមពេលវេលា មិនឲ្យជួញដូរបានក្នុងរយៈពេលកំណត់មួយ។ ការកំណត់នេះត្រូវបានដាក់ដោយឈ្មួញជើងសាមូលបត្រ ទីផ្សារមូលបត្រ ឬទីផ្សារក្រៅផ្លូវការ ឬដោយច្បាប់។

បណ្តាប្រទេសដែលនៅតែបោះពុម្ពជាសន្លឹកមូលបត្រ អ្នកទិញមូលបត្រមានជម្រើសក្នុងការទទួលយកសន្លឹកមូលបត្រដោយទុកមូលបត្រនៅជាមួយឈ្មួញជើងសារដោយដាក់ឈ្មោះខ្លួនឯង ឬមួយទុកមូលបត្រនៅជាមួយឈ្មួញជើងសារមូលបត្រដោយដាក់ឈ្មោះក្រុមហ៊ុនឈ្មួញជើងសារមូលបត្រ។ ប្រសិនបើបុគ្គលម្នាក់ជួញដូរជាញឹកញាប់ ឬមិនចង់ទទួលខុសត្រូវលើការរក្សាទុកមូលបត្រដោយខ្លួនឯង ការទទួលយកជាសន្លឹកមូលបត្រ មិនមែនជាជម្រើសល្អទេ។ ក្រៅពីអាចបាត់ ឬក៏ត្រូវចំណាយលើថ្លៃសេវាដើម្បីរក្សាទុកមូលបត្រ អ្នកជួញដូរនិងត្រូវរវល់ ជាមួយការបញ្ជូន និងទទួលមូលបត្រចុះឡើងនៅឯឈ្មួញជើងសារ

មូលបត្រ។ ប្រសិនបើអ្នកទិញចង់ធ្វើដូច្នេះ ឈ្មួញជើងសារមូលបត្រនិង កត់ត្រាមូលបត្រនៅក្នុងសៀវភៅរបស់ក្រុមហ៊ុនដោយដាក់ឈ្មោះ ឈ្មួញជើងសារមូលបត្រ ហើយបញ្ជូនមូលបត្រនោះទៅក្នុងគណនីរបស់អ្នកទិញ នៅក្នុងកំណត់ត្រារបស់វា។ អ្នកទិញអាចមានបំណងធ្វើដូចច្នេះដោយសារមូលហេតុជាច្រើនដូចជាមានភាពងាយស្រួលក្នុងការជួញដូរ និងការប្រើឈ្មោះអនាមិក។ ទម្រង់នៃភាពជាកម្មសិទ្ធដូចនេះសម្រួលនូវការជួញដូរដោយសារ មូលហេតុដែលបានចុះបញ្ជីសោយដាក់ឈ្មោះអ្នកទិញ ទោះបីជានៅទីណាក៏ដោយ ត្រូវតែការខ្ចង(Endorsed) នៅពេលលក់ ដូចនេះឈ្មួញជើងសារមូលបត្រ និងកាន់កាប់មូលបត្ររបស់អតិថិជនកាន់តែច្រើនឡើង ដោយប្រើឈ្មោះឈ្មួញជើងសារមូលបត្រ ហើយប្រទេសជាច្រើនដែលនៅប្រើសន្លឹកមូលបត្រ ក៏កំពុងតែព្យាយាមធ្វើការលុបបំបាត់នេះដែរ។

ការជួញដូរត្រូវបានទូទាត់ដោយប្តូរឈ្មោះអ្នកលក់ចេញពីសៀវភៅ និងកំណត់ត្រារបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ជំនួសដោយឈ្មោះរបស់អ្នកទិញដែលជាកម្មសិទ្ធករថ្មី។ ប្រសិនបើអ្នកទិញចង់បានវិញ្ញាបនបត្រ វិញ្ញាបនបត្រថ្មីនិងត្រូវបោះពុម្ពឡើងដោយដាក់ឈ្មោះរបស់អ្នកទិញ។ នេះគឺជាប្រតិបត្តិការរក្សាកំណត់ត្រាដែលគេឲ្យឈ្មោះថា ការចុះបញ្ជីក្នុងសៀវភៅ ព្រោះភស្តុតាងតែមួយគត់ដែលបង្ហាញពីកម្មសិទ្ធករគឺការចុះបញ្ជីកម្មសិទ្ធករថ្មីទៅក្នុងសៀវភៅកំណត់ត្រារបស់ក្រុមហ៊ុន បោះផ្សាយលក់មូលបត្រហើយសន្លឹកវិញ្ញាបនបត្រមិនត្រូវបានបោះផ្សាយនោះទេ។

## ២.១១. ប្រតិបត្តិការរក្សារទុកមូលបត្រ

យើងធ្លាប់បាននិយាយថា ឈ្មួញជើងសាមូលបត្រអាចកាន់កាប់មូលបត្រដោយដាក់ឈ្មោះអតិថិជន ឬឈ្មោះរបស់ក្រុមហ៊ុនផ្ទាល់។ ប៉ុន្តែ ឈ្មួញជើងសារមូលបត្រ ជាធម្មតាមិនរក្សាទុកមូលបត្រទាំងនេះក្នុងក្រុមហ៊ុនឡើយ គឺពួកគេជួលសេវា ឬប្រតិបត្តិការរក្សាទុកមូលបត្រដើម្បីរក្សាទុកមូលបត្រទាំងនោះវិញ។

ប្រតិបត្តិការរក្សាទុកមូលបត្រកណ្តាល (Center Depositary) គឺជាទីកន្លែង ឬប្រព័ន្ធរក្សាទុករក្សាសុវត្ថិភាព និងផ្ទៀងផ្ទាត់គណនីសមាជិក (Reconciliation of Members Accounts) ។ ប្រសិនបើវិញ្ញាបនបត្រ ឬកំណត់ត្រា (Script) ត្រូវបានប្រើ។ ប្រតិបត្តិកររក្សាទុកមូលបត្រកណ្តាល រក្សាទុកមូលបត្រដែលខ្លួនកាន់កាប់នៅក្នុងឈ្មោះរួម (Street Name) ហើយមិនបញ្ជូនទៅអតិថិជនជាសន្លឹកមូលបត្រទេ។ ប្រសិនបើមូលបត្រត្រូវបានបោះពុម្ព ហើយកត់ត្រាទុកនៅក្នុងសៀវភៅ (Book Entry) ប្រតិបត្តិកររក្សាទុកមូលបត្រកណ្តាល គឺជាប្រព័ន្ធកំព្យូទ័រដែលរក្សាទុករាល់គណនាសមតុល្យ (Track of Balance) ក្នុងគណនីនីមួយៗរបស់ក្រុមហ៊ុនដែលជាសមាជិក។ នៅពេលភ្នាក់ងារផាត់ទាត់ ធ្វើការផាត់ទាត់ការជួញដូរ

ហើយគណនាសមតុល្យរបស់គណនីក្រុមហ៊ុនដែលជាសមាជិកនៅចុងបញ្ចប់នៃថ្ងៃជួញដូរ មូលបត្រត្រូវតែបានបញ្ជូនរួចរាល់ ដូចនេះគណនីទាំងអស់ត្រូវមានសមតុល្យ។ ដូច្នេះនៅចុងបញ្ចប់នៃថ្ងៃជួញដូរ ភ្នាក់ងារផាត់ទាត់និងជូនដំណឹងទៅកាប់ប្រតិបត្តិកររក្សាទុកមូលបត្រកណ្តាល អំពីការប្រែប្រួលសមតុល្យគណនីរបស់សមាជិក ហើយប្រតិបត្តិកររក្សាទុកមូលបត្រកណ្តាលកែតម្រូវកំណត់ត្រាសមតុល្យគណនីរបស់ពួកគេទៅតាមនោះ។ គណនីរបស់សមាជិកដែលជាក្រុមហ៊ុនមូលបត្រត្រូវបានកែតម្រូវស្របទៅតាម ការជួញដូរប្រចាំថ្ងៃ ហើយគ្មាននរណាម្នាក់បានប៉ះពាល់វិញ្ញាបនបត្រដោយផ្ទាល់ឡើយ។ ដំណើរការទាំងមូលនៃការបញ្ជូនវិញ្ញាបនបត្រត្រូវធ្វើឡើងតាមរយៈ ការធ្វើសមតុល្យដោយគណនីអេឡិចត្រូនិក។ ក្រុមហ៊ុនឈ្មួញជើងសារមូលបត្រ ភ្នាក់ងារផាត់ទាត់មូលបត្រមិនទទួល ឬបញ្ជូនវិញ្ញាបនបត្រសូម្បីតែមួយសន្លឹក ហើយប្រតិបត្តិកររក្សាទុកមូលបត្រកណ្តាលក៏មិនទទួល ឬបញ្ជូនវិញ្ញាបនបត្រសូម្បីតែមួយសន្លឹកដែរ។ ប៉ុន្តែរាល់ការជួញដូរប្រចាំថ្ងៃទាំងអស់ត្រូវបានផាត់ទាត់ កត់ត្រា និងធ្វើសមតុល្យ គ្រប់ពេលវេលានៃការជួញដូរទាំងអស់។

ជាប្រពៃណី មានតែសមាជិកដែលជាឈ្មួញជើងសារមូលបត្រ ឬពាណិជ្ជករមូលបត្រប៉ុណ្ណោះដែលអនុញ្ញាតិឲ្យបើកគណនី នៅក្នុងប្រតិបត្តិកររក្សាទុកមូលបត្រកណ្តាល។ ដោយការប្រើប្រាស់កំណត់ត្រា (Scripts) បានបាត់ពីដំណើរការ វិនិយោគិនជាបុគ្គលត្រូវតែបើកគណនី ឬគណនីរង (Sub-account) នៅក្នុងប្រតិបត្តិកររក្សារទុកមូលបត្រកណ្តាលដែរ។

តាមការរំពឹងទុក បទបញ្ញត្តិជាក់ស្តែងទាក់ទងនិងការចុះបញ្ជី(Registration) ការផ្តល់អាជ្ញាបណ្ណ (Licensing) លក្ខខណ្ឌតម្រូវមូលធន (Capital Requirements) វិធានប្រតិបត្តិការ វិធានសមាជិក ។ល។ នៃប្រតិបត្តិកររក្សាទុកមូលបត្រកណ្តាលនិងត្រូវបានកំណត់ដោយច្បាប់នៃប្រទេសនីមួយៗ ហើយអាចនិងមានភាពខុសគ្នាពីប្រទេសមួយទៅប្រទេសមួយដែរ។

# ជំពូកទី៣

# ទំនាក់ទំនងរវាងទីផ្សារមូលបត្រ និងកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ

## ៣.១. ក្រុមហ៊ុនដែលចុះបញ្ជីលក់មូលបត្រ

ក្រុមហ៊ុនដែលបានចុះបញ្ជីលក់មូលបត្រមានដូចជា៖

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (PWSA)

- មូលបត្រដែលដាក់លក់៖ ភាគហ៊ុនធម្មតា
- ចំនួនភាគហ៊ុនចុះបញ្ជី៖ ៨៦,៩៧៣,១៦២ ភាគហ៊ុន
- ថ្លៃIPO ៖ ៦,៣០០ រៀល

ហ្គ្រេនធ្វីន អ៊ីនធើណេសិនណល (ខេមបូឌា)ភីអិលស៊ី (GTI)

- មូលបត្រដែលដាក់លក់៖ ភាគហ៊ុនធម្មតា
- ចំនួនភាគហ៊ុនចុះបញ្ជី៖ ៤០,០០០,០០០ ភាគហ៊ុន
- ថ្លៃIPO ៖ ៩,៦៤០ រៀល

កំពង់ផែស្វយ័តភ្នំពេញ (PPAP)

- មូលបត្រដែលដាក់លក់៖ ភាគហ៊ុនមានសិទ្ធបោះឆ្នោត
- ចំនួនភាគហ៊ុនចុះបញ្ជី៖ ២០,៦៨៤,៣៦៥ ភាគហ៊ុន
- ថ្លៃIPO ៖ ៥,១២០ រៀល

ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី (PPSP)

- មូលបត្រដែលដាក់លក់៖ ភាគហ៊ុនមានសិទ្ធបោះឆ្នោត
- ចំនួនភាគហ៊ុនចុះបញ្ជី៖ ៥៧,៨៧៥,០០០ ភាគហ៊ុន
- ថ្លៃIPO ៖ ២,៨៦០ រៀល

កំពង់ផែស្វយ័តក្រុងព្រះសីហនុ (PAS)

- មូលបត្រដែលដាក់លក់៖ ភាគហ៊ុនមានសិទ្ធបោះឆ្នោត
- ចំនួនភាគហ៊ុនចុះបញ្ជី៖ ៨៥,៧៧១,៩៦៧ ភាគហ៊ុន
- ថ្លៃIPO ៖ ៥,០៤០ រៀល

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីធីត

- មូលបត្រដែលដាក់លក់៖ មូលបត្របំណុល

- ចំនួនភាគហ៊ុនចុះបញ្ជី៖ ១,២០០,០០០ ភាគហ៊ុន
- ថ្លៃIPO ៖ ១០០,០០០ រៀល

ក្រុមហ៊ុន អិលអូអិលស៊ី

- មូលបត្រដែលដាក់លក់៖ មូលបត្របំណុល
- ចំនួនភាគហ៊ុនចុះបញ្ជី៖ ៥៣៦,០០០ ភាគហ៊ុន
- ថ្លៃIPO ៖ ១០០,០០០ រៀល

ធនាគារ អេប៊ីអេ (ABA)

- មូលបត្រដែលដាក់លក់៖ មូលបត្របំណុល
- ចំនួនភាគហ៊ុនចុះបញ្ជី៖ ៨៤៨,២១០ ភាគហ៊ុន
- ថ្លៃIPO ៖ ១០០,០០០ រៀល

## ៣.២. សកម្មភាពជួញដូរភាគហ៊ុនរបស់ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រកម្មសិទ្ធ[7]

### ៣.២.១. ភាគហ៊ុនរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

| ទិដ្ឋភាពទូទៅ (PWSA) | ត្រីមាសទី ៤ ឆ្នាំ២០១៩ | ត្រីមាសទី ១ ឆ្នាំ២០២០ | បម្រែបម្រួល |
|---|---|---|---|
| មូលធនូបនីយកម្មទីផ្សារ (លានរៀល) | 521,839 | 518,360 | -1% |
| មូលធនូបនីយកម្មទីផ្សារ (លានដុល្លារអាមេរិក) | 130.46 | 129.59 | |
| ទំហំជួញដូរ (ភាគហ៊ុន) | 251,530 | 176,117 | -30% |
| ទំហំជួញដូរជាមធ្យមប្រចាំថ្ងៃ (ភាគហ៊ុន) | 4,263 | 2,841 | |
| តម្លៃជួញដូរ (លានរៀល) | 1,509.90 | 1,051.83 | -30% |
| តម្លៃជួញដូរ (ដុល្លារអាមេរិក) | 377,474.57 | 262,958.24 | |
| តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ (លានរៀល) | 25.59 | 16.97 | -34% |
| តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ (ដុល្លារអាមេរិក) | 6,397.87 | 4,241.26 | |

តារាងទី៣៖ ទិភាពទូទៅនៃការជួញដូរភាគហ៊ុន PWSA

[7] គណៈកម្មការមូលបត្រកម្ពុជា,ព្រឹត្តិបត្រទិន្នន័យជួញដូរមូលបត្រ

ក្នុងត្រីមាសទី០១ ឆ្នាំ២០២០ ថ្លៃបិទរបស់ភាគហ៊ុន PWSA ប្រែប្រួលក្នុងចន្លោះពី ៥,៩០០រៀល ដល់៦,១២០រៀល។ ចំពោះការជួញដូរមានថយចុះ បើធៀបជាមួយត្រីមាសទី០៤ឆ្នាំ២០១៩ ដោយទំហំជួញដូរថយចុះពី២៥១,៥៣០ភាគហ៊ុន នៅក្នុងត្រីមាសទី០៤ឆ្នាំ២០១៩ នៅត្រឹម១៧៦,១១៧ភាគហ៊ុននៅក្នុងត្រីមាសទី០១ឆ្នាំ២០២០។ តម្លៃជួញដូរសរុបសម្រាប់ភាគហ៊ុន PWSAនៅក្នុងត្រីមាសទី០១ឆ្នាំ២០២០ មានតម្លៃប្រហែល១,០៥២ លានរៀល (ប្រហែល២៦២,៩៦ពាន់ដុល្លារសហរដ្ឋអាមេរិច)។




ក្រាហ្វិចទី១ ៖ថ្លៃភាគហ៊ុនធៀបនឹងទំហំជួញដូររបស់ភាគហ៊ុន PWSA

បរិមាណបញ្ជាលក់ភាគហ៊ុន PWSA សរុបដែលដាក់បញ្ជាដោយវិនិយោគិនជនជាតិខ្មែរមានចំនួន ៤៩% និងបញ្ជាលក់ធ្វើឡើងដោយវិនិយោគិនបរទេសមានចំនួន ៥១% នៃបរិមាណដាក់លក់សរុប។ ក្នុងនោះដែរ បរិមាណបញ្ជាលក់ភាគហ៊ុន PWSA សរុបដែលបានធ្វើឡើងដោយវិនិយោគិនរូបវន្តបុគ្គលមានចំនួន ៧០,៦% វិនិយោគិននីតិបុគ្គលមានចំនួន ២៥,៩% និងក្រុមហ៊ុនមូលបត្រមានចំនួន ៣,៥%។

ចំពោះបរិមាណបញ្ជាទិញភាគហ៊ុន PWSA សរុបដែលបានដាក់បញ្ជាដោយវិនិយោគិនជនជាតិខ្មែរមានចំនួន ៦២% និបញ្ជាទិញធ្វើឡើងដោយវិនិយោគិនបរទេសមានចំនួន៣៨% នៃបរិមាណដាក់បញ្ជាទិញសរុប។ ក្នុងនោះដែរ បរិមាណទិញភាគហ៊ុន PWSA សរុបដែលធ្វើឡើងដោយវិនិយោគិនរូបវន្តបុគ្គលមានចំនួន ៩៩,៧៨% ក្រុមហ៊ុនមូលបត្រមានចំនួន ០,២២% និងពុំមានការចូលរួមពីវិនិយោគិននីតិបុគ្គលទេ។




ក្រាហ្វិចទី២ ៖បញ្ជាទិញ នឹងលក់ភាគហ៊ុន PWSA តាមប្រភេទវិនិយោគិន

## ៣.២.២. ភាគហ៊ុនរបស់ក្រុមហ៊ុន ហ្គ្រេនធ្វីនអ៊ីនធើនេសិនណាល[8]

| ទិដ្ឋភាពទូទៅ (GTI) | ត្រីមាសទី ៤ ឆ្នាំ២០១៩ | ត្រីមាសទី ១ ឆ្នាំ២០២០ | បម្រែបម្រួល |
|---|---|---|---|
| មូលធនូបនីយកម្មទីផ្សារ (លានរៀល) | 176,000 | 142,800 | -19% |
| មូលធនូបនីយកម្មទីផ្សារ (លានដុល្លារអាមេរិក) | 44.00 | 35.70 | |
| ទំហំជួញដូរ (ភាគហ៊ុន) | 45,174 | 37,938 | -16% |
| ទំហំជួញដូរជាមធ្យមប្រចាំថ្ងៃ (ភាគហ៊ុន) | 766 | 612 | |
| តម្លៃជួញដូរ (លានរៀល) | 198.78 | 153.57 | -23% |
| តម្លៃជួញដូរ (ដុល្លារអាមេរិក) | 49,694 | 38,393 | |
| តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ (លានរៀល) | 3.37 | 2.48 | -26% |
| តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ (ដុល្លារអាមេរិក) | 842.27 | 619.25 | |

តារាងទី៤ ៖ ទិដ្ឋភាពទូទៅនៃការជួញដូរភាគហ៊ុន GTI

[8]គណៈកម្មការមូលបត្រកម្ពុជា,ព្រឹត្តិបត្រទិន្នន័យជួញដូរមូលបត្រ

ក្នុងត្រីមាសទី០១ ឆ្នាំ២០២០ ថ្លៃបិទភាគហ៊ុន GTI ប្រែប្រួលក្នុងចន្លោះពី ៣,៩៧០រៀល ដល់ ៤,៦០០រៀល ក្នុងមួយភាគហ៊ុន។ ចំណែកឯសកម្មភាពជួញដូរថយចុះបន្តិច ប្រៀបធៀបជាមួយនឹងត្រីមាសទី០៤ ឆ្នាំ២០១៩ ដោយទំហំជួញដូរថយចុះប្រមាណ ១៦% ពី ៤៥,១៧៤ ភាគហ៊ុន ក្នុងត្រីមាសទី០៤ ឆ្នាំ២០១៩ មកត្រឹម ៣៧,៩៣៨ ភាគហ៊ុន ក្នុងត្រីមាសទី០១ ឆ្នាំ២០២០។ តម្លៃជួញដូរសរុបក្នុងត្រីមាសទី០១ ឆ្នាំ២០២០ នេះ មានតម្លៃប្រហែល ១៥៣,៥៧ លានរៀល (ប្រហែល ៣៨,៣៩ ពាន់ដុល្លារសហរដ្ឋអាមេរិក)។




ក្រាហ្វិចទី៣ ៖ ថ្លៃភាគហ៊ុនធៀប នឹងទំហំជួញដូររបស់ភាគហ៊ុន GTI

បរិមាណបញ្ជាលក់ភាគហ៊ុន GTI សរុបដែលបានដាក់បញ្ជាដោយវិនិយោគិនជនជាតិខ្មែរមានចំនួន ៣៣% និងបញ្ជាលក់ធ្វើឡើងដោយវិនិយោគិនបរទេសមានចំនួន ៦៧% នៃបរិមាណដាក់បញ្ជាលក់សរុប។ក្នុងនោះដែរ បរិមាណបញ្ជាលក់ភាគហ៊ុន GTI សរុបដែលបានធ្វើឡើងដោយវិនិយោគិនរូបវន្តបុគ្គលមានចំនួន ៩៩,៨៤% ក្រុមហ៊ុនមូលបត្រមានចំនួន ០,១៦% និងពុំមានការចូលរួមពីវិនិយោគិននីតិបុគ្គលទេ។

ចំពោះបរិមាណបញ្ជាទិញភាគហ៊ុន GTI សរុប ដែលបានដាក់បញ្ជាវិនិយោគិនជនជាតិខ្មែរមានចំនួន ៧១% និងបញ្ជាទិញធ្វើឡើងដោយវិនិយោគិនបរទេសមានចំនួន ៧១% និងបញ្ជាទិញធ្វើឡើងដោយវិនិយោគិនជនជាតិបរទេសមានចំនួន ២៩% នៃបរិមាណដាក់បញ្ជាទិញសរុប។ ក្នុងនោះដែរ បរិមាណបញ្ជាទិញភាគហ៊ុន GTI ទាំងអស់ធ្វើឡើងដោយវិនិយោគិនរូបវន្តបុគ្គល ដោយពុំមានការចូលរួមពីវិនិយោគិននីតិបុគ្គល និងក្រុមហ៊ុនមូលបត្រនោះទេ។




ក្រាហ្វិចទី៤ ៖ បញ្ជាទិញ និងលក់របស់ភាគហ៊ុន GTI តាមប្រភេទវិនិយោគ

### ៣.២.៣. **ភាគហ៊ុនរបស់កំពង់ផែស្វយ័តភ្នំពេញ** PPAP

| ទិដ្ឋភាពទូទៅ (PPAP) | ត្រីមាសទី ៤ ឆ្នាំ២០១៩ | ត្រីមាសទី ១ ឆ្នាំ២០២០ | បម្រែបម្រួល |
|---|---|---|---|
| មូលធនូបនីយកម្មទីផ្សារ (លានរៀល) | 258,555 | 221,323 | -14% |
| មូលធនូបនីយកម្មទីផ្សារ (លានដុល្លារអាមេរិក) | 64.64 | 55.33 | |
| ទំហំជួញដូរ (ភាគហ៊ុន) | 65,123 | 74,048 | 14% |
| ទំហំជួញដូរជាមធ្យមប្រចាំថ្ងៃ (ភាគហ៊ុន) | 1,104 | 1,194 | |
| តម្លៃជួញដូរ (លានរៀល) | 809.06 | 844.65 | 4% |
| តម្លៃជួញដូរ (ដុល្លារអាមេរិក) | 202,265.80 | 211,162.50 | |
| តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ (លានរៀល) | 13.71 | 13.62 | -1% |
| តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ (ដុល្លារអាមេរិក) | 3,428.23 | 3,405.85 | |

តារាងទី៥ ៖ ទិដ្ឋភាពទូទៅនៃការជួញដូរភាគហ៊ុន PPAP

ក្នុងត្រីមាសទី០១ ឆ្នាំ២០២០ ថ្លៃបិទភាគហ៊ុន PPAP ប្រែប្រួលក្នុងចន្លោះពី ១០,២៨០រៀល ដល់ ១២,៤២០រៀល ក្នុងមួយភាគហ៊ុន។ ចំណែកឯទំហំជួញដូរសរុបបានកើនឡើងប្រមាណ១៤% ពី ៦៥,១២៣ ភាគហ៊ុន ក្នុងត្រីមាសទី៤ឆ្នាំ ២០១៩ ដល់៧៤,០៤៨ ភាគ ក្នុងត្រីមាសទី០១ ឆ្នាំ២០២០ ។

តម្លៃជួញដូរភាគហ៊ុនសរុបមានចំនួនប្រហែល ៨៤៤,៦៥លានរៀល (ប្រហែល ២១១,១៧ពាន់ដុល្លារសហរដ្ឋអាមេរិក)។




ក្រាហ្វិចទី៥ ៖ ថ្លៃភាគហ៊ុនធៀបនិងទំហំជួញដូររបស់ភាគហ៊ុន PPAP

បរិមាណបញ្ជាលក់ភាគហ៊ុន PPAP សរុបដែលបានដាក់បញ្ជាដោយវិនិយោគិនជនជាតិខ្មែរមានចំនួន ៣២% និងបញ្ជាលក់ធ្វើឡើងដោយវិនិយោគិនបរទេសមានចំនួន ៦៨% នៃបរិមាណដាក់បញ្ជាលក់សរុប។ក្នុងនោះដែរ បរិមាណបញ្ជាលក់ភាគហ៊ុន PPAP សរុបដែលបានធ្វើឡើងដោយវិនិយោគិនរូបវន្តបុគ្គលមានចំនួន ៩៦,៤១% ក្រុមហ៊ុនមូលបត្រមានចំនួន ២,៤៣% និងវិនិយោគិននីតិបុគ្គលមានចំនួន ១,១៦%។

ចំពោះបរិមាណបញ្ជាទិញភាគហ៊ុន PPAP សរុប ដែលបានដាក់បញ្ជាវិនិយោគិនជនជាតិខ្មែរមានចំនួន ៨០% និងបញ្ជាទិញធ្វើឡើងដោយវិនិយោគិនបរទេសមានចំនួន ២០%នៃបរិមាណដាក់បញ្ជាទិញសុប។ ក្នុងនោះដែរ បរិមាណបញ្ជាទិញភាគហ៊ុន PPAP ទាំងអស់ធ្វើឡើងដោយវិនិយោគិនរូបវន្តបុគ្គលមានចំនួន ៧,០១% និងក្រុមហ៊ុនមូលបត្រចំនួន ៣,៤០%។




ក្រាហ្វិចទី៦៖ បញ្ជាទិញនិងលក់ភាគហ៊ុន PPAP តាមប្រភេទវិនិយោគិន

### ៣.២.៤. ភាគហ៊ុនរបស់កំពង់ផែស្វយ័តភ្នំពេញ PPSP

| ទិដ្ឋភាពទូទៅ (PPSP) | ត្រីមាសទី ៤ ឆ្នាំ២០១៩ | ត្រីមាសទី ១ ២០២០ | បម្រែបម្រួល |
|---|---|---|---|
| មូលធនូបនីយកម្មទីផ្សារ (លានរៀល) | 185,438 | 166,031 | -10% |
| មូលធនូបនីយកម្មទីផ្សារ (លានដុល្លារអាមេរិក) | 46.36 | 41.51 | |
| ទំហំជួញដូរ (ភាគហ៊ុន) | 178,750 | 184,505 | 3% |
| ទំហំជួញដូរជាមធ្យមប្រចាំថ្ងៃ (ភាគហ៊ុន) | 3,030 | 2,976 | |
| តម្លៃជួញដូរ (លានរៀល) | 479.83 | 455.27 | -5% |
| តម្លៃជួញដូរ (ដុល្លារអាមេរិក) | 119,957.63 | 113,817.14 | |
| តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ (លានរៀល) | 8.13 | 7.34 | -10% |
| តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ (ដុល្លារអាមេរិក) | 2,033.18 | 1,835.76 | |

តារាងទី៦ ៖ ទិដ្ឋភាពទូទៅនៃការជួញដូរភាគហ៊ុន PPSP

ក្នុងត្រីមាសទី០១ ឆ្នាំ២០២០ ថ្លៃបិទភាគហ៊ុន PPSP ប្រែប្រួលក្នុងចន្លោះពី ២,២០០រៀល ដល់ ២,៦៨០រៀល ក្នុងមួយភាគហ៊ុន។ ចំណែកឯទំហំជួញដូរសរុបបានកើនឡើងបន្តិច ៣% ពី ១៧៨,៥០៤

ភាគហ៊ុន ក្នុងត្រីមាសទី០៤ ឆ្នាំ២០១៩ ដល់ ១៨៤,៥០៥ ភាគហ៊ុន ក្នុងត្រីមាសទី០១ ឆ្នាំ២០២០។ តម្លៃជួញដូរសរុបក្នុងត្រីមាសទី០១ ឆ្នាំ២០២០ នេះ មានតម្លៃប្រហែល ៤៥៥,២៧ លានរៀល (ប្រហែល ១១៣,៨២ ពាន់ដុល្លារសហរដ្ឋអាមេរិក)។




ក្រាហ្វិចទី៧៖ ថ្លៃភាគហ៊ុនធៀបនិងទំហំជួញដូររបស់ភាគហ៊ុន PPSP

បរិមាណបញ្ជាលក់ភាគហ៊ុន PPSP សរុបដែលបានដាក់បញ្ជាដោយវិនិយោគិនជនជាតិខ្មែរមានចំនួន ៥២% និងបញ្ជាលក់ធ្វើឡើងដោយវិនិយោគិនបរទេសមានចំនួន ៤៨% នៃបរិមាណដាក់បញ្ជាលក់សរុប។ក្នុងនោះដែរ បរិមាណបញ្ជាលក់ភាគហ៊ុន PPSP សរុបដែលបានធ្វើឡើងដោយវិនិយោគិនរូបវន្តបុគ្គលមានចំនួន ៦១,១% ក្រុមហ៊ុនមូលបត្រមានចំនួន ៣៨,៩% និងពុំមានការចូលរួមពីវិនិយោគិននីតិបុគ្គលទេ។

ចំពោះបរិមាណបញ្ជាទិញភាគហ៊ុន PPSP សរុប ដែលបានដាក់បញ្ជាវិនិយោគិនជនជាតិខ្មែរមានចំនួន ៦៨% និងបញ្ជាទិញធ្វើឡើងដោយវិនិយោគិនបរទេសមានចំនួន ៣២% នៃបរិមាណដាក់បញ្ជាទិញសរុប។ ក្នុងនោះដែរ បរិមាណបញ្ជាទិញភាគហ៊ុន PPSP ទាំងអស់ធ្វើឡើងដោយវិនិយោគិនរូបវន្តបុគ្គលដោយពុំមានការចូលរួមពីវិនិយោគិននីតិបុគ្គល និងក្រុមហ៊ុនមូលបត្រនោះទេ។




ក្រាហ្វិចទី៨ ៖ បញ្ជាទិញនិងលក់ភាគហ៊ុន PPSPតាមប្រភេទវិនិយោគិន

### ៣.២.៥. ភាគហ៊ុនរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ PAS

| ទិដ្ឋភាព ទូទៅ (PAS) | ត្រីមាសទី ៤ ឆ្នាំ២០១៩ | ត្រីមាសទី ១ ឆ្នាំ២០២០ | បម្រែបម្រួល |
|---|---|---|---|
| មូលធនូបនីយកម្មទីផ្សារ (លានរៀល) | 1,663,976 | 1,127,044 | -32% |
| មូលធនូបនីយកម្មទីផ្សារ (លានដុល្លារអាមេរិក) | 415.99 | 281.76 | |
| ទំហំជួញដូរ (ភាគហ៊ុន) | 138,029 | 87,871 | -36% |
| ទំហំជួញដូរជាមធ្យមប្រចាំថ្ងៃ (ភាគហ៊ុន) | 2,339 | 1,417 | |
| តម្លៃជួញដូរ (លានរៀល) | 2,809.19 | 1,393.90 | -50% |
| តម្លៃជួញដូរ (ដុល្លារអាមេរិក) | 702,296.30 | 348,473.80 | |
| តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ (លានរៀល) | 47.61 | 22.48 | -53% |
| តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ (ដុល្លារអាមេរិក) | 11,903.33 | 5,620.55 | |

តារាងទី៧ ៖ ទិដ្ឋភាពទូទៅនៃការជួញដូរភាគហ៊ុន PAS

ក្នុងត្រីមាសទី០១ ឆ្នាំ២០២០ ថ្លៃបិទភាគហ៊ុន PAS ប្រែប្រួលក្នុងចន្លោះពី ១២,៥០០រៀល ដល់ ១៩,៦០០រៀល ក្នុងមួយភាគហ៊ុន។ ចំណែកឯទំហំជួញដូរថយចុះប្រមាណ ៣៦% ធៀបជាមួយនឹងត្រីមាសទី០៤ ឆ្នាំ២០១៩ ដែលថយចុះពី ១៣៨,០២៩ ភាគហ៊ុន មកត្រឹម ៨៧,៨៧១ ភាគហ៊ុន ក្នុងត្រីមាសទី០១ ឆ្នាំ២០២០។ តម្លៃជួញដូរសរុបមានតម្លៃប្រហែល ១,៣៩៣,៩០ លានរៀល (ប្រហែល ៣៤៨,៤៧ ពាន់ដុល្លារសហរដ្ឋអាមេរិក)។




ក្រាហ្វិចទី៩ ៖ ថ្លៃភាគហ៊ុនធៀបនិងទំហំជួញដូររបស់ភាគហ៊ុន PAS

បរិមាណបញ្ជាលក់ភាគហ៊ុន PAS សរុបដែលបានដាក់បញ្ជាដោយវិនិយោគិនជនជាតិខ្មែរមានចំនួន ៤៨% និងបញ្ជាលក់ធ្វើឡើងដោយវិនិយោគិនបរទេសមានចំនួន ៥២% នៃបរិមាណដាក់បញ្ជាលក់សរុប។ក្នុងនោះដែរ បរិមាណបញ្ជាលក់ភាគហ៊ុន PAS សរុបដែលបានធ្វើឡើងដោយវិនិយោគិនរូបវន្តបុគ្គលមានចំនួន ៩៩,៩៦% ក្រុមហ៊ុនមូលបត្រមានចំនួន ០,០៤% និងពុំមានការចូលរួមពីវិនិយោគិននីតិបុគ្គលទេ។

ចំពោះបរិមាណបញ្ជាទិញភាគហ៊ុន PAS សរុបដែលបានដាក់បញ្ជាវិនិយោគិនជនជាតិខ្មែរមានចំនួន ៧២% និងបញ្ជាទិញធ្វើឡើងដោយវិនិយោគិនបរទេសមានចំនួន ២៨% នៃបរិមាណដាក់បញ្ជាទិញសរុប។ ក្នុងនោះដែរ បរិមាណបញ្ជាទិញភាគហ៊ុន PAS ស្ទើរតែទាំងអស់ធ្វើឡើងដោយ វិនិយោគិនរូបវន្តបុគ្គល ។




ក្រាហ្វិចទី១០ ៖ បញ្ជាទិញនិងលក់ភាគហ៊ុនតាមប្រភេទវិនិយោគិន PAS

## ៣.៣. សកម្មភាពជួញដូរមូលបត្រកម្មសិទ្ធរបស់វិនិយោគិន

ក្នុងត្រីមាសទី០១ ឆ្នាំ២០២០ ចំនួនវិនិយោគិនចូលរួមសរុបមានចំនួន ៦៣៤នាក់ ដែលក្នុងនោះ វិនិយោគិនជនជាតិខ្មែរមានចំនួន ៧១% វិនិយោគិនជនជាតិជប៉ុនមានចំនួន ១៤% វិនិយោគិនជនជាតិចិន មានចំនួន ៩% និងវិនិយោគិនដែលមានសញ្ជាតិផ្សេងទៀតចំនួន ៦%។




ក្រាហ្វិចទី១១ ៖ ការចូលរួមរបស់វិនិយោគិនខ្មែរ និងបរទេស

## ៣.៤. សកម្មភាពជួញដូរសញ្ញាបណ្ណរបស់ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្របំណុល

### ៣.៤.១. គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីធីត

នាថ្ងៃ ០៥ ខែធ្នូ ឆ្នាំ២០១៨ ផ.ម.ក បានទទួលស្វាគមន៍នៃការចុះបញ្ជីដាក់ឲ្យ ជួញដូរនូវសញ្ញាបណ្ណដំបូងបំផុត ដែលមានឈ្មោះថា "សញ្ញាប័ណ្ណដំបូងបំផុតនៅកម្ពុជាលេខ១" (HKL21A) បោះផ្សាយជាប្រាក់រៀល ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថកសិករ លីមីតធីត។ ការបោះផ្សាយសញ្ញាបណ្ណ HKL21A ត្រូវបានធ្វើឡើងក្នុងបរិមាណ ១,២លានសញ្ញាបណ្ណ ដែលគិតជាទឹកប្រាក់សរុបចំនួន ១២០ពាន់លានរៀល។ វិនិយោគិនសញ្ញាបណ្ណនេះនឹងទទួលបានគូប៉ុង (ការប្រាក់) ដែលបង់ប្រចាំឆមាសក្នុងអត្រា ៨,៥០% ក្នុងមួយឆ្នាំ។ យ៉ាងណាមិញ ក្នុងត្រីមាសទី០១ ឆ្នាំ២០២០ នេះសញ្ញាបណ្ណសាជីវកម្ម (Corporate Bond) របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហត្ថាកសិករ (HKL) ពុំមានការជួញដូរទេ។

### ៣.៤.២. គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី

បន្ទាប់ពីការចុះបញ្ជីលក់មូលបត្រសញ្ញាបណ្ណសាជីវកម្ម របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីធីត ផ.ម.ក. បានសម្រេចចុះបញ្ជីសញ្ញាបណ្ណសាជីវកម្មដែលបានចុះបញ្ជីលក់នេះមានឈ្មោះថា"សញ្ញាបណ្ណសាជីវកម្ម អិល អូ អិល ស៊ី មានការការពារហានិភ័យអត្រាប្តូរប្រាក់ FX-indexed Bond 2019-2022 No.1" ដែលមានអត្រាគូប៉ុង ៨% ក្នុងមួយឆ្នាំ និង "សញ្ញាបណ្ណសាជីវកម្ម អិល អូ អិល ស៊ី មិនការការពារហានិភ័យអត្រាប្តូរប្រាក់" ដែលមានអត្រាគូប៉ុង ៩% ក្នុងមួយឆ្នាំ។ សញ្ញាបណ្ណសាជីវកម្មនេះមានឥណទានប្រតិទិនរយៈពេល ៣ឆ្នាំ ដោយគិតចាប់ពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩ដល់ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២។ ក្នុងត្រីមាសទី០១ ឆ្នាំ២០២០ នេះ សញ្ញាបណ្ណសាជីវកម្ម (Corporate Bond) របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី ពុំមានការជួញដូរទេ។

### ៣.៤.៣. ធនាគារវឌ្ឍនៈអាស៊ីចំកាត់

នាថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ សញ្ញាបណ្ណសាជីវកម្មរបស់ធនាគារ វឌ្ឍនៈ អាស៊ីចំកាត់ (ABA) ត្រូវបានសម្រេចឲ្យចុះបញ្ជីជាផ្លូវការនៅ ផ.ម.ក.។ សញ្ញាបណ្ណសាជីវកម្មនេះ មានឈ្មោះថា "សញ្ញាបណ្ណសាជីវកម្ម អេ ប៊ី អេ" ដែលមានអត្រាគូប៉ុងចំនួន ៧,៧៦% ក្នុងមួយឆ្នាំ ជាមួយនឹងឥណប្រតិទិនរយៈពេល ៣ឆ្នាំ ដោយគិតចាប់ពីថ្ងៃទី១៤ខែសីហា ឆ្នាំ២០១៩ រហូតដល់ ថ្ងៃទី១៤ ខែសីហាឆ្នាំ២០២០។ គួរបញ្ជាក់ផងដែរថា ធនាគារ វឌ្ឍនៈ អាស៊ីចំកាត់ គឺជាធនាគារពាណិជ្ជដំបូងបង្អស់ដែលបានបោះផ្សាយលក់សញ្ញាបណ្ណសម្រាប់វិនិយោគិនស្ថាប័ន និងវិនិយោគិនរូបវន្តបុគ្គល ជាមួយនឹងអត្រាគូប៉ុង៧,៧% ដែលខ្ពស់ជាងអត្រាដាក់ប្រាក់បញ្ញើមានកាលកំណត់របស់ធនាគារពាណិជ្ជ។ បន្ថែមពីនេះសញ្ញាបណ្ណនេះទទួលបាន

ចំណាត់ថ្នាក់លទ្ធភាពសង "B" ចេញដោយភ្នាក់ងារវាយតម្លៃលទ្ធភាពសង S&P Global Ratings។ នៅក្នុងត្រីមាសទី០១ ឆ្នាំ២០២០ សញ្ញាបណ្ណសាជីវកម្ម អេ ប៊ី អេ មានការដាក់បរិមាណបញ្ជាសរុបមានចំនួន ១៦,៤ ពាន់ឯកតា និងបរិមាណបញ្ជាលក់មានចំនួនប្រមាណ ១៦,៣ ពាន់ឯកតា និងបរិមាណបញ្ជាទិញមានចំនួន ៦២ ពាន់ឯកតា (អនុបាតបញ្ជាក់ធៀបនឹងបញ្ជាទិញមានចំនួន ២៦៤)។ ចំពោះវិនិយោគិនចូលរួមដាក់បញ្ជាមានចំនួន ៧ រូប ដែលសុទ្ធតែជាវិនិយោគិនរូបវន្តបុគ្គលជនជាតិខ្មែរ។

## ៣.៥. ស្ថិតិវិនិយោគ

### ៣.៥.១. ចំនួនវិនិយោគចាប់ពីឆ្នាំ២០១២ ដល់ត្រីមាសទី១ឆ្នាំ ២០២០

#### ក. ចំនួនវិនិយោគិន




ក្រាហ្វិចទី១២ ៖ ចំនួនវិនិយោគិនសរុប (២០២០ ដល់ត្រីមាសទី១ ឆ្នាំ២០២០)

តាមរយៈក្រាហ្វិចទិន្នន័យខាងលើនេះបានបង្ហាញថា មានវិនិយោគិនដែលបានស្នើសុំ និងទទួលបានលេខអត្តសញ្ញាណវិនិយោគិនពី គ.ម.ក. ក្នុងឆ្នាំ ២០១២ មានចំនួន ១៩% , ឆ្នាំ២០១៣ មានចំនួន ៤%, ឆ្នាំ២០១៤ មានចំនួន ៣%, ឆ្នាំ ២០១៥ មានចំនួន ៥%, ឆ្នាំ២០១៦ មានចំនួន ២%, ឆ្នាំ២០១៧ មានចំនួន ៤% , ឆ្នាំ២០១៨ មានចំនួន ៤៩%, ឆ្នាំ២០១៩ មានចំនួន ៨% និងក្នុងត្រីមាសទី០១ ឆ្នាំ ២០២០នេះ មានវិនិយោគិនដែលទទួលបានលេខអត្តសញ្ញាណវិនិយោគិនមានចំនួន ៧% នៃចំនួនវិនិយោគិនសរុប។

### ខ. វិនិយោគិនរូបវន្តបុគ្គល និងនីតិបុគ្គលទៅតាមឆ្នាំនីមួយៗ




ក្រាហ្វិចទី១៣៖ វិនិយោគិនជាមួយនិងនីតិបុគ្គលទៅតាមឆ្នាំនីមួយៗ




ក្រាហ្វិចទី១៤ ៖ វិនិយោគិនសរុបជារូបវន្តបុគ្គល និងនីតិបុគ្គល

គិតត្រឹមត្រីមាសទី០១ ឆ្នាំ២០២០ នេះគ.ម.ក. បានទទួល និងផ្តល់លេខអត្តសញ្ញាណវិនិយោគជូនវិនិយោគជារូបវន្តបុគ្គលមានចំនួន ៩៩% និងជានីតិបុគ្គលមានចំនួន ១%។

**គ. វិនិយោគិនសញ្ជាតិខ្មែរ និងសញ្ជាតិបរទេសទៅតាមឆ្នាំនីមួយៗ**




ក្រាហ្វិចទី១៥ ៖ វិនិយោគិនសញ្ជាតិខ្មែរ និងសញ្ជាតិបរទេសទៅតាមឆ្នាំនីមួយៗ

តាមរយៈក្រាហ្វិចខាងលើនេះបង្ហាញថាឆ្នាំ២០២០វិនិយោគសញ្ជាតិខ្មែរមានចំនួន៧% វិនិយោគិនសញ្ជាតិបរទេសមានចំនួន២៩%, ឆ្នាំ២០១៥ សញ្ជាតិខ្មែរមានរហូតដល់ ៩៧% ខណៈពេលវិនិយោគិនសញ្ជាតិបរទេសមានត្រឹមតែ ៣% ប៉ុណ្ណោះ។

វិនិយោគិនសញ្ជាតិខ្មែរ និងសញ្ជាតិបរទេស សរុបត្រឹមត្រីមាសទី១ ឆ្នាំ២០២០




ក្រាហ្វិច១៦ ៖ វិនិយោគិនសញ្ជាតិខ្មែរ និងសញ្ជាតិបរទេស

តាមរយៈទិន្នន័យដែលបានបង្ហាញខាងលើ គិតត្រឹមត្រីមាសទី១ ឆ្នាំ២០២០ គ.ម.ក. បានផ្តល់លេខអត្តសញ្ញាណវិនិយោគិនជូនវិនិយោគិនខ្មែរមានចំនួន ៨៣% និងវិនិយោគសញ្ជាតិបរទេសមានចំនួន ១៧%នៃចំនួនវិនិយោគិនសរុប។







ក្រាហ្វិចទី១៧ ៖ ចំនួនវិនិយោគិនជារូបវន្តបុគ្គលតាមសញ្ជាតិ

ក្រាហ្វិចទី១៨ ៖ ចំនួនវិនិយោគិនជានីតិបុគ្គលតាមសញ្ជាតិ

តាមរយៈក្រាហ្វិច ខាងលើនេះក្នុងចំណោមវិនិយោគិន ជារូបវន្តបុគ្គល មានវិនិយោគិនដែលមានសញ្ជាតិខ្មែរមានចំនួនច្រើនជាងគេរហូតដល់ ៧៩% ចិន៨% ជប៉ុន៥% ម៉ាឡេស៊ី ១% និងវិនិយោគិនផ្សេងៗចំនួន ៦%។ ក្នុងចំណោមវិនិយោគិនជានីតិបុគ្គល មានវិនិយោគិនដែលមានសញ្ជាតិខ្មែរចំនួន ១៨% ចិន១៥% សហរដ្ឋអាមេរិច ១៥% ជប៉ុន១១% អូស្ត្រាលី៦% អង់គ្លេស៦% ម៉ាឡេស៊ី៦% កូរ៉េខាងត្បូង ៣% វៀតណាម២% និងមានវិនិយោគិនសញ្ជាតិផ្សេងៗទៀត១៣%។

### ឃ. វិនិយោគិនតាមភេទ




ក្រាហ្វិច១៩ ៖ វិនិយោគិនតាមភេទ (ប្រុស និងស្រី)

គិតត្រឹមដំណាច់ត្រីមាសទី១ ឆ្នាំ២០២០ វិនិយោគិនរួមទាំងរូបវន្តបុគ្គល និងនីតិបុគ្គល ព្រមទាំងវិនិយោគិនគ្រប់សញ្ជាតិ ដែលទទួលបានលេខអត្តសញ្ញាណវិនិយោគិនពី គ.ម.ក. មានវិនិយោគិនភេទស្រី

មានចំនួន ៣៨% និងវិនិយោគិនភេទប្រុស មានចំនួន៦២% នៃវិនិយោគិនសរុបដែលមានលេខអត្តសញ្ញាណវិនិយោគិន។

### ៣.៥.២. ចំនួនគណនីជួញដូរ




ក្រាហ្វិចទី២០ ៖ គណនីជួញដូរត្រីមាសទី១ ឆ្នាំ២០២០

តាមទិន្នន័យខាងលើនេះដោយគិតត្រឹមត្រីមាស០១ ឆ្នាំ២០២០ចំនួនវិនិយោគិនដែលទទួលបានលេខអត្តសញ្ញាណវិនិយោគិនពី គ.ម.ក. រួចហើយ នឹងបានទៅបើកគណនីជួញដូរមូលបត្រនៅតាមបណ្ដាក្រុមហ៊ុនមូលបត្រមានចំនួនប្រហែល២៤០០០លេខគណនីជួញដូរ ដែលវិនិយោគិនបានបើកគណនីជួញដូរនៅក្រុមហ៊ុនមូលបត្រអេស៊ីសីដា ស៊ីឃ្យូរីធី ភីអិលស៊ី មានចំនួន ៨០.៥% ក្រុមហ៊ុន អិលប៊ីអាយ រ៉ូយ៉ាល់ ស៊ីឃ្យូរីធី មានចំនួន ៦% ក្រុមហ៊ុន អ អេច ប៊ី ស៊ីឃ្យូរីធី (ខេមបូឌា) ម.ក. មានចំនួន ៥.៣% និងតាមបណ្ដាក្រុមហ៊ុនមូលបត្រផ្សេងៗ មួយចំនួនទៀតផងដែរ។

### ៣.៥.៣. វិនិយោគិនដែលមានសកម្មភាពវិនិយោគក្នុងទីផ្សារប្រចាំត្រីមាសទី១ឆ្នាំ ២០២០

ក្នុងត្រីមាសទី០១ ឆ្នាំ២០២០ ចំនួនវិនិយោគិនដែលចូលរួមវិនិយោគក្នុងទីផ្សារមូលបត្រ ក្នុងនោះ ភាគហ៊ុនរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (PPWA) ចំនួន ១៩%, ភាគហ៊ុនរបស់ក្រុមហ៊ុនហ្ក្រេនធ្វីនអិនធើនេសិនណល(ខេមបូឌា) ភិអិលស៊ី (GTI) មានចំនួន ១០%, ភាគហ៊ុនរបស់កំពង់ផែស្វយ័តភ្នំពេញ (PPAP) មានចំនួន ១៩%, ភាគហ៊ុនរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ (PAS) មានចំនួន ២៨%,

ភាគហ៊ុនរបស់ក្រុមហ៊ុនភ្នំពេញអេសអ៊ីហ្សិតភីអិលស៊ី (PPSP) មានចំនួន១៩% និងមូលបត្របំណុលរបស់ធនាគារវឌ្ឍនៈអាស៊ីចំកាត់ (ABA) មានចំនួន៦%។

### ៣.៥.៤. ចំនួនបញ្ជាទិញ និងលក់

ចំនួនបញ្ជាទិញ និងលក់សរុបប្រចាំឆ្នាំត្រីមាសទី០១ ឆ្នាំ២០២០ មានចំនួនសរុបប្រមាណ ៧,៦២ លាន ភាគហ៊ុន ដែលក្នុងនោះបរិមាណបញ្ជាលក់មានប្រមាណ ៣,៨៦ លានភាគហ៊ុន និងចំនួនបញ្ជាទិញមានប្រមាណ ៣,៧៦ លានភាគហ៊ុន។ នៅក្នុងនោះ បរិមាណបញ្ជាទិញសរុបបានកើនឡើងប្រមាណ ៦៥% ធៀបនឹងត្រីមាសទី០៤ ឆ្នាំ២០១៩ ប៉ុន្តែបរិមាណបញ្ជាលក់បានថយចុះប្រមាណ ១៧% បើប្រៀបធៀបនឹងត្រីមាសទី០៤ ឆ្នាំ២០១៩ ផងដែរ។ ក្នុងចំណោមភាគហ៊ុនចុះបញ្ជីលក់នៅ ផ.ម.ក. ភាគហ៊ុនរបស់ PWSA ទទួលបានការដាក់បញ្ជាលក់ច្រើនជាងគេ ដែលមានចំនួនបញ្ជាលក់សរុបប្រមាណ ១,២២ លានភាគហ៊ុន និងភាគហ៊ុន PPSP ទទួលបានការដាក់បញ្ជាទិញច្រើនជាងគេ ដែលមានចំនួនសរុបប្រមាណ ១,៩៧ ពាន់ភាគហ៊ុន។




ក្រាហ្វិចទី២១ ៖ ចំនួនបញ្ជាទិញ និងលក់ភាគហ៊ុនចុះបញ្ជីរបស់វិនិយោគិន

## ៣.៦. ទិន្នន័យសង្ខេបនៃការជួញដូរប្រចាំត្រីមាសទី១ឆ្នាំ២០២០

| ទិដ្ឋភាពទូទៅនៃទីផ្សារ | ត្រីមាសទី៤ ឆ្នាំ២០១៩ | ត្រីមាសទី១ ឆ្នាំ២០២០ | បម្រែបម្រួល |
|---|---|---|---|
| ថ្ងៃជួញដូរ | 59 | 62 | 5% |
| ចំនួនភាគហ៊ុនចុះបញ្ជីសរុប (លានភាគហ៊ុន) | 305 | 305 | 0% |
| មូលធនូបនីយកម្មទីផ្សារ (លានរៀល) | 2,805,808 | 2,175,558 | -22% |
| មូលធនូបនីយកម្មទីផ្សារ (លានដុល្លារអាមេរិក) | 701 | 544 | |
| បរិមាណបញ្ជាទិញ (លានភាគហ៊ុន) | 2.3 | 3.8 | 65% |
| បរិមាណបញ្ជាលក់ (លានភាគហ៊ុន) | 4.65 | 3.86 | -17% |
| ទំហំជួញដូរ (លានភាគហ៊ុន) | 0.68 | 0.56 | -17% |
| ទំហំជួញដូរជាមធ្យមប្រចាំថ្ងៃ (ភាគហ៊ុន) | 11,502 | 9,040 | |
| តម្លៃជួញដូរ (លានរៀល) | 5,807 | 3,899 | -33% |
| តម្លៃជួញដូរ (លានដុល្លារអាមេរិក) | 1.5 | 0.97 | |
| តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ (លានរៀល) | 98 | 63 | -36% |
| តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ (ដុល្លារអាមេរិក) | 24,605 | 15,723 | |
| សន្ទស្សន៍ ផ.ម.ក. (សន្ទស្សន៍ បិទ) | 761.73 | 590.63 | -22% |

តារាងទី៨ ៖ ទិដ្ឋភាពទូទៅនៃការជួញដូរក្នុងមូលបត្រកម្មសិទ្ធ

ទំហំមូលធននូបនីយកម្មទីផ្សារសរុប (Market Cap.) នៅចុងត្រីមាសទី១ ឆ្នាំ២០២០ មានតម្លៃ ២,១៧៥,៥៥៨ លានរៀល (ប្រហែល ៥៤៤លានដុល្លារសហរដ្ឋអាមេរិច)។ ក្នុងត្រីមាសទី០១ ឆ្នាំ២០២០ ទំហំជួញដូរសរុបមានចំនួន ៥៦០,៤៧៩ ភាគហ៊ុន បានថយចុះប្រមាណ១៧%ប្រៀបធៀបនិងត្រីមាសទី ០៤ ឆ្នាំ២០១៩ ដែលមានបរិមាណជួញដូរសរុបប្រមាណចំនួន ៦៧៨,០០៨ ភាគហ៊ុន។ តម្លៃជួញដូរមូលបត្រសរុបមានតម្លៃប្រហែល ៣,៨៩៩ លានរៀល (ប្រហែល ៩៧៤ ពាន់ដុល្លារសហរដ្ឋអាមេរិច) បានថយចុះប្រមាណ៣៣% ប្រៀបធៀបជាមួយនិងត្រីមាសទី៤ ឆ្នាំថ២០១៩។ ចំពោះទំហំជួញដូរជាមធ្យមប្រចាំថ្ងៃមានចំនួន ៩,០៤០ ភាគហ៊ុន ដែលមានតម្លៃប្រមាណ ៦២,៩ លានរៀល(ប្រហែលនឹង ១៥,៧ ពាន់ដុល្លារសហរដ្ឋអាមេរិច)។ ចំណែកឯបញ្ជាទិញមានចំនួនន ៣,៧៦ លានភាគហ៊ុនខណៈដែលបញ្ជាំលក់មានចំនួន ៣,៨៥ លានភាគហ៊ុន ដែលបញ្ជាទិញកើនឡើងចំនួន ៦៥% និងបញ្ជាលក់ថយចុះ ១៧% បើធៀបនិងត្រីមាសទី៤ ឆ្នាំ២០១៩។




ក្រាហ្វិចទី២២ ៖ ទំហំជួញដូររបស់ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ (គិតជាភាគរយ)

ទំហំជួញដូរភាគហ៊ុនរបស់ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្របានបែងចែកតាមក្រុមហ៊ុន រួមមាន PWSA ស្មើរនឹង ៣១%, GTI ស្មើរនឹង ៧%, PPAP ស្មើរនឹង ១៣%, PPSP ស្មើរនឹង ៣៣%, PAS ស្មើរនឹង ១៦% នៃភាគហ៊ុនដែលបានជួញដូរសរុបប្រចាំត្រីមាសទី១ ឆ្នាំ២០២០។

## ៣.៧. សន្ទស្សន៍ ផ.ម.ក




ក្រាហ្វិចទី២៣ ៖ ទំហំជួញដូរសរុប និងសន្ទស្សន៍ ផ.ម.ក

ក្នុងត្រីមាសទី០១ ឆ្នាំ២០២០ សន្ទស្សន៍ ផ.ម.ក បានថយចុះប្រមាណ ២២% ដែលប្រែប្រួលពី ៧៦១,៧៣ នៅចុងត្រីមាសទី០៤ ឆ្នាំ២០១៩ មកត្រឹម ៥៩០,៦៣ នៅចុងត្រីមាសទី០១ ឆ្នាំ ២០២០ ។

## ៣.៨. ចំណុចខ្លាំង និងចំណុចខ្សោយ

- **ចំណុចខ្លាំង**
  - មានការចូលរួមពីក្រុមហ៊ុនមូលបត្រកូរ៉េ និងការបង្ហាត់បង្ហាញពីបុគ្គលិកមានជំនាញ ដែលជាហេតុឲ្យមានការរៀបចំ និងប្រតិបត្តិការក្នុងទីផ្សារមានលក្ខណៈច្បាស់លាស់ និងងាយស្រួលយល់
  - ការដាក់ឲ្យអនុវត្តន៍ច្បាប់ បទបញ្ញាត្តិ វិធានការ និងប្រកាសដែលទាក់ទងនឹងប្រតិបត្តិការទីផ្សារ និងដំណើរការជួញដូរមានប្រសិទ្ធភាព
  - ការដាក់បង្ហាញនូវព័ត៌មានទាក់ទងនឹងវិស័យមូលបត្រ អ្នកចូលរួមក្នុងទីផ្សារ និងទិន្នន័យទីផ្សារតាមរយៈគេហទំព័របានក្បោះក្បាយ ដែលជាហេតុងាយស្រួលដល់មហាជន ក្នុងការទទួលយកព័ត៌មានបន្ថែម
  - ការរៀបចំឡើងនូវសិក្ខាសាលាអប់រំ និងវគ្គបំប៉នខ្លីៗ ដើម្បីបណ្តុះបណ្តាលវិជ្ជាជីវៈទាក់ទងនឹងវិស័យមូលបត្រ
  - ការបើកឲ្យមានកម្មវិធីប្រកួតប្រជែងដល់សិស្សនិសិត្ស និងមហាជនក្នុងការអនុវត្តការទិញលក់មូលបត្រនៅលើទីផ្សារ ក្នុងគោលបំណងបញ្ជ្រាបព័ត៌មានឲ្យកាន់តែទំលំទូលាយ។
- **ចំណុចខ្សោយ**
  - ជាក់ស្តែងចំណេះដឹងទាក់ទងនឹងការជួញដូរមូលបត្រនៅ ផ្សារមូលបត្រកម្ពុជារបស់វិនិយោគិនទាំងក្នុងស្រុក និងក្រៅស្រុកនៅមានកម្រិតនៅឡើយ
  - ក្រុមហ៊ុនចុះបញ្ជីនៅក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាមានចំនួនតិច ដែលជាហេតុធ្វើឲ្យមានជម្រើសតិចក្នុងការជ្រើសរើស
  - ចំនួននៃប្រតិបត្តិការជួញដូរនៅមានកម្រិតទាបនៅឡើយ ដែលនាំឲ្យវិនិយោគិនខ្វះការទុកចិត្តលើក្រុមហ៊ុនមូលបត្រ និងដំណើរការទីផ្សារ។

# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវអំពីប្រធានបទដែលស្តីពី "ទំនាក់ទំនងរវាងទីផ្សារមូលបត្រ និងកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ" រួចមកយើងខ្ញុំបានទទួលនូវចំណេះដឹងបន្ថែមទៀតមួយកម្រិតទៀតទាក់ទងទៅនឹងនីតិវិធីលក្ខខណ្ឌចាំបាច់ក្នុងការជួញដូរមូលបត្រ រួមទាំងបានស្វែងយល់ពីទីផ្សារមូលបត្រក៏ដូចជាបានដឹងនូវទិន្នន័យសង្ខេបមួយចំនួននៃការជួញដូរមូលបត្រ និងតួនាទីទីផ្សារមូលបត្រក្នុងសេដ្ឋកិច្ចជាតិ។ ជាក់ស្តែងក្នុងការជួញដូរមូលបត្រវាពិតជាមានដំណាក់កាលជាច្រើនក៏ប៉ុន្តែ ពុំសូវមានផលវិបាកសម្រាប់វិនិយោគិននោះទេ ដោយវិនិយោគិនគ្រាន់តែជ្រើសរើសក្រុមហ៊ុនមូលបត្រដែលខ្លួនពេញចិត្តដើម្បីធ្វើជាតំណាងក្នុងការជួញដូរមូលបត្រ បន្ទាប់មកគ្រាន់តែធ្វើការបើកនូវគណនីជួញដូរជាមួយក្រុមហ៊ុនមូលបត្រ និងធ្វើការភ្ជាប់មកជាមួយព័ត៌មានលំអិតរួមមាន ប្រភេទនៃបញ្ជាទិញឬលក់ ឈ្មោះមូលបត្រ ថ្លៃជួញដូរ បរិមាណជួញដូរជាដើម។ ចំណែកឯតួនាទីរបស់ទីផ្សារមូលបត្រជួយជម្រុញឲ្យមហាជនបង្កើននូវការសន្សំ និងកៀរគរមូលធនដែលនៅសេសសល់មិនមាន តម្រូវការប្រើប្រាស់ហើយធ្វើការប្រមែប្រមូលកៀរគរនូវប្រភពមូលធនដែលនៅទំនេរសម្រួលដល់រាជរដ្ឋាភិបាល ក្នុងការអនុវត្តនូវកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិឲ្យរីកចម្រើនដើម្បីទាក់ទាញ និងស្រូបយកនូវមូលធនពីបរទេស ហើយក៏បានជួយជម្រុញឲ្យប្រភពមូលធនក្នុងស្រុកមានចរាចររស់រវើកប្រកបដោយប្រសិទ្ធភាព អភិបាលកិច្ចល្អ បង្កើតនូវទម្លាប់នៃការវិនិយោគ និងធ្វើឲ្យប្រតិបត្តិការរបស់ខ្លួនប្រកបដោយស្ថេរភាព។

សរុបសេចក្តីមក ការវិនិយោគក្នុងវិស័យមូលបត្រគឺជាផ្នែកសំខាន់មួយដែលជួយជម្រុញឲ្យប្រទេសជាតិរបស់យើងមានការរីកចម្រើននឹងបន្តលូតលាស់ទៅមុខជាបន្តបន្ទាប់។ ជាការពិតណាស់ទីផ្សារមូលបត្រដំណើរការគឺបានផ្តល់ឱកាសដល់ក្រុមហ៊ុនធំ ឬតូចនៅប្រទេសកម្ពុជាប្រមូលដើមទុនផ្តល់ឲ្យក្រុមហ៊ុនបានបោះផ្សាយភាគហ៊ុនលក់នៅក្នុងទីផ្សារ។ ក្រុមហ៊ុនបានទទួលធនធានពីវិនិយោគដើម្បីយកទៅពង្រីកឧស្សាហកម្មឬអាជីវកម្មដើម្បីឲ្យបានរឹងមាំ ព្រមទាំងបង្កើតការងារបានកាន់តែច្រើនដើម្បីលើកតម្កើនជីវភាពរបស់ប្រជាពលរដ្ឋយើងផងដែរ។

## ២. ការផ្តល់អនុសាសន៍

ជាចុងក្រោយ បន្ទាប់ពីបានសិក្សានូវប្រធានបទខាងលើ ក្រុមនាងខ្ញុំមាននូវមតិយោបល់មួយចំនួនដើម្បីជាពុទ្ធិ នៅក្នុងការអភិវឌ្ឍវិស័យមូលបត្រនៅកម្ពុជាឲ្យកាន់តែរីកចម្រើន និងមានប្រជាប្រិយភាពពី

សំណាក់វិនិយោគិនគ្រប់ជាន់ថ្នាក់។ គំនិតយោបល់ដែលក្រុមនាងខ្ញុំចង់លើកយកមកបង្ហាញនោះមានដូចតទៅ៖

- ❖ គណៈកម្មការមូលបត្រកម្ពុជា គួតែបន្តធ្វើការផ្សព្វផ្សាយឲ្យទូលំទូលាយ ដល់សាធារណៈជនទូទៅ អំពីដំណើរការជួញដូរមូលបត្រ ផលប្រយោជន៍ និងសមិទ្ធផលដែលទទួលបានពីការវិនិយោគលើមូលបត្រ ដើម្បីជម្រុញទឹកចិត្តពួកគេឲ្យចូលរួមឲ្យកាន់តែច្រើន ។
- ❖ លើកទឹកចិត្តឲ្យបណ្តាក្រុមហ៊ុននានា ក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនបោះផ្សាយមូលបត្រ ឲ្យពួកគេចូលរួមយ៉ាងសកម្មក្នុងការបោះផ្សាយលក់មូលបត្រ ដើម្បីឲ្យមានកំណើននៃការផ្គត់ផ្គង់កើនឡើង។
- ❖ គណៈកម្មការមូលបត្រកម្ពុជា គួរតែសហការជាមួយក្រសួងពាក់ព័ន្ធ បញ្ចូលការអប់រំអំពីវិស័យមូលបត្រមួយនេះ នៅតាមសាលារៀន សកលវិទ្យាល័យ ស្ថាប័ន ក្រុមហ៊ុននានា ដើម្បីឲ្យពួកគេកាន់តែយល់ច្បាស់ពីវិស័យមួយនេះ និងការរីកសាយកាន់តែទូលំទូលាយជាងមុន។
- ❖ រដ្ឋាភិបាលគួតែរឹតបន្តឹងលើប្រព័ន្ធច្បាប់ និងបទបញ្ញត្តិដែលការពារផលប្រយោជន៍របស់វិនិយោគិន ដើម្បីបង្កើនទំនុកចិត្តវិនិយោគិនក្នុងការវិនិយោគមូលបត្រ ឲ្យមានតម្លាភាពនិងប្រសិទ្ធភាព។
- ❖ រដ្ឋាភិបាល ឧស្សាហកម្ម និងពាណិជ្ជកម្មព្រមទាំងធនាគារជាតិនៃកម្ពុជាគួរតែផ្តោត និងឃ្លាំមើលយ៉ាងដិតដល់អំពីទីផ្សារមូលបត្រនៅកម្ពុជា។

# ឯកសារយោង


## ច្បាប់ និងបទប្បញ្ញត្តិក្នុងវិស័យមូលបត្រកម្ពុជា

១. ច្បាប់ស្តីពី "ការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន" ព្រះរាជក្រមលេខ នស/រកម/ ១០០៧/ ០២៨/ ចុះថ្ងៃទី ១៩ តុលា ឆ្នាំ២០០៧ ។

២. អនុក្រឹតស្តីពី "ការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈកម្មការទីផ្សារមូលបត្រកម្ពុជា" លេខ ៩៧អនក្រ.ប .ក ចុះថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ ២០០៨

៣.ប្រកាសស្តីពី "ការអនុវត្តវិធានប្រតិបត្តិការផាត់ទាត់ និងទូទាត់មូលបត្រ" លេខ ០០៥ ១១ គ.ម.ក. ប្រ.ក ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១១។

## សៀវភៅ អត្ថបទ និងឯកសារសិក្សា

៤. មូលដ្ឋានគ្រឹះនៃទីផ្សារមូលបត្រ

៥. ឈៀង ម៉េងហៀក (២០១៨-២០១៩) មូលដ្ឋានគ្រឹះនៃការវិនិយោគ

៦. គណៈកម្មការមូលបត្រកម្ពុជា (២០១៦), អត្ថប្រយោជន៍នៃទីផ្សារមូលបត្រ

៧. Financial Market and Institution

៨. Overview of the Securities Market

## សារណាបញ្ចប់ការសិក្សា

៩. ពៅ ផនមន្ថា និងសែម សក្កា (២០១៨), "មូលដ្ឋានគ្រឹះនៃការវិនិយោគលើមូលបត្រកម្មសិទ្ធិ" សកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច

១០. លឹម វិភា (២០១៨), "ដំណើរការជួញដូរមូលបត្រលើទីផ្សារមូលបត្រកម្ពុជា" សកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច

## ឯកសារដកស្រង់ពីគេហទំព័រ

១១. https://m.postkhmer.com

១២. https://www.secc.gov.kh

១៣. https://siborann.blogspot.com

១៤. https://acledasecurities.com.kh

១៥. https://csx.com.kh/kh/product/mainboard.jsp

១៦. https://docplayer.net/20928200-The-role-of-financial-markets-in-economic-growth.html

១៧. https://www.bizkhmer.com/articles/61716

១៨. https://www.bizkhmer.com/articles/61496

១៩. https://www.bizkhmer.com/articles/60380

២០. https://www.bizkhmer.com/articles/45280

២១. https://www.bizkhmer.com/articles/73213

២២. https://talentedge.com/blog/role-finance-development-economy/

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា
លេខ:...០០១............គ ម ក

លិខិតចូល
ថ្ងៃទី០៧...ខែ០៤...ឆ្នាំ២០១០

# ប្រកាស
## ស្តីពី
## ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

* * * * *

### ឧបនាយករដ្ឋមន្ត្រី
### រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
### និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩

# ស ម្រេ ច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងចែងអំពីបែបបទ យន្តការ នីតិវិធី និងការអនុញ្ញាត ពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

**ប្រការ ២.-**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងប្រកាសនេះ ត្រូវបានកំណត់ក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ៖

១-ច្បាប់ សំដៅដល់ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

២-អនុក្រឹត្យ សំដៅដល់អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

៣-ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ អាចជាការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មីជាសាធារណៈ ឬការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិបន្ថែមជាសាធារណៈ ៖

ក-ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មី ឬលើកដំបូងជាសាធារណៈ សំដៅដល់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិដែលមិនធ្លាប់បានបោះផ្សាយលក់ជាសាធារណៈពីមុនមក ដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ដែលមានចែងក្នុងច្បាប់ អនុក្រឹត្យ និងប្រកាសនេះ។

ខ-ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិបន្ថែមជាសាធារណៈ សំដៅដល់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិដែលធ្វើឡើងដោយក្រុមហ៊ុនធ្លាប់បានបោះផ្សាយលក់មូលបត្រជាសាធារណៈរួចហើយ។

៤-ប្រាក់បង់លើស (Premium) សំដៅដល់ទឹកប្រាក់ដែលបានទទួលពីការលក់មូលបត្រកម្មសិទ្ធិលើសពីតម្លៃចារឹក។

៥-ភាគហ៊ុនបុរិមា (Preference Share) សំដៅដល់ភាគហ៊ុនដែលអ្នកកាន់កាប់គ្មានសិទ្ធិបោះឆ្នោត និងមានសិទ្ធិជាអាទិភាពក្នុងការទទួលភាគលាភ។

៦-ភ្នាក់ងារបញ្ជិកាមូលបត្រ (Securities Registrar) សំដៅដល់បុគ្គលដែលទទួលស្គាល់ដោយ **គ.ម.ក.** ដើម្បីផ្តល់សេវានានាពាក់ព័ន្ធនឹងការកត់ត្រាមូលបត្រដែលបានបោះផ្សាយលក់មូលបត្រជាសាធារណៈដោយក្រុមហ៊ុនបោះផ្សាយ។

៧-ភ្នាក់ងារវាយតម្លៃ សំដៅដល់ក្រុមហ៊ុនដែលមានសកម្មភាពធុរកិច្ចក្នុងការវាយតម្លៃទ្រព្យសកម្មរបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ។

៨-ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ (Securities Transfer Agent) សំដៅដល់បុគ្គលដែលទទួលស្គាល់ដោយ **គ.ម.ក.** ដើម្បីផ្តល់សេវានានាពាក់ព័ន្ធនឹងការផ្ទេរមូលបត្រ។

៩-ភ្នាក់ងារទូទាត់ជំនួស (Paying Agent) សំដៅដល់បុគ្គលដែលទទួលស្គាល់ដោយ **គ.ម.ក.** ដើម្បីផ្តល់សេវានានាពាក់ព័ន្ធនឹងការទូទាត់ជំនួសឱ្យក្រុមហ៊ុនបោះផ្សាយ។

១០-មូលបត្រកម្មសិទ្ធិ សំដៅដល់ផលប្រយោជន៍ ឬសិទ្ធិស្របច្បាប់លើមូលបត្រនៃក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត រួមទាំងនីតិបុគ្គលបរទេសប្រហាក់ប្រហែល ហើយរាប់បញ្ចូលទាំងភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោត និងគ្មានសិទ្ធិបោះឆ្នោត ភាគហ៊ុនមិនបង់ថ្លៃគ្រប់ និងភាគហ៊ុនបុរិមា។

១១-មូលធនភាគហ៊ុនិក (Shareholders' Equity) សំដៅដល់មូលធនសរុបរបស់ក្រុមហ៊ុនដែលវិនិយោគដោយភាគហ៊ុនិក រួមទាំងប្រាក់ចំណេញរក្សាទុក។

១២-របាយការណ៍ហិរញ្ញវត្ថុ សំដៅដល់របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មដោយសវនករឯករាជ្យ ដោយអនុលោមតាមច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ ដែលក្នុងនោះរួមមាន របាយការណ៍របស់អភិបាល របាយការណ៍របស់សវនករឯករាជ្យ និងរបាយការណ៍ហិរញ្ញវត្ថុដែលធ្វើសវនកម្មរួច។

១៣-សិទ្ធិបរិវត្តន៍ (Conversion Rights) សំដៅដល់សិទ្ធិក្នុងការផ្ទេរពីភាគហ៊ុនបុរិមាទៅជាមូលបត្រកម្មសិទ្ធិធម្មតា។

**ប្រការ ៣.-**

សំណើលក់មូលបត្រកម្មសិទ្ធិ អាចជាសំណើលក់ជាឯកជន ឬសំណើលក់ជាសាធារណៈ។

សំណើលក់មូលបត្រកម្មសិទ្ធិដែលបំពេញលក្ខខណ្ឌដូចខាងក្រោម ត្រូវចាត់ទុកថាជាសំណើលក់មូលបត្រកម្មសិទ្ធិជាឯកជន ៖

១-សំណើលក់មូលបត្រដែលធ្វើឡើង ចំពោះបុគ្គលដែលមានចំនួនមិនលើសពី ៣០ (សាមសិប) រូប និង

២-សំណើលក់មូលបត្រមិនត្រូវផ្សព្វផ្សាយជាសាធារណៈ ទោះបីតាមមធ្យោបាយណាក៏ដោយ រួមទាំងការផ្សព្វផ្សាយក្នុងគោលបំណងគ្រាន់តែឱ្យមកសាកសួរព័ត៌មាន ឬសុំពិគ្រោះយោបល់ អំពីការធ្វើវិនិយោគលើមូលបត្រ។

បុគ្គលដែលមានបំណងធ្វើសំណើលក់មូលបត្រជាឯកជន ត្រូវផ្តល់ឯកសារពាក់ព័ន្ធនឹងសំណើលក់នោះមក **គ.ម.ក.** ហើយនៅពេលដែលសំណើលក់ជាឯកជននោះបានបញ្ចប់ បុគ្គលត្រូវរាយការណ៍ពីលទ្ធផលឱ្យបានឆាប់ជូន **គ.ម.ក.**។ ចំពោះបុគ្គលដែលបានចុះបញ្ជីបោះផ្សាយលក់មូលបត្រជាសាធារណៈ ហើយមានសំណើធ្វើប្រតិបត្តិការដាក់លក់ជាឯកជន បុគ្គលត្រូវរាយការណ៍ពីលទ្ធផលភ្លាមជូន **គ.ម.ក.**។

សំណើលក់មូលបត្រកម្មសិទ្ធិទាំងឡាយណាដែលខុសពីលក្ខខណ្ឌខាងលើ គឺជាសំណើលក់មូលបត្រកម្មសិទ្ធិជាសាធារណៈដែលតម្រូវឱ្យអនុវត្តតាមនីតិវិធីដូចមានចែងក្នុងច្បាប់ ក្នុងអនុក្រឹត្យ និងក្នុងប្រកាសនេះ។

## ជំពូកទី ២
## ការអនុញ្ញាតការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

**ប្រការ ៤.-**

បុគ្គលដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ត្រូវបំពេញនូវលក្ខខណ្ឌដូចខាងក្រោម ៖

១-ត្រូវមានមូលធនភាគហ៊ុនិកសរុបយ៉ាងតិច ៥.០០០.០០០.០០០ (ប្រាំពាន់លាន) រៀល គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

២-ត្រូវបោះផ្សាយលក់មូលបត្រកម្មសិទ្ធិយ៉ាងតិច ២០ (ម្ភៃ) ភាគរយនៃមូលធនភាគហ៊ុនិកសរុប សម្រាប់ក្រុមហ៊ុនដែលមានមូលធនភាគហ៊ុនិកសរុបតិចជាង ២០.០០០.០០០.០០០

(ម្ភៃពាន់លាន) រៀល និងត្រូវបោះផ្សាយលក់មូលបត្រកម្មសិទ្ធិយ៉ាងតិច ១៥ (ដប់ប្រាំ) ភាគរយនៃមូលធនភាគហ៊ុនិកសរុប សម្រាប់ក្រុមហ៊ុនដែលមានមូលធនភាគហ៊ុនិកសរុបចាប់ពី ២០.០០០.០០០.០០០ (ម្ភៃពាន់លាន) រៀល ឡើងទៅ។

៣-ត្រូវមានប្រាក់ចំណេញសុទ្ធយ៉ាងតិចចំនួន ៥០០.០០០.០០០ (ប្រាំរយលាន) រៀល នៃឆ្នាំសារពើពន្ធមុនការដាក់ពាក្យស្នើសុំ និងមានផលចំណេញសរុបសម្រាប់រយៈពេល ០៣ (បី) ឆ្នាំនៃឆ្នាំសារពើពន្ធចុងក្រោយចំនួន ១.០០០.០០០.០០០ (មួយពាន់លាន) រៀល។

៤-ត្រូវទទួលបានការបញ្ជាក់ជាមុនពីទីផ្សារមូលបត្រប្រតិស្រុតពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ។

៥-ត្រូវទទួលបានការបញ្ជាក់ជាមុនដោយទីផ្សារមូលបត្រប្រតិស្រុតលើការដាក់តម្លៃមូលបត្រដែលធ្វើសំណើលក់។

**ប្រការ ៥.-**

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ដែលមានបំណងបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ត្រូវ ÷

១-ដាក់ពាក្យស្នើសុំតាមទម្រង់កំណត់ដោយ **គ.ម.ក.**។

២-ដាក់ឯកសារផ្តល់ព័ត៌មានតាមការកំណត់របស់ **គ.ម.ក.**។

៣-ដាក់ឯកសារភ្ជាប់ដូចមានកំណត់ក្នុងប្រកាសនេះ។

**ប្រការ ៦.-**

បុគ្គលដាក់ពាក្យស្នើសុំ ត្រូវសុំការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈនៅ **គ.ម.ក.** ដោយអនុលោមតាមមាត្រា ១២ នៃច្បាប់ និងមាត្រា ៩ មាត្រា ១០ មាត្រា ១១ និងមាត្រា ១៣ នៃអនុក្រឹត្យ។

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានដូចមានកំណត់ពីប្រការ ៧ ដល់ប្រការ ២៧ នៃប្រកាសនេះ។ ឯកសារផ្តល់ព័ត៌មានត្រូវមានហត្ថលេខារបស់ប្រធានក្រុមប្រឹក្សាភិបាល អភិបាលនាយកប្រតិបត្តិរបស់ក្រុមហ៊ុនបោះផ្សាយ និងនាយកហិរញ្ញវត្ថុ។

**ប្រការ ៧.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានមាតិកាដូចខាងក្រោម ÷

១-ព័ត៌មានទូទៅរបស់ក្រុមហ៊ុនបោះផ្សាយ

២-ព័ត៌មានស្តីពីកត្តាហានិភ័យ

៣-ការប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

៤-ផែនការវិនិយោគ

៥-ការពិពណ៌នាអំពីធុរកិច្ច

៦-ការពិពណ៌នាអំពីអចលកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយ

៧-ផែនការប្រតិបត្តិការ និងស្ថានភាពហិរញ្ញវត្ថុ

៨-ការវាយតម្លៃទ្រព្យសកម្ម និង/ឬការវាយតម្លៃទ្រព្យសកម្មឡើងវិញ

៩-ព័ត៌មានពាក់ព័ន្ធនឹងអភិបាល និងបុគ្គលិកជាន់ខ្ពស់

១០-ការជាប់ពាក់ព័ន្ធរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ក្នុងដំណើរការផ្លូវច្បាប់

១១-ទំនាក់ទំនង និងប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ

១២-ប្រាក់បំណាច់ ឬលាភការសម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់

១៣-សិទ្ធិទិញមូលបត្រកម្មសិទ្ធិដែលបានផ្តល់ទៅឱ្យអភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត

១៤-ប្រតិបត្តិការជាមួយអភិបាល និងភាគហ៊ុនិក

១៥-ទ្រព្យសកម្មសុទ្ធ និងប្រាក់ចំណេញក្នុងមួយឯកតានៃមូលបត្រកម្មសិទ្ធិ

១៦-កម្មសិទ្ធិនៃមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយ

១៧-ការដាក់តម្លៃមូលបត្រកម្មសិទ្ធិដើម្បីធ្វើសំណើលក់

១៨-ការពិពណ៌នាពីមូលបត្រកម្មសិទ្ធិដែលធ្វើសំណើលក់

១៩-ព័ត៌មានហិរញ្ញវត្ថុ និងរបាយការណ៍ហិរញ្ញវត្ថុ

២០-ព័ត៌មានហិរញ្ញវត្ថុរួម និងរបាយការណ៍ហិរញ្ញវត្ថុរួម។

**ប្រការ ៨.-**

ករណីសំណើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ពាក់ព័ន្ធនឹងផែនការវិនិយោគ ឬមានការពាក់ព័ន្ធនឹងផែនការវិនិយោគលើសពី ០១ (មួយ) ផែនការនីមួយៗ ត្រូវបង្ហាញដាច់ពីគ្នាជាទម្រង់ពេញលេញក្នុងឯកសារផ្តល់ព័ត៌មាន។

**ប្រការ ៩.-**

ឯកសារផ្តល់ព័ត៌មាន ត្រូវមានព័ត៌មានទូទៅដូចខាងក្រោម ៖

១-ឈ្មោះក្រុមហ៊ុនដាក់ពាក្យស្នើសុំ

២-ចំនួន និងប្រភេទមូលបត្រកម្មសិទ្ធិដែលត្រូវបោះផ្សាយ

៣-តម្លៃលក់មូលបត្រកម្មសិទ្ធិក្នុងមួយឯកតា និងតម្លៃសរុប

៤-ថ្ងៃបើក និងថ្ងៃបិទការធ្វើបរិវិសកម្ម

៥-ឈ្មោះ និងអាសយដ្ឋានក្រុមហ៊ុនមូលបត្រដែលធ្វើអាជីវកម្មធានាទិញ

៦-កាលបរិច្ឆេទចុះបញ្ជីឯកសារផ្តល់ព័ត៌មាន

៧-សេចក្តីបញ្ជាក់ថា "ព័ត៌មានដែលមាននៅក្នុងឯកសារផ្តល់ព័ត៌មានត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវទាំងស្រុងរបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ និងបុគ្គលពាក់ព័ន្ធ ក្នុងការរៀបចំឯកសារផ្តល់ព័ត៌មាននេះ"។

**ប្រការ ១០.-**

ឯកសារផ្តល់ព័ត៌មាន ត្រូវមានព័ត៌មានស្តីពីកត្តាហានិភ័យដូចខាងក្រោម ៖

១-ហានិភ័យអត្រាការប្រាក់

២-ហានិភ័យអត្រាប្តូរប្រាក់

៣-ហានិភ័យក្នុងវិស័យធុរកិច្ចរបស់ក្រុមហ៊ុនបោះផ្សាយ

៤-ហានិភ័យពាក់ព័ន្ធនឹងប្រតិបត្តិការធុរកិច្ច

៥-ហានិភ័យពាក់ព័ន្ធនឹងសកម្មភាពមិនមែនប្រតិបត្តិការធុរកិច្ចរបស់ក្រុមហ៊ុន

៦-ហានិភ័យពាក់ព័ន្ធនឹងទីផ្សារ និងបច្ចេកវិទ្យា

៧-ហានិភ័យពាក់ព័ន្ធនឹងការវិវត្តនៃបទប្បញ្ញត្តិ

៨-ហានិភ័យពាក់ព័ន្ធនឹងការវិវត្តនៃបរិការណ៍ជាតិ និងអន្តរជាតិ។

**ប្រការ ១១.-**

ឯកសារផ្តល់ព័ត៌មាន ត្រូវបង្ហាញពីការប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ដោយបញ្ជាក់ឱ្យ បានច្បាស់លាស់ពីចំនួនទឹកប្រាក់ដែលត្រូវប្រើប្រាស់សម្រាប់គោលដៅនីមួយៗ។

ឯកសារផ្តល់ព័ត៌មាន ត្រូវបង្ហាញពីដំណាក់កាលនានានៃការអនុវត្ត និងការប្រើប្រាស់សាច់ប្រាក់ដែលទទួលបានពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

ប្រសិនបើសាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ត្រូវប្រើប្រាស់ សម្រាប់ធានាចំណាយលើកិច្ចសន្យានៃសកម្មភាពណាមួយរបស់ក្រុមហ៊ុន

បោះផ្សាយ ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញពីរយៈពេលសុពលភាពនៃកិច្ចសន្យាទាំងនោះ និងត្រូវភ្ជាប់កិច្ចសន្យានោះជាឧបសម្ព័ន្ធរបស់ឯកសារផ្តល់ព័ត៌មានដែលស្នើសុំចុះបញ្ជីនេះ។

**ប្រការ ១២.-**

ឯកសារផ្តល់ពត៌មានត្រូវបញ្ជាក់ពីកាលបរិច្ឆេទចុះបញ្ជីពាណិជ្ជកម្ម និងកាលបរិច្ឆេទចាប់ផ្តើមប្រតិបត្តិការ របស់ក្រុមហ៊ុនបោះផ្សាយ ព្រមទាំងលក្ខណៈនៃធុរកិច្ចដែលក្រុមហ៊ុនបោះផ្សាយ និងសាខាក្រុមហ៊ុនបោះផ្សាយបានចូលរួម ឬនឹងចូលរួម។

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានសំខាន់ៗពាក់ព័ន្ធនឹងប្រតិបត្តិការធុរកិច្ចរបស់ក្រុមហ៊ុនបោះផ្សាយ ដូចជា ៖

១-ផលិតផលដែលជាទំនិញ ឬសេវាស្នូលរបស់ក្រុមហ៊ុនបោះផ្សាយ និងទីផ្សាររបស់ផលិតផលទាំងនោះនៅក្នុង ឬនៅក្រៅព្រះរាជាណាចក្រកម្ពុជា។

២-ទំហំនៃការលក់ផលិតផលផ្សេងទៀតដែលមិនមែនជាផលិតផលស្នូល ហើយទទួលបានប្រាក់ចំណូលលើសពី ១០ (ដប់) ភាគរយនៃប្រាក់ចំណូលសរុបរបស់ក្រុមហ៊ុនបោះផ្សាយ។

៣-ឈ្មោះក្រុមហ៊ុនបុត្រសម្ព័ន្ធ បុត្រសម្ព័ន្ធនៃក្រុមហ៊ុនបុត្រសម្ព័ន្ធ ក្រុមហ៊ុនហូលឌីងរបស់ក្រុមហ៊ុនបោះផ្សាយ ព្រមទាំងធុរកិច្ចស្នូលរបស់ក្រុមហ៊ុនទាំងនោះ។

៤-វិធីសាស្ត្រចែកចាយផលិតផល។

៥-ស្ថានភាពប្រកួតប្រជែងនៃធុរកិច្ចក្នុងទីផ្សារ។

៦-វត្ថុធាតុដើម ឬធាតុចូលផ្សេងៗដែលធានាដល់ដំណើរការផលិតកម្ម ឬសេវាកម្មរបស់ក្រុមហ៊ុនបោះផ្សាយ ព្រមទាំងប្រភព និងអ្នកផ្គត់ផ្គង់។

៧-តម្រូវការថាមពល ឧស្ម័ន ទឹក ឬសម្ភារៈប្រើប្រាស់ផ្សេងៗទៀតដែលចាំបាច់សម្រាប់ដំណើរការផលិតកម្ម ឬសេវាកម្មរបស់ក្រុមហ៊ុន ដោយបញ្ជាក់ពីប្រភព។

៨-ឈ្មោះអតិថិជនដែលទិញផលិតផល ឬសេវារបស់ក្រុមហ៊ុនបោះផ្សាយចាប់ពី ១០ (ដប់) ភាគរយឡើងទៅនៃផលិតផល ឬសេវាសរុប ដោយបញ្ជាក់ពីកិច្ចសន្យាដែលបានធ្វើ រួមមានចំនួនទឹកប្រាក់សរុប បរិមាណនៃប្រតិបត្តិការ និងរយៈពេលនៃកិច្ចសន្យា។

៩-ឈ្មោះអ្នកផ្គត់ផ្គង់ដែលលក់ផលិតផល ឬផ្តល់សេវាឱ្យក្រុមហ៊ុនបោះផ្សាយចាប់ពី ១០ (ដប់) ភាគរយឡើងទៅនៃផលិតផល ឬសេវាសរុបរបស់អ្នកផ្គត់ផ្គង់នោះ ដោយបញ្ជាក់ពីកិច្ចសន្យាដែលបានធ្វើ រួមមានចំនួនទឹកប្រាក់សរុប បរិមាណនៃប្រតិបត្តិការ និងរយៈពេលនៃកិច្ចសន្យា។

១០-ការពិពណ៌នាពីប្រកាសនីយបត្រតក្កកម្ម ម៉ាក ពាណិជ្ជនាម សិទ្ធិអាជីវកម្ម ឬកិច្ចព្រមព្រៀងផ្សេងទៀតពាក់ព័ន្ធនឹងសិទ្ធិកម្មសិទ្ធិបញ្ញា។

១១-ចំនួនបុគ្គលិកសរុប និងចំនួនបុគ្គលិកធ្វើការពេញម៉ោង។

១២-សក្តានុភាពនៃសមត្ថភាពផលិតកម្ម ឬសេវាកម្មរបស់ក្រុមហ៊ុនបោះផ្សាយ និងបញ្ជាក់ពីកម្រិតសមត្ថភាពដែលកំពុងប្រើប្រាស់នាពេលបច្ចុប្បន្ន។

១៣-ប្រសិនបើក្រុមហ៊ុនបោះផ្សាយជាក្រុមហ៊ុនហូលឌីង ឬក្រុមហ៊ុនបុត្រសម្ព័ន្ធ ឯកសារផ្តល់ពត៌មានត្រូវមានព័ត៌មានពេញលេញស្តីពីប្រតិបត្តិការសំខាន់រវាងក្រុមហ៊ុនបោះផ្សាយជាមួយនឹងក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីង ដោយបញ្ជាក់ពីលក្ខណៈនៃប្រតិបត្តិការ និងចំនួនទឹកប្រាក់ដែលបានធ្វើ ក្នុងរយៈពេល ០៣ (បី) ឆ្នាំ គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំធ្វើការបោះផ្សាយលក់មូលបត្រជាសាធារណៈ។

**ប្រការ ១៣.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានសំខាន់ពាក់ព័ន្ធនឹងអចលកម្មវត្ថុរបស់ក្រុមហ៊ុនបោះផ្សាយ ដូចខាងក្រោម ៖

១-ទីតាំងប្រតិបត្តិការ និងទីតាំងអចលកម្មវត្ថុរបស់ក្រុមហ៊ុនបោះផ្សាយ ព្រមទាំងលក្ខខណ្ឌនៃអចលកម្មវត្ថុទាំងនោះ។

២-សេចក្តីបញ្ជាក់អំពីកម្មសិទ្ធិលើអចលកម្មវត្ថុរបស់ក្រុមហ៊ុនបោះផ្សាយ។ ប្រសិនបើអចលកម្មវត្ថុទាំងនោះទទួលបានមកតាមរយៈការជួល ត្រូវមានការបញ្ជាក់ពីកាលបរិច្ឆេទផុតកំណត់នៃការជួល ព្រមទាំងឈ្មោះម្ចាស់អចលកម្មវត្ថុ។

៣-ការវាយតម្លៃលើអចលកម្មវត្ថុរបស់ក្រុមហ៊ុនបោះផ្សាយធ្វើឡើងដោយភ្នាក់ងារវាយតម្លៃដែលបានចុះបញ្ជីនៅ **គ.ម.ក.** ដោយភ្ជាប់មកជាមួយនូវរបាយការណ៍វាយតម្លៃ។

៤-ប្រសិនបើអចលកម្មវត្ថុដែលក្រុមហ៊ុនបោះផ្សាយកំពុងប្រើប្រាស់ ជាប់នូវប្រាតិភោគភណ្ឌិក ក្រុមហ៊ុនបោះផ្សាយត្រូវបញ្ជាក់ពីអត្តសញ្ញាណរបស់ម្ចាស់ទ្រព្យនោះ ព្រមទាំងតម្លៃដើម និងតម្លៃបច្ចុប្បន្នរបស់ប្រាតិភោគភណ្ឌិក។

**ប្រការ ១៤.-**

នៅក្នុងឯកសារផ្តល់ព័ត៌មាន បុគ្គលដាក់ពាក្យស្នើសុំត្រូវបង្ហាញផែនការប្រតិបត្តិការសង្ខេបសម្រាប់រយៈពេល ០៣ (បី) ឆ្នាំ ដូចខាងក្រោម ៖

១-ការប៉ាន់ស្មានចំណេញភាព និងចលនាសាច់ប្រាក់រយៈពេល ១២ (ដប់ពីរ) ខែ ដែលត្រូវបានពិនិត្យឡើងវិញ និងរាយការណ៍ដោយសវនករឯករាជ្យ។

២-ការរំពឹងទុកអំពីការផ្លាស់ប្តូរបុគ្គលិកចំនួនច្រើន។

៣-ប្រភពសាច់ប្រាក់ខាងក្នុង និងខាងក្រៅ។

៤-ការចំណាយមូលធនសំខាន់ៗ និងប្រភពមូលនិធិសម្រាប់ការចំណាយនោះ។

៥-មូលហេតុដែលបណ្តាលឱ្យមានការប្រែប្រួលពីពេលមួយទៅពេលមួយនៃប្រាក់ចំណូល ថ្លៃដើមទំនិញដែលបានលក់ ចំណាយប្រតិបត្តិការផ្សេងៗ និងចំណេញសុទ្ធ។

៦-និន្នាការតាមរដូវកាលនៃធុរកិច្ចរបស់ក្រុមហ៊ុនបោះផ្សាយ។

៧-និន្នាការ ព្រឹត្តិការណ៍ ឬភាពមិនប្រក្រតីណាមួយ ដែលមានផលប៉ះពាល់ខ្លាំងលើធុរកិច្ចរបស់ក្រុមហ៊ុនបោះផ្សាយក្នុងពេលអនាគត។

៨-រាល់ការផ្លាស់ប្តូរចំពោះទ្រព្យសកម្មរបស់ក្រុមហ៊ុនបោះផ្សាយ ដែលត្រូវប្រើប្រាស់សម្រាប់ទូទាត់បំណុល។

៩-សេចក្តីបញ្ជាក់ពីកម្ចីសំខាន់ៗ រវាងក្រុមហ៊ុនហូលឌីង និងក្រុមហ៊ុនបុត្រសម្ព័ន្ធនៅពេលដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

១០-រាល់កិច្ចសន្យាពាក់ព័ន្ធនឹងបំណុលនាពេលអនាគតដែលអាចកើតមាន និងផលប៉ះពាល់នៃបំណុលនោះលើស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបោះផ្សាយ។

១១-ចំណាយមូលធនជាំនស្នាន។

១២-រាល់អាករលើតម្លៃបន្ថែម ពន្ធលើប្រាក់ចំណេញ ពន្ធគយ ឬបំណុលពន្ធផ្សេងៗដែលមិនទាន់បានទូទាត់ រួមទាំងបំណុលជាយថាហេតុ ដោយបញ្ជាក់ពីមូលហេតុនៃការមិនទាន់បានទូទាត់មុនពេលចេញផ្សាយឯកសារផ្តល់ពត៌មាន។

១៣-សេចក្តីលម្អិតអំពីភតិសន្យាប្រតិបត្តិការសំខាន់ ដែលក្រុមហ៊ុនបោះផ្សាយបានចុះកិច្ចសន្យា ដោយបញ្ជាក់ឱ្យបានច្បាស់នូវលក្ខខណ្ឌនៃភតិសន្យា។

១៤-សេចក្តីលម្អិតអំពីបញ្ញត្តិនានាពាក់ព័ន្ធនឹងបុគ្គលិកក្រុមហ៊ុនបោះផ្សាយ។

១៥-សេចក្តីលម្អិតអំពីចំណាយទាំងអស់ ដែលពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ដោយបង្ហាញជាពិសេសនូវកម្រៃសម្រាប់ក្រុមហ៊ុនមូលបត្រដែលធ្វើអាជីវកម្មធានាទិញមូលបត្រ។

១៦-របាយការណ៍របស់សវនករពាក់ព័ន្ធនឹងគោលនយោបាយលើកទឹកចិត្តរបស់ក្រុមហ៊ុនបោះផ្សាយតាមរយៈការបែងចែងជាមូលបត្រកម្មសិទ្ធិ តម្លៃតបស្នង ឬជាសាច់ប្រាក់ដូចមានកំណត់ក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន។

**ប្រការ ១៥.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានសំខាន់ស្តីពីការវាយតម្លៃទ្រព្យសកម្ម និង/ឬការវាយតម្លៃទ្រព្យសកម្មឡើងវិញ។ ក្រុមហ៊ុនបោះផ្សាយត្រូវបង្ហាញឈ្មោះ គុណវុឌ្ឍិរបស់ភ្នាក់ងារវាយតម្លៃ និងហេតុផលនៃការវាយតម្លៃ ឬការវាយតម្លៃឡើងវិញ ដោយបង្ហាញពីតម្លៃទ្រព្យសកម្មមុនពេលធ្វើការវាយតម្លៃឡើងវិញ សមាសធាតុនៃទ្រព្យដែលបានវាយតម្លៃឡើងវិញ ត្រូវដាក់ដោយឡែកក្នុងលក្ខណៈមួយដែលជួយសម្រួលដល់ការប្រៀបធៀបរវាងតម្លៃចារឹក និងតម្លៃដែលបង្ហាញក្រោយពីបានវាយតម្លៃឡើងវិញ និងត្រូវភ្ជាប់មកជាមួយនូវរបាយការណ៍វាយតម្លៃ។

**ប្រការ ១៦.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានស្តីពីអភិបាល និងបុគ្គលិកជាន់ខ្ពស់ ដូចខាងក្រោម ៖

១-ជីវប្រវត្តិសង្ខេប ដោយមានបញ្ជាក់ពីឈ្មោះ អាយុ គុណវុឌ្ឍិ បទពិសោធន៍ និងតំណែងរបស់អភិបាលម្នាក់ៗរបស់ក្រុមហ៊ុនបោះផ្សាយ និងបុគ្គលដែលត្រូវបានតែងតាំងជាអភិបាល ដោយបង្ហាញពីអាណត្តិនៃការតែងតាំង និងស្ថាប័នដែលបានតែងតាំងអភិបាលនោះ។

២-កាលបរិច្ឆេទក្លាយជាអភិបាលរបស់ក្រុមហ៊ុនបោះផ្សាយជាលើកដំបូង និងកាលបរិច្ឆេទបញ្ចប់អាណត្តិបច្ចុប្បន្ន។

៣-ប្រសិនបើអភិបាលណាម្នាក់ ជាអភិបាល ជាភាគហ៊ុនិក ជាកម្មសិទ្ធិករ ឬជាសហកម្មសិទ្ធិកររបស់ក្រុមហ៊ុន ឬរបស់សហគ្រាសផ្សេងទៀត ត្រូវបង្ហាញឈ្មោះក្រុមហ៊ុនពាក់ព័ន្ធទាំងនោះ។

៤-ទំនាក់ទំនងសាច់ញាតិ ក្នុងចំណោមអភិបាល និងបុគ្គលិកជាន់ខ្ពស់។

៥-សេចក្តីបញ្ជាក់អំពីអសាធនភាពរបស់ភាគហ៊ុនិករបស់ក្រុមហ៊ុនបោះផ្សាយដែលកាន់កាប់ភាគហ៊ុនចាប់ពី ០៥ (ប្រាំ) ភាគរយឡើងទៅ ប្រសិនបើមាន។

៦-ឈ្មោះ រួមទាំងតំណែង គុណវុឌ្ឍិអប់រំ កាលបរិច្ឆេទចូលរួមជាមួយក្រុមហ៊ុនបោះផ្សាយ បទពិសោធន៍ ០៥ (ប្រាំ) ឆ្នាំចុងក្រោយរបស់អគ្គនាយក អគ្គនាយករង នាយក-ប្រតិបត្តិ នាយកហិរញ្ញវត្ថុ លេខាធិការក្រុមហ៊ុន អ្នកប្រឹក្សាយោបល់ និងអ្នកដែលមានមុខតំណែងសំខាន់ផ្សេងទៀតក្នុងក្រុមហ៊ុន។

ឯកសារដូចខាងក្រោម ត្រូវភ្ជាប់ទៅក្នុងឯកសារផ្តល់ព័ត៌មាន ៖

១-ក្រមសីលធម៌វិជ្ជាជីវៈសម្រាប់អភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ។

២-របាយការណ៍របស់អភិបាលស្តីពីការវាយតម្លៃស្ថានភាពរបស់ក្រុមហ៊ុនបោះផ្សាយ។

ប្រការ ១៧.-

ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញនូវព្រឹត្តិការណ៍ដែលបានកើតឡើងនៅក្នុងរយៈពេល ១០ (ដប់) ឆ្នាំចុងក្រោយ ដូចខាងក្រោម ÷

១-បណ្តឹងពាក់ព័ន្ធនឹងក្ស័យធន ធ្វើឡើងចំពោះក្រុមហ៊ុនដែលបុគ្គលិកជាន់ខ្ពស់ ឬអភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ ធ្លាប់ជាអភិបាល បុគ្គលិក ឬជាសហកម្មសិទ្ធិករ។

២-ការផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬកំពុងស្ថិតនៅក្នុងនីតិវិធីតុលាការចំពោះអភិបាល ឬបុគ្គលិកជាន់ខ្ពស់។

៣-ការសម្រេចជាស្ថាពរ ឬជាបណ្តោះអាសន្នរបស់តុលាការមានសមត្ថកិច្ច ចំពោះអភិបាល បុគ្គលិកជាន់ខ្ពស់ ដោយហាមឃាត់មិនឱ្យចូលរួម ឬដោយរារាំង ឬដោយព្យួរ ឬដោយដាក់កំហិតទៅលើអភិបាល ឬបុគ្គលិកជាន់ខ្ពស់នោះ នៅក្នុងសកម្មភាពមូលបត្រ ឬសកម្មភាពធុរកិច្ចណាមួយ។

៤-ការសម្រេចរបស់គណៈកម្មការមូលបត្រកម្ពុជា ឬគណៈកម្មការមូលបត្របរទេស ឬនិយ័តករនៃវិស័យផ្សេងទៀត ដោយហាមឃាត់មិនឱ្យចូលរួម ឬដោយរារាំង ឬដោយព្យួរ ឬដោយដាក់កំហិតទៅលើអភិបាល ឬបុគ្គលិកជាន់ខ្ពស់នៅក្នុងសកម្មភាពមូលបត្រ ឬសកម្មភាពធុរកិច្ចណាមួយ។

ប្រការ ១៨.-

ឯកសារផ្តល់ព័ត៌មានត្រូវពិពណ៌នាអំពីប្រតិបត្តិការសំខាន់ៗ ក្នុងរយៈពេល ០៣ (បី) ឆ្នាំចុងក្រោយ ដោយផ្តល់ឈ្មោះ ទំនាក់ទំនង ទំហំ និងប្រភេទនៃផលប្រយោជន៍ដែលកើតចេញពីទំនាក់ទំនងរវាងក្រុមហ៊ុនបោះផ្សាយជាមួយនឹងបុគ្គលជាប់ពាក់ព័ន្ធដូចខាងក្រោម ÷

១-អភិបាល ឬបុគ្គលិកជាន់ខ្ពស់ណាមួយ។

២-បុគ្គលដែលមានភាគហ៊ុនចាប់ពី ០៥ (ប្រាំ) ភាគរយឡើងទៅនៃមូលបត្រកម្មសិទ្ធិកំពុងធ្វើចរាចរនៅក្នុងទីផ្សារ។

៣-សមាជិកគ្រួសារផ្ទាល់ (រួមមាន ប្តី ប្រពន្ធ កូន ឪពុកម្តាយ បងប្អូនប្រុស ឬបងប្អូនស្រី) របស់បុគ្គលដែលចែងក្នុងចំណុចទី ១ និងទី ២ ខាងលើ។

៤-បុគ្គលមានទំនាក់ទំនងជាមួយអភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីងរបស់ក្រុមហ៊ុនបោះផ្សាយ ដែលទំនាក់ទំនងរបស់បុគ្គលទាំងនេះកើតមាននៅក្នុងប្រតិបត្តិការ ឬការចាត់ចែងណាមួយ ដែលបានធ្វើឡើងដោយក្រុមហ៊ុនបោះផ្សាយ។

៥-បុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធជាមួយបុគ្គលធ្លាប់ជាអភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ ដែលទំនាក់ទំនងកើតឡើងក្នុងក្របខ័ណ្ឌប្រតិបត្តិការរបស់ក្រុមហ៊ុនបោះផ្សាយ ក្នុងរយៈពេល ០២ (ពីរ) ឆ្នាំចុងក្រោយ គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

៦-អភិបាលដែលកាន់មុខតំណែងណាមួយនៅក្នុងសមាគម ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ឬនៅក្នុងក្រុមហ៊ុនណាមួយផ្សេងទៀតក្រៅពីក្រុមហ៊ុនបោះផ្សាយ។

៧-អភិបាលដែលទទួលបានផលប្រយោជន៍ពីក្រុមហ៊ុនបោះផ្សាយ ទោះជាហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុ។

### ប្រការ ១៩.-

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានពាក់ព័ន្ធនឹងប្រាក់បំណាច់ ឬលាភការសម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់ ដូចខាងក្រោម ÷

១-ចំនួនប្រាក់បំណាច់ ឬលាភការសរុបដែលបានបើកឱ្យបុគ្គលិកដែលទទួលបានប្រាក់បំណាច់ ឬលាភការខ្ពស់បំផុតចំនួន ០៥ (ប្រាំ) រូបរបស់ក្រុមហ៊ុនបោះផ្សាយ នៅឆ្នាំសារពើពន្ធចុងក្រោយ ដោយមានរាយនាម និងមុខតំណែងរបស់បុគ្គលិកជាន់ខ្ពស់បំផុតនោះ។

២-ចំនួនប្រាក់បំណាច់ ឬលាភការសរុបដែលបើកឱ្យអភិបាលមិនប្រតិបត្តិ នៅក្នុងឆ្នាំសារពើពន្ធចុងក្រោយ។

៣-ចំនួនប្រាក់បំណាច់ ឬលាភការជាកញ្ចប់ដែលបានបើកឱ្យអភិបាល និងបុគ្គលិកជាន់ខ្ពស់ នៅក្នុងឆ្នាំសារពើពន្ធចុងក្រោយ។

៤-ចំនួនប្រាក់បំណាច់ ឬលាភការសរុបសម្រាប់រយៈពេល ០១ (មួយ) ឆ្នាំខាងមុខដែលត្រូវផ្តល់ជូនអភិបាល ឬបុគ្គលិកជាន់ខ្ពស់។

៥-ប្រសិនបើក្រុមហ៊ុនបោះផ្សាយមានបំណងបង្កើនប្រាក់បំណាច់ ឬលាភការសរុបក្នុងចំនួនច្រើនដល់អភិបាល ឬបុគ្គលិករបស់ក្រុមហ៊ុន នៅក្នុងឆ្នាំសារពើពន្ធបច្ចុប្បន្ន ឬអនាគត ក្រុមហ៊ុនបោះផ្សាយត្រូវផ្តល់ព័ត៌មានពាក់ព័ន្ធក្នុងការបង្កើននោះ។

### ប្រការ ២០.-

ព័ត៌មានពាក់ព័ន្ធនឹងសិទ្ធិទិញមូលបត្រកម្មសិទ្ធិរបស់អភិបាល ឬបុគ្គលិក ត្រូវមាននៅក្នុងឯកសារផ្តល់ព័ត៌មាន ដោយត្រូវបញ្ជាក់ នូវ ÷

១-កាលបរិច្ឆេទដែលសិទ្ធិទិញមូលបត្រកម្មសិទ្ធិត្រូវបានផ្តល់ឱ្យ។

២-ថ្ងៃនៃមូលបត្រដែលត្រូវអនុវត្តសិទ្ធិទិញមូលបត្រកម្មសិទ្ធិ។

៣-ចំនួនមូលបត្រកម្មសិទ្ធិដែលពាក់ព័ន្ធនឹងការអនុវត្តសិទ្ធិទិញមូលបត្រកម្មសិទ្ធិ។

៤-ថ្ងៃទីផ្សាររបស់មូលបត្រកម្មសិទ្ធិនៅកាលបរិច្ឆេទដែលសិទ្ធិទិញមូលបត្រកម្មសិទ្ធិត្រូវបានផ្តល់ឱ្យ។

៥-កាលបរិច្ឆេទអស់សុពលភាពនៃសិទ្ធិទិញមូលបត្រកម្មសិទ្ធិ។

**ប្រការ ២១.-**

ករណីក្រុមហ៊ុនបោះផ្សាយមានប្រតិបត្តិការជាមួយអភិបាល និងភាគហ៊ុនិក ក្រុមហ៊ុនបោះផ្សាយត្រូវពិពណ៌នាក្នុងឯកសារផ្តល់ព័ត៌មាន នូវឈ្មោះរបស់អភិបាល និងភាគហ៊ុនិក ប្រភេទនិងតម្លៃនៃទ្រព្យសកម្ម សេវាកម្ម ប្រាក់បំណាច់ ឬលាភការដែលបានទទួល ឬផ្តល់ឱ្យក្រុមហ៊ុនបោះផ្សាយ ដោយផ្ទាល់ ឬដោយប្រយោល ក្នុងរយៈពេល ០៥ (ប្រាំ) ឆ្នាំចុងក្រោយ។

ប្រសិនបើក្រុមហ៊ុនបោះផ្សាយបានទិញ ឬនឹងទិញចលនទ្រព្យ និងអចលនទ្រព្យពីអភិបាល ឬភាគហ៊ុនិក ឯកសារផ្តល់ព័ត៌មានត្រូវមានបញ្ជាក់ពីវិធីសាស្ត្រនៃការកំណត់ថ្លៃ និងចំនួនទឹកប្រាក់ទូទាត់។

**ប្រការ ២២.-**

ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញពីទ្រព្យសកម្មសុទ្ធក្នុងមួយឯកតាមុន និងក្រោយការបោះផ្សាយ និងប្រាក់ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិដែលត្រូវបោះផ្សាយលក់ នៅកាលបរិច្ឆេទនៃតារាងតុល្យការចុងក្រោយ។

**ប្រការ ២៣.-**

ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញក្រោមទម្រង់ជាតារាង នូវឈ្មោះរបស់បុគ្គលដែលកាន់កាប់ចាប់ពី ០៥ (ប្រាំ) ភាគរយនៃមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយ ដោយត្រូវបញ្ជាក់ពីចំនួន និងភាគរយនៃមូលបត្រកម្មសិទ្ធិដែលបានកាន់កាប់។

ឯកសារផ្តល់ព័ត៌មានត្រូវមានតារាងដែលបង្ហាញពីចំនួនមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយដែលកាន់កាប់ដោយអភិបាលម្នាក់ៗ បុគ្គលិកដែលទទួលបានប្រាក់បំណាច់ ឬលាភការខ្ពស់បំផុតចំនួន ០៥ (ប្រាំ) រូប ដោយបញ្ជាក់ឈ្មោះ និងអាសយដ្ឋានរបស់ពួក

គេម្នាក់ៗ ព្រមទាំងបុគ្គលិកផ្សេងទៀត ក្រោមរូបភាពជាសរុប ដោយត្រូវបញ្ជាក់ជាភាគរយនៃមូលបត្រកម្មសិទ្ធិដែលបានកាន់កាប់ធៀបនឹងចំនួនមូលបត្រកម្មសិទ្ធិសរុបទាំងអស់ដែលកំពុងធ្វើចរាចរនៅលើទីផ្សារ។

**ប្រការ ២៤.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានការកំណត់នូវកត្តាដែលយកមកប្រើប្រាស់ ក្នុងការដាក់តម្លៃមូលបត្រកម្មសិទ្ធិដែលត្រូវបោះផ្សាយលក់ជាសាធារណៈ។

ប្រសិនបើថ្លៃលក់មូលបត្រកម្មសិទ្ធិខ្ពស់ជាងតម្លៃចារឹក ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញនូវអំណះអំណាងអំពីប្រាក់បង់លើស ដោយផ្អែកលើ ៖

១-តម្លៃទ្រព្យសកម្មសុទ្ធក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ ដោយឈរលើមូលដ្ឋានថ្លៃដើមប្រវត្តិសាស្ត្រ (Historical Cost) ឬថ្លៃដើមបច្ចុប្បន្ន (Current Cost)។

២-តម្លៃចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ ដែលគណនាដោយឈរលើមូលដ្ឋាននៃមធ្យមទម្ងន់នៃប្រាក់ចំណេញសុទ្ធក្រោយការបង់ពន្ធរយៈពេល ០៣ (បី) ឆ្នាំចុងក្រោយបន្តបន្ទាប់គ្នា ឬរយៈពេលខ្លីជាងនេះ ដោយគិតពីពេលចាប់ផ្តើមធ្វើប្រតិបត្តិការពាណិជ្ជកម្មរបស់ក្រុមហ៊ុនបោះផ្សាយ។

៣-តម្លៃចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិដែលប៉ាន់ស្មាន សម្រាប់រយៈពេល ០៣ (បី) ឆ្នាំនៃឆ្នាំសារពើពន្ធខាងមុខ ដោយឈរលើមូលដ្ឋានចំណេញប៉ាន់ស្មាន។ ការព្យាករណ៍ត្រូវតែធ្វើឡើងដោយក្រុមហ៊ុនបោះផ្សាយ ហើយត្រូវពិនិត្យឡើងវិញ និងរាយការណ៍ ដោយសវនករឯករាជ្យ។

៤-តម្លៃក្នុងមួយឯកតាគិតជាមធ្យមក្នុងទីផ្សារនៃមូលបត្រកម្មសិទ្ធិដែលមានលក្ខណៈប្រហាក់ប្រហែលគ្នាសម្រាប់រយៈពេល ០៦ (ប្រាំមួយ) ខែមុនការធ្វើសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ឬតម្លៃក្នុងមួយឯកតាគិតជាមធ្យមក្នុងទីផ្សារនៃមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយ ក្នុងរយៈពេល ០៦ (ប្រាំមួយ) ខែដូចគ្នា ក្នុងករណីការបោះផ្សាយនោះជាសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈឡើងវិញ។

៥-កត្តាផ្សេងទៀតដោយបញ្ជាក់អំណះអំណាងថាក្រុមហ៊ុនបោះផ្សាយធ្លាប់បានយកមកប្រើសម្រាប់កំណត់ប្រាក់បង់លើស។

៦-គំរូផ្សេងទៀតដែលកំណត់ដោយ **គ.ម.ក.** ក្នុងការគណនាតម្លៃក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ។

**ប្រការ ២៥.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានពាក់ព័ន្ធទៅនឹងសិទ្ធិផ្សេងៗភ្ជាប់ជាមួយមូលបត្រកម្មសិទ្ធិដែលជាកម្មវត្ថុនៃសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ដូចខាងក្រោម ÷

១-ពិពណ៌នាពីសិទ្ធិទទួលភាគលាភ និងសិទ្ធិបោះឆ្នោតនៃមូលបត្រកម្មសិទ្ធិដែលកំពុងចរាចរនៅលើទីផ្សារ ឬត្រូវបោះផ្សាយលក់។

២-ពិពណ៌នាពីសិទ្ធិទទួលភាគលាភ សិទ្ធិបោះឆ្នោត សិទ្ធិបរិវត្តន៍ និងសិទ្ធិជំរះបញ្ជីព្រមទាំងមូលនិធិសម្រាប់ទូទាត់សងភាគហ៊ុនបុរិមាដែលកំពុងចរាចរនៅលើទីផ្សារ ឬត្រូវបោះផ្សាយលក់។

៣-ប្រសិនបើមានការដាក់កំហិតណាមួយលើការបង់ភាគលាភទៅឱ្យអ្នកកាន់កាប់មូលបត្រកម្មសិទ្ធិដោយសារកិច្ចសន្យាបំណុលពាក់ព័ន្ធ ត្រូវពន្យល់ពីការដាក់កំហិតនោះ។

៤-ពិពណ៌នាពីសិទ្ធិសំខាន់ផ្សេងៗទៀតរបស់អ្នកកាន់កាប់មូលបត្រកម្មសិទ្ធិ។

**ប្រការ ២៦.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានហិរញ្ញវត្ថុប្រវត្តិសាស្ត្រ និងព័ត៌មានហិរញ្ញវត្ថុព្យាករណ៍ ដែលបំពេញតាមទម្រង់កំណត់ដោយ **គ.ម.ក.** ហើយត្រូវភ្ជាប់របាយការណ៍ហិរញ្ញវត្ថុដែលបានរៀបចំ និងធ្វើសវនកម្ម ស្របទៅតាមច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្ម គណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ សម្រាប់រយៈពេល ០៣ (បី) ឆ្នាំចុងក្រោយ។

**ប្រការ ២៧.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានហិរញ្ញវត្ថុប្រវត្តិសាស្ត្ររួម និងព័ត៌មានហិរញ្ញវត្ថុព្យាករណ៍រួម ដែលបំពេញតាមទម្រង់កំណត់ដោយ **គ.ម.ក.** ហើយត្រូវភ្ជាប់មករបាយការណ៍ហិរញ្ញវត្ថុរួមដែលរៀបចំ និងធ្វើសវនកម្ម ស្របតាមច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្ម គណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ សម្រាប់រយៈពេល ០៣ (បី) ឆ្នាំចុងក្រោយ។

**ប្រការ ២៨.-**

អនុលោមតាមមាត្រា ៩ និងមាត្រា ១០ នៃអនុក្រឹត្យ អ្នកជំនាញ ឬភាគីពាក់ព័ន្ធដែលបានផ្តល់នូវការយល់ព្រមជាលាយលក្ខណ៍អក្សរលើសេចក្តីថ្លែង ឬរបាយការណ៍ [illegible]

យោបល់ឱ្យធ្វើការផ្សព្វផ្សាយនៅក្នុងឯកសារផ្តល់ព័ត៌មាន ត្រូវទទួលខុសត្រូវលើសេចក្តីថ្លែងរបាយការណ៍ ឬយោបល់ដែលបានផ្តល់ឱ្យនោះ។

**ប្រការ ២៩.-**

ក្រុមហ៊ុនបោះផ្សាយត្រូវទទួលខុសត្រូវទាំងស្រុងចំពោះភាពត្រឹមត្រូវ ភាពគ្រប់គ្រាន់ និងភាពអាចជឿជាក់បាន នូវរាល់ព័ត៌មានដែលបានបង្ហាញនៅក្នុងឯកសារផ្តល់ព័ត៌មាន។

ក្រុមហ៊ុនមូលបត្រ និងបុគ្គលពាក់ព័ន្ធដទៃទៀត ដែលផ្តល់យោបល់ ឬព័ត៌មាន និងចូលរួមក្នុងការរៀបចំឯកសារផ្តល់ព័ត៌មានត្រូវទទួលខុសត្រូវចំពោះយោបល់ ឬព័ត៌មាន និងការចូលរួមនោះ។

**ប្រការ ៣០.-**

បុគ្គលដាក់ពាក្យស្នើសុំត្រូវភ្ជាប់មកជាមួយពាក្យស្នើសុំ នូវឯកសារដូចខាងក្រោម ៖

១-លក្ខន្តិកៈរបស់ក្រុមហ៊ុនបោះផ្សាយថតចម្លងដោយមានបញ្ជាក់ត្រឹមត្រូវ។

២-វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មថតចម្លងដោយមានបញ្ជាក់ត្រឹមត្រូវ។

៣-សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ទៅតាមការសម្រេចរបស់មហាសន្និបាតភាគហ៊ុនិក។

៤-លិខិតប្រគល់សិទ្ធិដោយមានបញ្ជាក់ពីតួនាទី និងភារកិច្ចជាអភិបាល ឬនាយកប្រតិបត្តិ ក្នុងការបម្រើការងារនៅក្នុងក្រុមហ៊ុនបោះផ្សាយ ដោយមានការចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាភិបាល និងអភិបាលទាំងអស់។

៥-កិច្ចព្រមព្រៀងពាក់ព័ន្ធនឹងកម្ចីផ្សេងៗដែលមាន។

៦-លិខិតបញ្ជាក់ពីធនាគារពាណិជ្ជស្តីពីការបើកគណនីដាច់ដោយឡែក សម្រាប់គោលបំណងបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

៧-កិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្រ។

៨-របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ (Due Diligence Report) ដែលចេញដោយក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្រ។

៩-លិខិតបញ្ជាក់ពីកិច្ចព្រមព្រៀងជាមួយភ្នាក់ងារបញ្ជិកាមូលបត្រ។

១០-លិខិតបញ្ជាក់ពីកិច្ចព្រមព្រៀងជាមួយភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ។

១១-លិខិតបញ្ជាក់ពីកិច្ចព្រមព្រៀងជាមួយភ្នាក់ងារទូទាត់ជំនួស។

១២-កិច្ចព្រមព្រៀងសំខាន់ៗវិនិយោគចម្រុះ ប្រសិនបើមាន។

១៣-លិខិតបញ្ជាក់ពីធនាគារពាណិជ្ជ ឬលិខិតបញ្ជាក់ពីសវនករនូវចំនួនទឹកប្រាក់តម្កល់សម្រាប់ធ្វើជាមូលធន។

១៤-របាយការណ៍អនុសាសន៍ស្តីពីការត្រួតពិនិត្យផ្ទៃក្នុងរបស់សវនករឯករាជ្យដែលមានគុណវុឌ្ឍិទទួលស្គាល់ដោយ **គ.ម.ក.**។

១៥-របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ពាក់ព័ន្ធនឹងកិច្ចការគណនេយ្យចេញដោយក្រុមហ៊ុនគណនេយ្យករជំនាញដែលមានគុណវុឌ្ឍិទទួលស្គាល់ដោយ **គ.ម.ក.**។

១៦-របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ចេញដោយមេធាវីដែលមានគុណវុឌ្ឍិទទួលស្គាល់ដោយ **គ.ម.ក.**។

### ប្រការ ៣១.-

អគ្គនាយកនៃ **គ.ម.ក.** ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់បុគ្គលដាក់ពាក្យស្នើសុំ ពីការមិនយល់ព្រម ឬការយល់ព្រមជាគោលការណ៍ លើការចុះបញ្ជីឯកសារផ្តល់ព័ត៌មានក្នុងរយៈពេល ០២ (ពីរ) ខែគិតចាប់ពីថ្ងៃទទួលបានឯកសារពេញលេញ។

### ប្រការ ៣២.-

អគ្គនាយកនៃ **គ.ម.ក.** អាចតម្រូវឱ្យបុគ្គលដាក់ពាក្យស្នើសុំ ផ្តល់ព័ត៌មានបន្ថែម ឬព័ត៌មានជំនួស ឬសេចក្តីបញ្ជាក់ ឬសេចក្តីបំភ្លឺ។ បុគ្គលដាក់ពាក្យស្នើសុំត្រូវបំពេញតាមសំណើនេះ ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ ឬក្នុងរយៈពេលដាក់លាក់ណាមួយដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.** គិតចាប់ពីថ្ងៃជូនដំណឹងជាលាយលក្ខណ៍អក្សរ។ ករណីបុគ្គលដាក់ពាក្យស្នើសុំមិនបំពេញបានទៅតាមសំណើខាងលើ អគ្គនាយកនៃ **គ.ម.ក.** អាចចាត់វិធានការទៅតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

### ប្រការ ៣៣.-

អគ្គនាយកនៃ **គ.ម.ក.** អាចបដិសេធលើសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈរបស់បុគ្គលដាក់ពាក្យស្នើសុំដោយផ្អែកលើមូលហេតុដូចខាងក្រោម ៖

១-បុគ្គលដាក់ពាក្យសុំមិនបំពេញតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ អនុក្រឹត្យ និងប្រកាសនេះ។

២-ព័ត៌មាន ឬឯកសារដែលបានដាក់ជូន **គ.ម.ក.** មានលក្ខណៈក្លែងបន្លំ ឬនាំឱ្យយល់ខុស។

៣-បុគ្គលដាក់ពាក្យស្នើសុំស្ថិតនៅក្នុងស្ថានភាពឈានទៅរកការបញ្ឈប់ធុរកិច្ច ឬការរំលាយ។

៤-ការមិនអនុវត្តតាមទាំងស្រុង ឬមួយផ្នែក នូវសេចក្តីសម្រេចរបស់តុលាការដែលតម្រូវឱ្យបុគ្គលដាក់ពាក្យស្នើសុំខ្ញុំទាត់សងបំណុល។

៥-បុគ្គលដាក់ពាក្យស្នើសុំ ឬអភិបាលណាម្នាក់ នាយកប្រតិបត្តិ អ្នកគ្រប់គ្រង ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់របស់បុគ្គលដាក់ពាក្យស្នើសុំ ÷

ក-មិនមានលក្ខណសម្បត្តិ និងអត្តចរិតល្អ ស្របតាមអនុក្រឹត្យ។

ខ-បានធ្វើ ឬជាប់ពាក់ព័ន្ធនឹងអាជីវកម្មណាមួយផ្សេងទៀតដែលធ្វើឱ្យមានការសង្ស័យចំពោះសមត្ថភាព និងសុក្រឹតភាពនៃសេចក្តីសម្រេចរបស់ខ្លួន។

គ-បានធ្វើអាជីវកម្មដែលមានលក្ខណៈបោកបញ្ឆោត ឬកេងប្រវ័ញ្ច ឬមិនត្រឹមត្រូវដោយប្រការណាមួយ។

ឃ-ស្តែងចេញនូវភាពមិនអាចធ្វើសកម្មភាព ដើម្បីផលប្រយោជន៍អតិថិជនរបស់ខ្លួន ដោយសារតែកេរ្តិ៍ឈ្មោះ បុគ្គលិកលក្ខណៈ សេចក្តីសុចរិតផ្នែកហិរញ្ញវត្ថុ និងភាពដែលអាចទុកចិត្តបានរបស់បុគ្គលទាំងនោះ។

ង-ស្តែងចេញនូវភាពមិនអាចធ្វើអាជីវកម្មបាន ក្រោមលក្ខខណ្ឌអាជ្ញាបណ្ណ ឬការអនុញ្ញាត ប្រកបដោយប្រសិទ្ធភាព ភាពស្មោះត្រង់ ឬយុត្តិធម៌។

៦-អភិបាល នាយកប្រតិបត្តិ អ្នកគ្រប់គ្រង ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់របស់បុគ្គលដាក់ពាក្យស្នើសុំ ធ្លាប់កាន់មុខតំណែងទាំងនេះនៅក្នុងក្រុមហ៊ុនដែលត្រូវបានប្រកាសក្ស័យធន នៅក្នុង ឬនៅក្រៅព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេល ០៥ (ប្រាំ) ឆ្នាំចុងក្រោយគិតមកត្រឹមកាលបរិច្ឆេទដាក់ពាក្យស្នើសុំ។

៧-ស្ថានភាពហិរញ្ញវត្ថុ ឬវិធីធ្វើអាជីវកម្មរបស់បុគ្គលដាក់ពាក្យស្នើសុំ មិនទាន់មានលក្ខណៈគ្រប់គ្រាន់ ដើម្បីធានានូវដំណើរការនៃធុរកិច្ចប្រកបដោយចីរភាព និងភាពទុកចិត្ត។

៨-នៅពេលកើតមានហេតុការណ៍ណាមួយដែលនាំឱ្យ ÷

ក-អភិបាល នាយកប្រតិបត្តិ អ្នកគ្រប់គ្រង ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់របស់បុគ្គលដាក់ពាក្យស្នើសុំ មិនអាចដំណើរការអាជីវកម្មបានត្រឹមត្រូវ។

ខ-មានភាពមិនអាចជឿជាក់បានលើវិធីធ្វើអាជីវកម្មរបស់បុគ្គលដាក់ពាក្យស្នើសុំ។

ឥ-ការផ្តល់ការអនុញ្ញាតដល់បុគ្គលដាក់ពាក្យស្នើសុំ នឹងនាំឱ្យមានផលប៉ះពាល់ដល់ប្រយោជន៍សាធារណៈ ដោយត្រូវពិចារណាលើលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ១៤ នៃច្បាប់។

## ជំពូកទី ៣
## ការដាក់លក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

**ប្រការ ៣៤.-**

បុគ្គលដាក់ពាក្យស្នើសុំដែលទទួលបានការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ អាចចាប់ផ្តើមធ្វើសំណើលក់មូលបត្រជាសាធារណៈបាន បន្ទាប់ពី ៖

១-បានរៀបចំលក្ខខណ្ឌនៃសំណើលក់ រួមទាំងការកំណត់ថ្លៃលក់មូលបត្រដែលការកំណត់ថ្លៃលក់មូលបត្រនេះត្រូវមានការបញ្ជាក់យល់ព្រមពីប្រតិបត្តិករទីផ្សារមូលបត្រ។

២-បានទទួលការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់មូលបត្រកម្មសិទ្ធិជាសាធារណៈដូចក្នុងចំណុចទី ១ ខាងលើ ពីអគ្គនាយកនៃ **គ.មូ.ក.** ស្របតាមមាត្រា ១២ នៃអនុក្រឹត្យ។

៣-បានទទួលការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានរបស់បុគ្គលដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈនៅ **គ.មូ.ក.**។

**ប្រការ ៣៥.-**

បន្ទាប់ពីបានទទួលការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន ការធ្វើបរិវិសកម្មត្រូវចាប់ផ្តើមក្នុងអំឡុងពេលដែលឯកសារផ្តល់ព័ត៌មាននៅមានសុពលភាព សម្រាប់រយៈពេលដូចកំណត់ក្នុងចំណុចទី ៣ នៃមាត្រា ៧ នៃអនុក្រឹត្យ។ នៅពេលការធ្វើបរិវិសកម្មត្រូវបានបញ្ចប់ពេញលេញ ក្រុមហ៊ុនបោះផ្សាយត្រូវផ្តល់របាយការណ៍ស្តីអំពីការធ្វើបរិវិសកម្មនោះភ្លាមមក **គ.មូ.ក.**។

ការធ្វើបរិវិសកម្មត្រូវធ្វើឡើងតាមរយៈក្រុមហ៊ុនមូលបត្រដែលមានអាជ្ញាបណ្ណពី **គ.មូ.ក.** ដូចមានចែងក្នុងមាត្រា ១៦ និងមាត្រា ១៧ នៃអនុក្រឹត្យ។ ក្រុមហ៊ុនមូលបត្រត្រូវតែរក្សា

ទុកប្រាក់ដែលទទួលបានពីការធ្វើបរិវិសកម្មក្នុងគណនីដោយឡែក នៅធនាគារពាណិជ្ជដូច មានចែងក្នុងមាត្រា ១៨ នៃអនុក្រឹត្យ។ ចំនួន និងបញ្ជីឈ្មោះរបស់អ្នកធ្វើបរិវិសកម្មត្រូវតែរក្សាទុកនៅភ្នាក់ងារបញ្ជិកាមូលបត្រ។

ទម្រង់នៃពាក្យស្នើសុំធ្វើបរិវិសកម្មត្រូវកំណត់ដោយ **គ.ម.ក.**។ ការធ្វើបរិវិសកម្មនីមួយៗ ត្រូវចាត់ទុកថាបានបញ្ចប់ នៅពេលអ្នកធ្វើបរិវិសកម្មបានបំពេញត្រឹមត្រូវ តាមទម្រង់នៃពាក្យស្នើសុំធ្វើបរិវិសកម្ម បានបង់ប្រាក់គ្រប់ចំនួន និងទទួលបានបង្កាន់ដៃដែលចេញដោយក្រុមហ៊ុនមូលបត្រ។ អ្នកធ្វើបរិវិសកម្មមិនអាចដកប្រាក់ដែលបានធ្វើបរិវិសកម្មនោះវិញបានទេ លើកលែងតែករណីដូចមានចែងក្នុងចំណុចទី ៤ "ខ" នៃមាត្រា ៧ និងចំណុចទី ២ នៃមាត្រា ១៨ នៃអនុក្រឹត្យ និងប្រការ ៣៩ និងប្រការ ៤០ នៃប្រកាសនេះ។

**ប្រការ ៣៦.-**

ក្រោយពេលបញ្ចប់កាលបរិច្ឆេទធ្វើបរិវិសកម្ម ករណីមូលបត្រកម្មសិទ្ធិធ្វើបរិវិសកម្មមិនអស់ ក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្ររបស់ក្រុមហ៊ុនបោះផ្សាយត្រូវធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិដែលនៅសល់ទាំងអស់នោះ និងទូទាត់គ្រប់ចំនួនជាសាច់ប្រាក់ ឬឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀតដូចដែលមានចែងក្នុងមាត្រា ៨ នៃអនុក្រឹត្យ ឱ្យក្រុមហ៊ុនបោះផ្សាយក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការបិទការដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម។ ក្រុមហ៊ុនបោះផ្សាយត្រូវផ្តល់របាយការណ៍អំពីការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិដែលនៅសល់ មក **គ.ម.ក.** ភ្លាម។

**ប្រការ ៣៧.-**

ការធ្វើបរិវិសកម្មត្រូវបានកំណត់ដូចខាងក្រោម ÷

១-២០ (ម្ភៃ) ភាគរយនៃសំណើលក់ជាសាធារណៈសរុប ត្រូវបានបម្រុងសម្រាប់អ្នកវិនិយោគសញ្ជាតិខ្មែរ។

២-៨០ (ប៉ែតសិប) ភាគរយដែលនៅសល់ ត្រូវបើកចំហចំពោះអ្នកវិនិយោគសញ្ជាតិខ្មែរ និងអ្នកវិនិយោគមិនមែនសញ្ជាតិខ្មែរ។

ករណីការធ្វើបរិវិសកម្មមិនអាចសម្រេចបានតាមការកំណត់ខាងលើ អគ្គនាយកនៃ **គ.ម.ក.** អាចធ្វើការកំណត់នូវការបែងចែកឡើងវិញ ដើម្បីធានាភាពជោគជ័យនៃសំណើបោះផ្សាយ និងលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

**ប្រការ ៣៨.-**

ក្រុមហ៊ុនមូលបត្រ ត្រូវចែកចាយលក់មូលបត្រកម្មសិទ្ធិក្នុងថ្ងៃដែលបានកំណត់នៅក្នុងឯកសារផ្តល់ព័ត៌មានដែលបានចុះបញ្ជីរួចនៅ **គ.ម.ក.**។

ក្រុមហ៊ុនបោះផ្សាយ ភ្នាក់ងារបញ្ជីកាមូលបត្រ ឬក្រុមហ៊ុនមូលបត្រ ត្រូវបញ្ជូនមូលបត្រកម្មសិទ្ធិ ឬវិញ្ញាបនបត្រមូលបត្រកម្មសិទ្ធិទៅឱ្យអ្នកធ្វើបរិវិសកម្មក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការគិតចាប់ពីកាលបរិច្ឆេទបញ្ចប់ការធ្វើបរិវិសកម្ម។

**ប្រការ ៣៩.-**

អនុលោមតាមមាត្រា ២១ នៃច្បាប់ ឯកសារផ្តល់ព័ត៌មានដែលបានចុះបញ្ជីរួចអាចត្រូវបានព្យួរដោយអគ្គនាយកនៃ **គ.ម.ក.**។ ករណីនេះ ក្រុមហ៊ុនបោះផ្សាយ និងក្រុមហ៊ុនមូលបត្រ ត្រូវបញ្ឈប់ទទួលពាក្យស្នើសុំធ្វើបរិវិសកម្មមូលបត្រ និងជូនដំណឹងអំពីការព្យួរនេះភ្លាមដល់អ្នកធ្វើបរិវិសកម្ម និងសាធារណជន។ ក្រុមហ៊ុនបោះផ្សាយ និងក្រុមហ៊ុនមូលបត្រត្រូវបញ្ជាក់ជូនអ្នកធ្វើបរិវិសកម្មថាអាចមានសិទ្ធិដកស្ទីការដែលបានធ្វើ ចំពោះសំណើលក់ជាសាធារណៈ និងអាចទទួលប្រាក់ដែលបានបង់នោះមកវិញ។ ក្រុមហ៊ុនបោះផ្សាយ និងក្រុមហ៊ុនមូលបត្រ អាចបន្តទទួលពាក្យស្នើសុំធ្វើបរិវិសកម្មឡើងវិញ បន្ទាប់ពីបញ្ហាដែលបណ្តាលឱ្យមានការព្យួរត្រូវបានដោះស្រាយ និងមានការអនុញ្ញាតឡើងវិញពីអគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ៤០.-**

ក្រុមហ៊ុនបោះផ្សាយត្រូវផ្សព្វផ្សាយភ្លាមៗអំពីការលុបចោលនូវការចុះបញ្ជីឯកសារផ្តល់ព័ត៌មានដល់សាធារណជន តាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដែលទទួលស្គាល់ពីអគ្គនាយកនៃ **គ.ម.ក.** ដោយត្រូវបញ្ជាក់នូវចំណុចដូចខាងក្រោម ៖

១-លេខសេរី និងកាលបរិច្ឆេទនៃការសម្រេចលុបចោលនូវការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន។

២-មូលហេតុនៃការលុបចោលនូវការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន។

៣-ពេលវេលា ទីកន្លែង និងរបៀបទូទាត់នៃការបង្វិលប្រាក់សងដល់អ្នកបានធ្វើបរិវិសកម្មដែលបានបង់ ឬបានតម្កល់សម្រាប់ការធ្វើបរិវិសកម្ម។ ពេលវេលានៃការបង្វិលសងនេះ ត្រូវធ្វើឡើងយ៉ាងយូរក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទសម្រេចលុបចោលនូវការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន។

៤-ព័ត៌មានផ្សេងទៀតតាមការណែនាំរបស់អគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ៤១.-**

ការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន អាចត្រូវបានលុបចោលផងដែរ ក្នុងករណីដែលការធ្វើបរិវិសកម្មមិនបានជោគជ័យ ឬនៅពេលក្រុមហ៊ុនបោះផ្សាយមិនអាចបញ្ចប់ការចែកចាយមូលបត្រកម្មសិទ្ធិអស់ តាមពេលកំណត់ដូចមានចែងក្នុងប្រកាសនេះ។

**ប្រការ ៤២.-**

ក្រុមហ៊ុនបោះផ្សាយត្រូវរាយការណ៍ពីលទ្ធផលនៃការបោះផ្សាយ និងលក់មូលបត្រកម្មសិទ្ធិជាសាធារណៈដែលត្រូវធ្វើឡើងក្នុងទម្រង់ដែលកំណត់ដោយ **គ.ម.ក.** ដោយត្រូវភ្ជាប់មកជាមួយនូវលិខិតជាលាយលក្ខណ៍អក្សររបស់ធនាគារពាណិជ្ជ អំពីចំនួនទឹកប្រាក់នៅក្នុងគណនីដោយឡែកដែលបង្កើតឡើងសម្រាប់គោលបំណងនៃការបោះផ្សាយនេះ។

**ប្រការ ៤៣.-**

ក្រុមហ៊ុនបោះផ្សាយត្រូវបំពេញនីតិវិធីនៅទីផ្សារមូលបត្រប្រតិស្រុត ក្នុងរយៈពេល ០៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីមូលបត្រកម្មសិទ្ធិ ឬវិញ្ញាបនបត្រមូលបត្រកម្មសិទ្ធិត្រូវបានបញ្ជូនទៅអ្នកធ្វើបរិវិសកម្ម ដូចមានកំណត់ក្នុងប្រការ ៣៩ នៃប្រកាសនេះដើម្បីចុះបញ្ជីជួញដូរមូលបត្រជាផ្លូវការនៅទីផ្សារមូលបត្រប្រតិស្រុត។

**ប្រការ ៤៤.-**

ក្រុមហ៊ុនបោះផ្សាយ ត្រូវអនុវត្តឱ្យបានពេញលេញនូវកាតព្វកិច្ចដូចមានចែងក្នុងជំពូកទី ៦ នៃច្បាប់ អនុក្រឹត្យ និងបទប្បញ្ញត្តិផ្សេងទៀតដែលកំណត់ដោយ **គ.ម.ក.**។

## ជំពូកទី ៤
## ការផ្សាយពាណិជ្ជកម្ម និងការផ្សព្វផ្សាយជាសាធារណៈ

**ប្រការ ៤៥.-**

ការផ្សាយពាណិជ្ជកម្ម ឬការផ្សព្វផ្សាយព័ត៌មាន ឬការផ្សព្វផ្សាយសេចក្តីថ្លែងទាំងឡាយណាដែលពាក់ព័ន្ធដោយផ្ទាល់ ឬដោយប្រយោលទៅនឹងសំណើបោះផ្សាយ និងលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ត្រូវធ្វើឡើងស្របតាមលក្ខខណ្ឌតម្រូវដូចមានចែងក្នុងមាត្រា ១៤ នៃអនុក្រឹត្យ និងត្រូវមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអគ្គនាយកនៃ **គ.ម.ក.** ស្របតាមមាត្រា ១៥ នៃអនុក្រឹត្យ។

ក្រុមហ៊ុនបោះផ្សាយត្រូវតែរៀបចំឯកសារផ្តល់ព័ត៌មាន ដើម្បីត្រៀមទុកផ្តល់ឱ្យសាធារណជន នៅក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនបោះផ្សាយ ប្រតិបត្តិករទីផ្សារមូលបត្រ និងនៅ **គ.ម.ក.** ក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីបានទទួលបានការយល់ព្រមពីអគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ៤៦.-**

រយៈពេលយ៉ាងតិច ០៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការមុនថ្ងៃចាប់ផ្តើមធ្វើបរិវិសកម្ម ក្រុមហ៊ុនបោះផ្សាយត្រូវជូនដំណឹងជាផ្លូវការ តាមរយៈសារព័ត៌មាន និងឧបករណ៍ផ្សព្វផ្សាយដែលទទួលស្គាល់ដោយអគ្គនាយកនៃ **គ.ម.ក.** ដោយបញ្ជាក់នូវព័ត៌មានដូចខាងក្រោម ៖

១-ឈ្មោះ និងប្រទេស ឬស្ថាប័នផ្សេងៗទៀត របស់ក្រុមហ៊ុនបោះផ្សាយ។

២-ចំនួន និងឈ្មោះមូលបត្រកម្មសិទ្ធិដែលនឹងត្រូវធ្វើសំណើលក់។

៣-ទីកន្លែងដែលសាធារណជនអាចទទួលបានឯកសារផ្តល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្ម។

៤-កាលបរិច្ឆេទនៃការផ្សព្វផ្សាយជាសាធារណៈនៃការជូនដំណឹងអំពីការធ្វើបរិវិសកម្មជាផ្លូវការ។

៥-សេចក្តីថ្លែង ដើម្បីឱ្យសាធារណជនដឹងថាសំណើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិត្រូវបានទទួលការយល់ព្រមជាគោលការណ៍ពី **គ.ម.ក.** រួចហើយ។

៦-សេចក្តីថ្លែង ដើម្បីឱ្យសាធារណជនដឹងថាការជូនដំណឹងជាផ្លូវការនេះមានគោលបំណងផ្តល់ព័ត៌មានតែប៉ុណ្ណោះ មិនមែនដើម្បីអញ្ជើញឱ្យធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិឡើយ។

៧-កាលបរិច្ឆេទដែលការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ នឹងចាប់ផ្តើម។

៨-សេចក្តីថ្លែងដែលបញ្ជាក់ថាអ្នកដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម ត្រូវពិចារណា ដោយផ្អែកទៅលើឯកសារផ្តល់ព័ត៌មាន។

ឯកសារផ្តល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្មដែលត្រូវផ្សព្វផ្សាយ ត្រូវធ្វើឡើងក្នុងទម្រង់បោះពុម្ព។ បន្ថែមលើនេះ ក្រុមហ៊ុនបោះផ្សាយអាចផ្សព្វផ្សាយឯកសារផ្តល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្មក្នុងទម្រង់អេឡិចត្រូនិក ប៉ុន្តែក្រុមហ៊ុនបោះផ្សាយត្រូវរក្សាខ្លឹមសារនៃឯកសារផ្តល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្មក្នុងទម្រង់អេឡិចត្រូនិកឱ្យដូចគ្នានឹងឯកសារផ្តល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្មក្នុងទម្រង់បោះពុម្ព។

## ជំពូកទី ៥
## តម្លៃសេវាក្នុងការចុះបញ្ជី

**ប្រការ ៤៧.-**

បុគ្គលដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ត្រូវបង់ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សានិងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន នៅពេលដាក់ពាក្យស្នើសុំឱ្យ **គ.ម.ក.** ដូចខាងក្រោម ÷

១-ជាសាច់ប្រាក់ចំនួន ១២.០០០.០០០ (ដប់ពីរលាន) រៀល ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មីជាសាធារណៈ។

២-ជាសាច់ប្រាក់ចំនួន ៨.០០០.០០០ (ប្រាំបីលាន) រៀល ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈបន្ថែម។

**ប្រការ ៤៨.-**

បុគ្គលដាក់ពាក្យស្នើសុំធ្វើការពិនិត្យ និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានបន្ថែម ត្រូវបង់សោហ៊ុយ សម្រាប់ការពិនិត្យ និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានបន្ថែម នៅពេលដាក់ពាក្យស្នើសុំ ឱ្យ **គ.ម.ក.** ដូចខាងក្រោម ÷

១-ជាសាច់ប្រាក់ចំនួន ១.២០០.០០០ (មួយលានពីរសែន) រៀល ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មីជាសាធារណៈ។

២-ជាសាច់ប្រាក់ចំនួន ៨០០.០០០ (ប្រាំបីសែន) រៀល ករណីសំណើបោះផ្សាយ-លក់មូលបត្រកម្មសិទ្ធិជាសាធារណៈបន្ថែម។

**ប្រការ ៤៩.-**

បុគ្គលដាក់ពាក្យស្នើសុំដែលមានបំណងឱ្យ **គ.ម.ក.** ធ្វើការពិនិត្យឡើងវិញចំពោះសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈដែលអស់សុពលភាព ត្រូវបង់សោហ៊ុយពិនិត្យឡើងវិញ នៅពេលដាក់ពាក្យស្នើសុំ ឱ្យ **គ.ម.ក.** ដូចខាងក្រោម ÷

១-ជាសាច់ប្រាក់ចំនួន ៦.០០០.០០០ (ប្រាំមួយលាន) រៀល ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មីជាសាធារណៈ។

២-ជាសាច់ប្រាក់ចំនួន ៤.០០០.០០០ (បួនលាន) រៀល ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈបន្ថែម។

**ប្រការ ៥០.-**

ថ្លៃពាក្យស្នើសុំ និងសោហ៊ុយដូចមានចែងក្នុងប្រការ ៤៧ ប្រការ ៤៨ និងប្រការ ៤៩ នៃប្រកាសនេះ មិនត្រូវបានប្រគល់ឱ្យបុគ្គលដាក់ពាក្យស្នើសុំវិញឡើយ ទោះជាឯកសារផ្តល់ព័ត៌មានទទួលបានការអនុញ្ញាត និងចុះបញ្ជី ឬត្រូវបានបដិសេធក៏ដោយ។

**ជំពូកទី ៦**

**ទោសប្បញ្ញត្តិ**

**ប្រការ ៥១.-**

បុគ្គលដែលបំពានលើបញ្ញត្តិនៃប្រកាសនេះ ត្រូវទទួលរងនូវទណ្ឌកម្មរដ្ឋបាលដូចខាងក្រោម ៖

១-ការស្នើឱ្យដាក់អនុស្សារណៈ។

២-ការព្រមាន ឬការដាស់តឿន។

៣-ការកត់សម្គាល់ជាសាធារណៈ ហើយបញ្ជាឱ្យធ្វើការកែតម្រូវ។

៤-ការដាក់កំហិតលើការបោះផ្សាយមូលបត្រកម្មសិទ្ធិ។

៥-ការផ្តល់អនុសាសន៍លើការបណ្តេញអភិបាល ឬបុគ្គលិកជាន់ខ្ពស់។

៦-ការប្រកាសជាសាធារណៈនូវទណ្ឌកម្មរបស់បុគ្គលដែលប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

៧-ការព្យួរ ឬហាមឃាត់នូវការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ឬការចែកចាយបន្ទាប់។

**ប្រការ ៥២.-**

ដោយមិនទាន់គិតពីទោសទណ្ឌផ្សេងទៀតដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាននៅព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនបោះផ្សាយ ឬក្រុមហ៊ុនមូលបត្រដែលធ្វើអាជីវកម្មធានាទិញមូលបត្រ ឬអ្នកជំនាញ ឬភាគីពាក់ព័ន្ធ ដែលប្រព្រឹត្តល្មើសនឹងប្រកាសនេះ ត្រូវទទួលពិន័យអន្តរការណ៍ពី **គ.ម.ក.** ជាប្រាក់ពី ១៥.០០០.០០០ (ដប់ប្រាំលាន) រៀល ដល់ ៣០.០០០.០០០ (សាមសិបលាន) រៀល។

## ជំពូកទី ៧
## អវសានប្បញ្ញត្តិ

**ប្រការ ៥៣.-**

គ.ម.ក. អាចចេញគោលការណ៍ណែនាំ ដើម្បីសម្រួលការយល់ដឹង និងការអនុវត្តតាមលក្ខខណ្ឌនៃប្រកាសនេះ ដល់បុគ្គលពាក់ព័ន្ធ អ្នកចូលរួមក្នុងទីផ្សារមូលបត្រ និងដល់សាធារណជន។

**ប្រការ ៥៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥៥.-**

អគ្គនាយក អគ្គនាយករងនៃគណៈកម្មការមូលបត្រកម្ពុជា នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ នាយកដ្ឋាន អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា និងបុគ្គលពាក់ព័ន្ធត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ២០១០

គាត ឈន់

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
 នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
-ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងយុត្តិធម៌
-ធនាគារជាតិនៃកម្ពុជា
-គណៈកម្មការមូលបត្រកម្ពុជា
 "ដើម្បីជូនជ្រាប"
-ដូចប្រការ ៥៥
 "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ពុទ្ធិមូលបត្រ

លេខ VIII ចេញផ្សាយប្រចាំសប្តាហ៍ទី ៣ ខែតុលា ឆ្នាំ២០១៦

# ភាពខុសគ្នារវាងមូលបត្របំណុល និងមូលបត្រកម្មសិទ្ធិ

វិនិយោគិនតែងត្រូវបានផ្តល់យោបល់ ឱ្យធ្វើពិពិធកម្មរវាងមូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) និងមូលបត្របំណុល (សញ្ញាបណ្ណ) ក្នុងការវិនិយោគរបស់ពួកគេ។ ប៉ុន្តែ តើអ្វីទៅដែលជាភាពខុសគ្នា រវាងប្រភេទនៃការវិនិយោគទាំងពីរនេះ? អត្ថបទនេះ នឹងបកស្រាយពីភាពខុសគ្នារវាងភាគហ៊ុន និងសញ្ញាបណ្ណក្នុងកម្រិតមូលដ្ឋានបំផុត។



រូបភាព: Zack Blanton / Getty Images

ភាគហ៊ុន (Stock) ជាចំណែកនៃកម្មសិទ្ធិក្នុងក្រុមហ៊ុន។ នៅពេលដែលក្រុមហ៊ុនមួយបោះផ្សាយលក់ភាគហ៊ុន គឺមានន័យថា ក្រុមហ៊ុនបានលក់ចំណែកនៃក្រុមហ៊ុនរបស់ខ្លួនដើម្បីទទួលបានដើមទុនបន្ថែម។ ឧទាហរណ៍ថា ក្រុមហ៊ុនមួយបានចាប់ដំណើរការ និងទទួលបានភាពជោគជ័យ ហើយម្ចាស់ក្រុមហ៊ុនមានបំណងចង់ពង្រីកអាជីវកម្មរបស់ខ្លួន ក៏ប៉ុន្តែមិនទាន់មានដើមទុនគ្រប់គ្រាន់ ដូច្នេះម្ចាស់ក្រុមហ៊ុននោះគឺអាចស្វែងរកដើមទុនបន្ថែមតាមរយៈទីផ្សារមូលបត្រ ដោយលក់ចំណែកកម្មសិទ្ធិរបស់ក្រុមហ៊ុននៅក្នុងទីផ្សារដំបូង (Primary Market) ដែលភាសាបច្ចេកទេសហៅថា "ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង" (Initial Public Offering - IPO)។ ចំណែកឯ វិនិយោគិនដែលបានទិញភាគហ៊ុននោះ គឺមានន័យថាពួកគេបានក្លាយម្ចាស់កម្មសិទ្ធិនៅក្នុងក្រុមហ៊ុននោះតាមចំណែកភាគហ៊ុនដែលគេបានកាន់កាប់។

សញ្ញាបណ្ណ (Bond) តំណាងឱ្យបំណុល មានន័យថាក្រុមហ៊ុនស្វែងរកហិរញ្ញប្បទានបន្ថែម តាមរយៈការធ្វើកិច្ចព្រមព្រៀងបង់ការប្រាក់ សម្រាប់ការប្រើប្រាស់ប្រាក់ដែលបានខ្ចី។ រដ្ឋាភិបាល, សាជីវកម្ម, ឬក្រុមហ៊ុនផ្សេងៗដែលត្រូវការដើមទុនបន្ថែម អាចខ្ចីប្រាក់ពីសាធារណជន និងត្រូវបង់ការប្រាក់លើប្រាក់កម្ចីនោះ ព្រមទាំងត្រូវសងប្រាក់ដើមទៅឱ្យវិនិយោគិនវិញនៅពេលដល់កាលកំណត់។ មូលបត្របំណុលនីមួយៗមានតម្លៃជាក់លាក់ ឧទាហរណ៍ មូលបត្របំណុលមួយមានតម្លៃ $1,000 ហើយមានអត្រាគូប៉ុង (ការប្រាក់) 4% ក្នុងមួយឆ្នាំ។ ដូច្នេះក្រុមហ៊ុននឹងត្រូវចំណាយប្រាក់ $20 សម្រាប់វិនិយោគិនពីរដងក្នុងមួយឆ្នាំ ($ 40 ជារៀងរាល់ឆ្នាំ) រហូតដល់កាលកំណត់សងប្រាក់ដើមជូនវិនិយោគិនវិញ។

**ភាពខុសគ្នារវាងភាគហ៊ុន និងសញ្ញាបណ្ណចំពោះវិនិយោគិន÷** ភាគហ៊ុន និងសញ្ញាបណ្ណ ជាឧបករណ៍ហិរញ្ញវត្ថុ ២ ផ្សេងគ្នាដែលក្រុមហ៊ុនប្រើប្រាស់សម្រាប់កៀរគរដើមទុនបន្ថែមសម្រាប់ពង្រីកអាជីវកម្មរបស់ខ្លួន។ ដោយសារភាគហ៊ុនជាចំណែកនៃកម្មសិទ្ធិនៅក្នុងក្រុមហ៊ុន ដូច្នេះវិនិយោគិនដែលកាន់កាប់ភាគហ៊ុនអាចទទួលការចំណេញ និងការខាតបង់ពីការវិនិយោគ។ វិនិយោគិនភាគហ៊ុន អាចទទួលបានអត្ថប្រយោជន៍ ប្រសិនបើក្រុមហ៊ុនមានដំណើរការល្អ ហើយតម្លៃរបស់ភាគហ៊ុនកើនឡើង។ ផ្ទុយទៅវិញ វិនិយោគិនអាចមានការខាតបង់ នៅពេលដែលក្រុមហ៊ុនជួបការលំបាក ហើយភាគហ៊ុនអាចនឹងធ្លាក់ថ្លៃ និងក្នុងករណីអាក្រក់បំផុតក្រុមហ៊ុនអាចក្ស័យធន។ ភាគហ៊ុនមានហានិភ័យខ្ពស់ជាងសញ្ញាបណ្ណ ក៏ប៉ុន្តែភាគហ៊ុនមានទំនោរផ្តល់ប្រាក់ចំណេញខ្ពស់ជាងសញ្ញាបណ្ណ សម្រាប់ការវិនិយោគរយៈពេលវែង ហើយភាគហ៊ុនមានការពេញនិយមច្រើន ពីសំណាក់វិនិយោគិនរយៈពេលវែងជាជាងវិនិយោគិនរយៈពេលខ្លី។ ចំណែកឯសញ្ញាបណ្ណ គឺមានកម្រិតហានិភ័យទាប ជាងភាគហ៊ុន ហើយពេញនិយមសម្រាប់វិនិយោគិនដែលត្រូវការចំណូលថេរ ព្រោះវិនិយោគិននឹងទទួលបានការបង់គូប៉ុងជាទៀតទាត់ និងទទួលប្រាក់ដើមវិញនៅពេលដល់កាលកំណត់។ ■

*អត្ថបទ៖ ណាង សេរីវុធ*
*ប្រភព៖ www.thebalance.com*


ទស្សនៈដែលមាននៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់ គ.ម.ក. ទេ ប៉ុន្តែជាទស្សនៈរបស់អ្នកនិពន្ធផ្ទាល់ខ្លួន ឬរបស់ក្រុមការងារ។

# ពុទ្ធិមូលបត្រ

លេខ ៣៥ ចេញផ្សាយឆ្នាំ២០១៩


## ប្រភេទមូលបត្រនៅកម្ពុជា

តាមរយៈបទដ្ឋានគតិយុត្តនៅកម្ពុជា មូលបត្រត្រូវបានចែកចេញជាពីរគឺ មូលបត្ររដ្ឋ និងមូលបត្រមហាជន។ បច្ចុប្បន្ននេះ មូលបត្ររដ្ឋមិនទាន់បានដាក់អោយដំណើការនូវឡើយទេ។ ចំណែកមូលបត្រមហាជន គឺស្ថិតក្រោមដែនសមត្ថកិច្ចរបស់គណៈកម្មការមូលបត្រកម្ពុជារួមមាន÷

**១. មូលបត្រកម្មសិទ្ធ** (Equity Securities) ÷ សំដៅដល់ផលប្រយោជន៍ ឬសិទ្ធិស្របច្បាប់លើមូលបត្រនៃក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គល ប្រតិស្រុត រួមទាំងនីតិបុគ្គលបរទេសប្រហាក់ប្រហែលហើយ រាប់បញ្ចូលទាំងភាគហ៊ុនដែលមានសិទ្ធបោះឆ្នោត និងគ្មានសិទ្ធបោះឆ្នោត ភាគហ៊ុនមិនបង់ថ្លៃគ្រប់ និងភាគហ៊ុនបរិមា។




**២. មូលបត្របំណុល** (Debt Securities) ÷ សំដៅដល់ឧបករណ៍ហិរញ្ញវត្ថុដែលបោះផ្សាយដោយបុគ្គលណាមួយដោយបញ្ជាក់ ឬទទួលស្គាល់នូវបំណុលរបស់ខ្លួនចំពោះ បុគ្គលមួយទៀតដែលបានអោយប្រាក់ខ្ចី ឬដាក់ប្រាក់បញ្ញើ ជាមួយបុគ្គលនោះ ឬបុគ្គលនោះជំពាក់តាមវិធីផ្សេងនេះ ហើយទោះបីជាមាន ឬគ្មានទ្រព្យដាក់ធានាក្តី។




**៣. អាជីវកម្មគម្រោងវិនិយោគរួម** (Collective Investment Schemes) ÷ គឺជាប្រភេទអាជីវកម្មមួយដែលអនុញ្ញាតឱ្យក្រុមហ៊ុនវិនិយោគណាមួយ អាចធ្វើការប្រមូលមូលនិធិឬ សាច់ប្រាក់ពីវិនិយោគក្នុងគម្រោង ដែលបានកំណត់ជាក់លាក់ណាមួយ ហើយក្រុមហ៊ុនវិនិយោគនោះត្រូវធ្វើការបែងចែកប្រាក់ចំណេញត្រលប់មកវិញសមាមាត្រ តាមចំនួនដែលវិនិយោគិនបានចូលរួម។ ដើម្បីអាចដំណើរ ការអាជីវកម្មគម្រោងវិនិយោគរួម ចាំបាច់ត្រូវមានការចូលរួមតួអង្គសំខាន់ៗមួយចំនួនដែលមានជាអាទិ៍ ÷ ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស ក្រុមហ៊ុនអភិបាលមូលនិធិ និងក្រុមហ៊ុនចែកចាយលក់ទិញ ត្រលប់មកវិញ ឬទូទាត់សង។




**៤. ឧបករណ៍និស្សន្ទ ឬ ឧបករណ៍ដេរីវេទីវ** (Derivative Instrument) ÷ សំដៅដល់កិច្ចសន្យាលើគម្លាតថ្លៃ (Contract For Difference) នៃឧបករណ៍ហិរញ្ញវត្ថុដើមដែលចេញពីមូលបត្រកម្មសិទ្ធ មូលបត្របំណុល សន្ទស្សន៍ លោហៈធាតុមានតម្លៃ ប្រេងឆៅ ឧស្ម័នធម្មជាតិ កសិផល រូបិយបណ្ណ រួមទាំងគម្រោងការពារថ្លៃដើម (Principle Protected Scheme) ជាដើម និងដែលត្រូវបានជួញដូរក្នុងទីផ្សារ។ ឧបករណ៍និស្សន្ទទាំងនេះ គឺជាឧបករណ៍ហិរញ្ញវត្ថុដែលជាប្រភេទមួយនៃមូលបត្រ។





**៥. ឧបករណ៍ហិរញ្ញវត្ថុ ដទៃទៀតដែលកំណត់ថាជាមូលបត្រ**


**អត្ថបទ÷ សុខជា ចរិយា**


**ឯកសារយោង÷**
- ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- ប្រកាសស្តីពីការបោះផ្សាយមូលបត្រកម្មសិទ្ធិជាសាធារណៈ
- ប្រកាសស្តីពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ
- ប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងគម្រោងវិនិយោគរួម
- ប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណ និងគ្រប់គ្រងការជួញដូរឧបករណ៍និស្សន្ទ

# ពុទ្ធិមូលបត្រ

*លេខ ៣៩ ចេញផ្សាយឆ្នាំ២០១៩*

## តួនាទីរបស់គណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ក្រុមហ៊ុនមូលបត្រ និងក្រុមហ៊ុនបោះផ្សាយមូលបត្រ

**គណៈកម្មការមូលបត្រកម្ពុជា** (Securities and Exchange Commission of Cambodia-SECC) ដែលហៅកាត់ថា **គ.ម.ក.** គឺជានិយ័តករ និងជាអាជ្ញាធរតែមួយគត់ដែលគ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍន៍ទីផ្សារមូលបត្រ តាមរយៈការបង្កើតច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនានា។ គ្រប់អាជីវកម្មទាំងអស់ដែលពាក់ព័ន្ធនឹងមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវតែទទួលបានអាជ្ញាបណ្ណ ការអនុញ្ញាត និងការទទួលស្គាល់ពី **គ.ម.ក.** រួមទាំងការបោះផ្សាយលក់មូលបត្រជាសាធារណៈផងដែរ។

*រូបសញ្ញារបស់ **គ.ម.ក.***

ចំណែក**ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា** (Cambodia Securities Exchange-CSX) ហៅកាត់ថា **ផ.ម.ក.** ដែលដើរតួនាទីសំខាន់ក្នុងការផ្តល់នូវប្រព័ន្ធជាត់ទាត់ និងទូទាត់ ប្រព័ន្ធរក្សាទុកមូលបត្រ និងផ្តល់នូវប្រព័ន្ធប្រតិបត្តិការជួញដូរមូលបត្រសម្រាប់ក្រុមហ៊ុនមូលបត្រ (ក្រុមហ៊ុនធានាទិញមូលបត្រ ពាណិជ្ជករមូលបត្រ និងឈ្មួញជើងសាមូលបត្រ) និងសមាជិករបស់ **ផ.ម.ក.** ព្រមទាំងវិនិយោគិនទូទៅផងដែរ ដើម្បីធានាឱ្យបាននូវបរិយាកាសអំណោយផល តណនេយ្យភាព តម្លាភាព និងប្រសិទ្ធភាពខ្ពស់ក្នុងទីផ្សារ។

ផ្សារមូលបត្រកម្ពុជា

CSX

*រូបសញ្ញារបស់ **ផ.ម.ក.***

ដើម្បីធ្វើការជួញដូរមូលបត្របាន វិនិយោគិនទូទៅ ត្រូវមានអត្តសញ្ញាណវិនិយោគិន (Investor ID) និងគណនីជួញដូរដែលត្រូវទៅបើកនៅ**ក្រុមហ៊ុនមូលបត្រ** (Securities Firms) ដែលរួមមានក្រុមហ៊ុនធានាទិញមូលបត្រ ពាណិជ្ជករមូលបត្រ និងឈ្មួញជើងសាមូលបត្រ។ ក្រុមហ៊ុនធានាទិញមូលបត្រ មានសិទ្ធក្នុងការសម្របសម្រួល និងជួយដល់ក្រុមហ៊ុនទាំងឡាយណាដែលមានបំណងចង់បោះផ្សាយលក់មូលបត្រ (មូលបត្រកម្មសិទ្ធ មូលបត្របំណុល និងឧបករណ៍ហិរញ្ញវត្ថុដទៃទៀត) ជាសាធារណៈ និងអាចធ្វើការជួញដូរមូលបត្រសម្រាប់គណនីក្រុមហ៊ុនផ្ទាល់ និងជួញដូរតាមការបញ្ជារបស់វិនិយោគិន។ ចំណែកឯពាណិជ្ជករមូលបត្រ មានសិទ្ធក្នុងការជួញដូរមូលបត្រសម្រាប់គណនីក្រុមហ៊ុនផ្ទាល់ និងជួញដូរតាមការបញ្ជារបស់វិនិយោគិន។ ចំពោះឈ្មួញជើងសាមូលបត្រ មានសិទ្ធអាចធ្វើបានតែការជួញដូរតាមការបញ្ជាទិញ-លក់របស់វិនិយោគិនតែប៉ុណ្ណោះ។

ការជួញដូរមូលបត្រអាចប្រព្រឹត្តទៅបានលុះត្រាតែមាន **ក្រុមហ៊ុនបោះផ្សាយមូលបត្រ** (Issuers) ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ។ ក្រុមហ៊ុនបោះផ្សាយមានសិទ្ធបោះផ្សាយលក់មូលបត្រកម្មសិទ្ធ មូលបត្របំណុល ឬឧបករណ៍ហិរញ្ញវត្ថុដទៃទៀតនៅក្នុងទីផ្សារមូលបត្រ ទៅតាមទំហំរបស់ក្រុមហ៊ុនដែលចង់បោះផ្សាយ។ គោលបំណងរបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រ គឺដើម្បីកៀរគរមូលធនពីសាធារណៈជន វិនិយោគិនទាំងក្នុង និងក្រៅស្រុកក្នុងទិសដៅពង្រីកអាជីវកម្ម និងប្រតិបត្តិការអាជីវកម្មរបស់ខ្លួនប្រកបដោយស្ថិរភាព និងការប្រកួតប្រជែងខ្ពស់ទាំងថ្នាក់ជាតិ អន្តរជាតិ និងក្នុងតំបន់។




****សម្គាល់**

- ក្រុមហ៊ុនដែលមានបំណងធ្វើការបោះផ្សាយលក់មូលបត្រជាសាធារណៈត្រូវទៅទាក់ទងក្រុមហ៊ុនធានាទិញមូលបត្រ ឬក្រុមហ៊ុនផ្តល់ប្រឹក្សាហិរញ្ញវត្ថុ។
- វិនិយោគិន ដែលមានបំណងចង់ធ្វើការជួញដូរមូលបត្រ ត្រូវទាក់ទងទៅក្រុមហ៊ុនមូលបត្រ (ក្រុមហ៊ុនធានាទិញមូលបត្រ ពាណិជ្ជករមូលបត្រ ឬឈ្មួញជើងសាមូលបត្រ) ដែលទទួលបានអាជ្ញាបណ្ណពី **គ.ម.ក.**។

**ចំពោះបញ្ជីក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាបណ្ណពី **គ.ម.ក** អាចរកបានតាមរយៈ QR Code:

**អត្ថបទ÷ ហាយ សុវណ្ណា**

**ប្រភព÷** www.secc.gov.kh & www.csx.com.kh


ទស្សនៈដែលមាននៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស គ.ម.ក. ទេ ប៉ុន្តែជាទស្សនៈរបស់អ្នកនិពន្ធផ្ទាល់ខ្លួន ឬរបស់ក្រុមការងារ។

# ពុទ្ធិមូលបត្រ

គណៈកម្មការមូលបត្រកម្ពុជា

លេខ ៤៩ ចេញផ្សាយ ឆ្នាំ២០២០

## ការជួញដូរមូលបត្របំណុលនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក.)

បន្ទាប់ពីទីផ្សារមូលបត្របំណុល ត្រូវបានដាក់ឱ្យដំណើរការ រហូតមកដល់ពេលនេះ មានក្រុមហ៊ុនចំនួន៦បានបោះផ្សាយលក់មូលបត្របំណុល (សញ្ញាបណ្ណសាជីវកម្ម) ជាសាធារណៈ ដែលក្នុងនោះរួមមាន÷ **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហត្ថាកសិករ លីមីតធីត (HKL), គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិល អូ អិល ស៊ី (LOLC), ធនាគារវឌ្ឍនៈអាស៊ីចំកាត់ (ABA), ធនាគារ ភ្នំពេញពាណិជ្ជ ម.ក, គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ និងក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក។**

ពិតត្រឹមថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២០ ក្នុងចំណោមសញ្ញាបណ្ណសាជីវកម្មទាំង ៦ មានការជួញដូរសញ្ញាបណ្ណសាជីវកម្ម ABA ចំនួន ២៤២ ឯកតា ក្នុងតម្លៃជួញដូរសរុប ២៤.២៤០.០០០ រៀល និងសញ្ញាបណ្ណសាជីវកម្មប្រាសាក់ចំនួន ៤០០.០០០ឯកតា ក្នុងតម្លៃជួញដូរសរុប ៤០.០៩៤.៨០០.០០០ រៀល។

### ការជួញដូរមូលបត្របំណុលអាចធ្វើឡើងដោយរបៀបណា?

ដើម្បីអាចជួញដូរមូលបត្របាន វិនិយោគិនត្រូវមានគណនីជួញដូរ។ក្នុងករណីវិនិយោគិនមិនទាន់មានគណនីជួញដូរ វិនិយោគិនអាចទាក់ទងទៅក្រុមហ៊ុនមូលបត្រណាមួយ ដែលទទួលបានអាជ្ញាបណ្ណពីគណៈកម្មការមូលបត្រកម្ពុជា(**គ.ម.ក**) និងជាសមាជិករបស់ **ផ.ម.ក** ដើម្បីបើកគណនីជួញដូរ ហើយដើម្បីអាចបើកគណនីជួញដូរបាន វិនិយោគិនត្រូវមានលេខអត្តសញ្ញាណវិនិយោគិន ដែលវិនិយោគិនអាចស្នើសុំតាមរយៈក្រុមហ៊ុនមូលបត្រនោះ ឬស្នើសុំដោយផ្ទាល់ទៅកាន់ **គ.ម.ក**។

ដូចការជួញដូរមូលបត្រកម្មសិទ្ធិដែរ វិនិយោគិនអាចជួញដូរមូលបត្របំណុលនៅ **ផ.ម.ក.** តាមរយៈការបង្គាប់បញ្ជាទៅកាន់ក្រុមហ៊ុនមូលបត្រ ដែលវិនិយោគិនបានបើកគណនីជួញដូរជាមួយ ដោយអនុលោមតាមវិធានប្រតិបត្តិការទីផ្សាររបស់ **ផ.ម.ក.**។

**ថ្ងៃ និងម៉ោងជួញដូរ÷** ថ្ងៃចន្ទ-សុក្រ លើកលែងថ្ងៃឈប់សម្រាកជាសាធារណៈ (ម៉ោង០៨:០០ព្រឹក-០៣:០០រសៀល)។

**វិធីសាស្រ្តជួញដូរ÷** ការជួញដូរមូលបត្របំណុលអាចធ្វើឡើងតាមវិធីសាស្រ្តជួញដូរតាមដេញថ្លៃ (Auction Trading Method-**ATM**) ឬវិធីសាស្រ្តជួញដូរតាមការចរចា (Negotiated Trading Method-**NTM**)។

-**ATM** ជាវិធីសាស្រ្តផ្គូរផ្គងបញ្ជាទិញ-លក់ដោយស្វ័យប្រវត្តិតាមវិធីសាស្រ្តដេញថ្លៃដោយយកថ្លៃតែមួយ ឬវិធីសាស្រ្តដេញថ្លៃដោយយកថ្លៃច្រើនដូចមូលបត្រកម្មសិទ្ធិដែរ។ វិនិយោគិនអាចដាក់បញ្ជាទិញ-លក់មូលបត្របំណុលតាមរយៈ ATM ចាប់ពីម៉ោង ០៨:០០ព្រឹក ០៣:០០រសៀល និងឯកតាបញ្ជាចាប់ពី ១ ឯកតាមូលបត្របំណុលដល់ ១០.០០០ ឯកតាមូលបត្របំណុល។ ការផ្គូផ្គងបញ្ជាទិញ-លក់នេះត្រូវធ្វើឡើងដោយផ្អែកលើអាទិភាពថ្លៃ និងពេលវេលា ករណីបញ្ជាមានថ្លៃដូចគ្នា។




-ចំពោះ **NTM** ជាវិធីសាស្រ្តផ្គូរផ្គងបញ្ជាតាមការចរចាទិញនិងលក់មួយគូ បន្ទាប់ពីអ្នកទិញ និងអ្នកលក់បានចរចា និងព្រមព្រៀងលើលក្ខខណ្ឌនៃការជួញដូរ។ ដើម្បីផ្គូរផ្គងបញ្ជាទិញ និងលក់តាមការចរចានេះបាន ចាំបាច់ត្រូវមានព័ត៌មានលម្អិតដូចគ្នាទាំងស្រុង (ឈ្មោះមូលបត្រ, ថ្លៃ, បរិមាណ និងលេខកូដជួញដូរ)។ វិនិយោគិនអាចដាក់បញ្ជាទិញ-លក់មូលបត្របំណុលតាមរយៈ NTM ចាប់ពីម៉ោង ០៩:០០ព្រឹក-០៣:០០រសៀល ដោយឯកតាបញ្ជាចាប់ពី ១ ឯកតាមូលបត្របំណុល។




**ឯកតាតម្លាតថ្លៃ និងដែនបម្រែបម្រួលថ្លៃប្រចាំថ្ងៃ÷** តម្លាតថ្លៃបញ្ជាពីមួយទៅមួយគឺ ១ រៀល ហើយមិនមានការកំណត់ទៅលើដែនបម្រែបម្រួលថ្លៃជួញដូរប្រចាំថ្ងៃនោះទេ។■

*អត្ថបទ÷ លោកស្រី* ***ហេង ចាន់តារ៉ា***

***ឯកសារយោង÷*** *-ប្រកាសលេខ ០០៣/១៩ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៩ ស្តីពីការដាក់ឱ្យអនុវត្តនូវការកែប្រែវិធានប្រតិបត្តិការទីផ្សារមូលបត្រ របស់* ***ផ.ម.ក.***។

*-ប្រកាសលេខ០១៧/១៧ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តនូវវិធានប្រតិបត្តិការទីផ្សារមូលបត្ររបស់* ***ផ.ម.ក.***។

| និមិត្តសញ្ញាក្រុមហ៊ុនចុះបញ្ជី | ព័ត៌មានសង្ខេបរបស់ក្រុមហ៊ុនចុះបញ្ជី |
|---|---|
| PHNOM PENH WATER SUPPLY AUTHORITY | ▪ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (PWSA)<br>▪ ប្រភេទភាគហ៊ុន÷ ភាគហ៊ុនធម្មតា<br>▪ ចំនួនភាគហ៊ុនចុះបញ្ជី÷ 86,973,162 ភាគហ៊ុន<br>▪ ថ្លៃ IPO÷ 6,300 រៀល<br>▪ គេហទំព័រ÷ www.ppwsa.com.kh |
| GTI GRAND TWINS | ▪ ក្រុមហ៊ុន ហ្គ្រេនធ្វីន អ៊ិនធើណេសិនណល(ខេមបូឌា) ភីអិលស៊ី (GTI)<br>▪ ប្រភេទភាគហ៊ុន÷ ភាគហ៊ុនធម្មតា<br>▪ ចំនួនភាគហ៊ុនចុះបញ្ជី÷ 40,000,000 ភាគហ៊ុន<br>▪ ថ្លៃ IPO÷ 9,640 រៀល<br>▪ គេហទំព័រ÷ www.grandtwins.com.kh |
| PHNOM PENH AUTONOMOUS PORT | ▪ កំពង់ផែស្វយ័តភ្នំពេញ (PPAP)<br>▪ ប្រភេទភាគហ៊ុន÷ ភាគហ៊ុនមានសិទ្ធិបោះឆ្នោត<br>▪ ចំនួនភាគហ៊ុនចុះបញ្ជី÷ 20,684,365 ភាគហ៊ុន<br>▪ ថ្លៃ IPO÷ 5,120 រៀល<br>▪ គេហទំព័រ÷ www.ppap.com.kh |
| PPSEZ Phnom Penh Special Economic Zone | ▪ ក្រុមហ៊ុនភ្នំពេញ អេសអ៊ីហ្សិតភីអិលស៊ី (PPSP)<br>▪ ប្រភេទភាគហ៊ុន÷ ភាគហ៊ុនមានសិទ្ធិបោះឆ្នោត<br>▪ ចំនួនភាគហ៊ុនចុះបញ្ជី÷ 57,875,000 ភាគហ៊ុន<br>▪ ថ្លៃ IPO÷ 2,860 រៀល<br>▪ គេហទំព័រ÷ www.ppsez.com |
| PORT AUTONOME DE SIHANOUKVILLE P.A.S | ▪ កំពង់ផែស្វយ័តក្រុងព្រះសីហនុ (PAS)<br>▪ ប្រភេទភាគហ៊ុន÷ ភាគហ៊ុនមានសិទ្ធិបោះឆ្នោត<br>▪ ចំនួនភាគហ៊ុនចុះបញ្ជី÷ 85,771,967 ភាគហ៊ុន<br>▪ ថ្លៃ IPO÷ 5,040 រៀល<br>▪ គេហទំព័រ÷ www.pas.gov.kh |

| និមិត្តសញ្ញាក្រុមហ៊ុនចុះបញ្ជី | ព័ត៌មានសង្ខេបរបស់ក្រុមហ៊ុនចុះបញ្ជី |
|---|---|
| ហត្ថាកសិករ លីមីតធីត<br>HATTHA KAKSEKAR LIMITED | ▪ ឈ្មោះមូលបត្របំណុល÷ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីតធីត (HKL21A)<br>▪ ចំណាត់ថ្នាក់លទ្ធភាពសង÷ BBB+<br>▪ ចំនួនបោះផ្សាយមូលបត្របំណុល (ឯកតា)÷ 1,200,000<br>▪ តម្លៃចារឹកនៃមូលបត្របំណុល÷ 100,000 រៀល<br>▪ អត្រាគូប៉ុង (%)÷ 8.50% (ប្រចាំឆ្នាំ)<br>▪ ចំនួននៃការទូទាត់÷ ប្រចាំឆមាស<br>▪ កាលបរិច្ឆេទទូទាត់÷ 14/05, 14/11<br>▪ រយៈពេលឥណប្រតិទាន (ឆ្នាំ)÷ 3 ឆ្នាំ<br>▪ ឥណប្រតិទាន÷ 14/11/2021 |
| LOLC | ▪ ឈ្មោះមូលបត្របំណុល÷ សញ្ញាបណ្ណ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី មានការការពារហានិភ័យអត្រាប្តូរប្រាក់ ២០១៩-២០២២ (Fx-indexed Bond 2019-2022 No.1)<br>▪ អ្នកបោះផ្សាយ÷ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិល អូ អិល ស៊ី (LOLC22A)<br>▪ ចំណាត់ថ្នាក់លទ្ធភាពសង÷ N/A<br>▪ ចំនួនបោះផ្សាយមូលបត្របំណុល (ឯកតា)÷ 536,000<br>▪ តម្លៃចារឹកនៃមូលបត្របំណុល÷ 100,000 រៀល<br>▪ អត្រាគូប៉ុង (%)÷ 8.00% (ប្រចាំឆ្នាំ)<br>▪ រយៈពេលឥណប្រតិទាន (ឆ្នាំ)÷ 3 ឆ្នាំ<br>▪ ឥណប្រតិទាន÷ 26/04/2022 |

| | |
|---|---|
| | ▪ ឈ្មោះមូលបត្របំណុល÷ សញ្ញាបណ្ណ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី ២០១៩-២០២២ (Plain Bond 2019-2022 No.2)<br>▪ អ្នកបោះផ្សាយ÷ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិល អូ អិល ស៊ី (LOLC22B)<br>▪ ចំណាត់ថ្នាក់លទ្ធភាពសង÷ N/A<br>▪ ចំនួនបោះផ្សាយមូលបត្របំណុល (ឯកតា)÷ 264,000<br>▪ តម្លៃចារឹកនៃមូលបត្របំណុល÷ 100,000 រៀល<br>▪ អត្រាគូប៉ុង (%)÷ 9.00% (ប្រចាំឆ្នាំ)<br>▪ រយៈពេលឥណប្រតិទាន (ឆ្នាំ)÷ 3 ឆ្នាំ<br>▪ ឥណប្រតិទាន÷ 26/04/2022 |
| ABA BANK<br>NATIONAL BANK OF CANADA GROUP | ▪ ឈ្មោះមូលបត្របំណុល÷ សញ្ញាបណ្ណសាជីវកម្ម អេ ប៊ី អេ (ABA Bond)<br>▪ អ្នកបោះផ្សាយ÷ ធនាគារ វឌ្ឍនៈ អាស៊ីចំកាត់<br>▪ ចំណាត់ថ្នាក់លទ្ធភាពសង÷ B (វាយតម្លៃដោយ S&P Global Ratings)<br>▪ ចំនួនបោះផ្សាយមូលបត្របំណុល (ឯកតា)÷ 848,210<br>▪ តម្លៃចារឹកនៃមូលបត្របំណុល÷ 100,000 រៀល<br>▪ អត្រាគូប៉ុង (%)÷ 7.75% (ប្រចាំឆ្នាំ)<br>▪ រយៈពេលឥណប្រតិទាន (ឆ្នាំ)÷ 3 ឆ្នាំ<br>▪ ឥណប្រតិទាន÷ 14/08/2022 |